- លោកអភិបាលអូលីវីយេ ឱ្យគ្រីស្តបរិស័ទភ្ជាក់ស្មារតីភ្ជាប់ជាមួយព្រះជាម្ចាស់សាជាថ្មី <ទំព័រ៖១៨
- លោកអភិបាលអេនរីគេ ហ្វីកាបេដ្ជូ ធ្វើដំណើរទៅតាមព្រះសហាគមន៍ដើម្បីស្តាប់យោបល់គ្រីស្តបរិស័ទ <ទំព័រ៖១៧

កាសែតចេញផ្សាយប្រចាំខែ ឆ្នាំទី១២

# អ្នកនាំសារ
# the messenger

ខែ វិច្ឆិកា | ឆ្នាំ ២០២១ | លេខទី ១៤៥

www.catholiccambodia.org/km/ www.facebook.com/RVAKHMER/ https://khmer.rvasia.org/

November, 2021 | #145

# លោក ប្រាក់ ប៊ុនហុង ឧបដ្ឋាកថ្មីជាតិពូណងដំបូងគេ

«ឧបដ្ឋាកថ្មី ប្រៀបដូចជាស្ពានមួយ ដើម្បីបន្តបេសកកម្មប្រកាសដំណឹងល្អរបស់ព្រះជាម្ចាស់។ ក្នុងភូមិភាគនីមួយមានគ្រីស្តបរិស័ទជាច្រើន ដែលត្រូវការអ្នកមើលថែ និងផ្តល់សក្ខីភាពអំពីសកម្មភាពនានាដែលធ្វើសម្រាប់អ្នកក្រីក្រ។ នេះជាបេសកកម្មមួយដែលទទួលនិងជាស្ពានមួយយ៉ាងពិសេស»។ *លោកអភិបាល អូលីវីយេ ជ្មីតហស្លេ*



- នាយករដ្ឋមន្ត្រីកម្ពុជាផ្តល់អនុសាសន៍មួយចំនួនដល់រដ្ឋមន្ត្រីដឹកជញ្ជូនអាស៊ានក្នុងការប្រតិបត្តិការដឹកជញ្ជូន និងខ្សែច្រវាក់ផ្គត់ផ្គង់សកល >ទំព័រ-៣
- អ្នកជំនាញថា អាជីវករតូចតាចកំពុងតែប្រឈមនឹងបញ្ហាជាច្រើន >ទំព័រ-៩



# ព្រះជាម្ចាស់ ជាសេចក្ដីស្រឡាញ់ដ៏ពិតប្រាកដ! ខ្ញុំស្រឡាញ់ព្រះអង្គវិញយ៉ាងដូចម្ដេច?



បងប្អូនជាទីស្រឡាញ់! នៅដើមខែធ្នូនេះ យើងចូលក្នុងឆ្នាំថ្មី ក្នុងប្រតិទិនរបស់ព្រះសហគមន៍កាតូលិកដែលចាប់ ផ្ដើមដោយការរៀបចំចិត្តទទួលអំណរសប្បាយដែលព្រះជាម្ចាស់ជាព្រះបិតា បានប្រទានសម្រាប់ពិភពលោកទាំង មូល គឺព្រះយេស៊ូគ្រីស្ដជាអម្ចាស់។ (យ៉ូហាន៣,១៦)

ក្នុងជំនឿយើងទាំងអស់គ្នាសុទ្ធតែបានទទួលស្គាល់ និងជឿយ៉ាងច្បាស់លាស់ថា ព្រះជាម្ចាស់ជាព្រះបិតាស្រឡា ញ់ មនុស្សលោកហួសពីការស្មាន ព្រះអង្គមានព្រះហឫទ័យ ប្រណីសន្ដោសឥតព្រំដែន។

តើបងប្អូនធ្លាប់ទទួលបទពិសោធន៍ក្នុងជីវិត នៃសេចក្ដីស្រឡាញ់ដែលមកពីព្រះជាម្ចាស់យ៉ាងដូចម្ដេច?

បងប្អូនគ្រីស្ដបរិស័ទ ម្នាក់ៗសុទ្ធតែមានចម្លើយរៀងៗខ្លួន តាមបទពិសោធន៍ជីវិតរៀងៗខ្លួន។ បងប្អូនគ្រីស្ដបរិស័ទថ្មី គឺទទួលបទពិសោធន៍ផ្ទាល់ខ្លួនតែម្ដង ព្រោះជាមូលហេតុតែមួយគត់ដែលនាំឱ្យបងប្អូនប្ដូរជំនឿ ហើយដើរតាមព្រះយេស៊ូ ដោយទទួលអគ្គសញ្ញាជ្រមុជទឹក ទទួលជីវិតថ្មីក្នុងអង្គព្រះគ្រីស្ដយេស៊ូ។ បងប្អូនទទួលព្រះជន្មផ្ទាល់របស់ព្រះយេស៊ូគ្រីស្ដដែលមានព្រះជន្មរស់ឡើងវិញ ដោយសារព្រះហឫទ័យប្រណីសន្ដោសរបស់ព្រះជាម្ចាស់។ ព្រះជាម្ចាស់ជាសេចក្ដីស្រឡាញ់ (១យ៉ូហាន ៤,៧-២១) ។

ព្រះជាម្ចាស់ស្រឡាញ់យើងម្នាក់ៗជាខ្លាំងពិតមែន ព្រះអង្គសូនយើងជារូបតំណាងរបស់ព្រះអង្គនៅលើផែនដីនេះ (កំណើតពិភពលោក ១,២៧)។ ពិតមែន! យើងជឿថា ព្រះជាម្ចាស់គង់នៅជាប់ជាមួយនឹងយើងម្នាក់ៗ រួមដំណើរ ជាមួយយើងដូចសាវ័កពីរនាក់នៅតាមផ្លូវទៅអេម៉ាអ៊ូស។ ព្រះអង្គ កាន់ដៃយើងម្នាក់ៗ ដូចកាន់ដៃលោកសិលាមិនឱ្យលិចទៅក្នុងទឹកសមុទ្រ។ ព្រះអង្គថែរក្សាការពារយើង ដូចព្រះអង្គបានការពារជនជាតិអ៊ីស្រាអែលឱ្យបានដើរឆ្លងសមុទ្រក្រហម រួចផុតពីការសម្លាប់របស់កងទាហានរបស់ស្ដេចផារោន។

បើយ៉ាងដូច្នេះ សម្រាប់ខ្ញុំផ្ទាល់ខ្លួនម្នាក់ៗ តើបានស្រឡាញ់ព្រះជាម្ចាស់ ឬព្រះយេស៊ូយ៉ាងដូចម្ដេចដែរ? តើយើងបានដឹងថាខ្លួនផ្ទាល់បានស្រឡាញ់ព្រះជាម្ចាស់ និងព្រះយេស៊ូពិតមែនដែរឬទេ?

ពិតណាស់! ក្នុងបរិបទកូវីដ១៩ មានសំណួរច្រើនបានចោទសួរថា តើព្រះជាម្ចាស់នៅឯណា? ព្រះអង្គមើលឃើញទុក្ខលំបាករបស់យើងម្នាក់ៗដែរទេ?

ត្រង់នេះខ្ញុំសូមរំលឹកបងប្អូនថា តើត្រូវរកចម្លើយ ចំពោះសំណួរទាំងនេះយ៉ាងដូចម្ដេច? មានវិធីមួយគឺត្រូវអានព្រះគម្ពីរ ដើម្បីឈ្វេងយល់ឱ្យបានកាន់តែច្បាស់ថែមទៀត។ ម្យ៉ាងទៀតការចូលរួមពិធីអធិដ្ឋាន អភិបូជា ស្ដាប់ធម្មទេសនានានា របស់លោកបូជាចារ្យ លោកអភិបាល និងការចែកសក្ខីភាពនានារបស់បងប្អូនរួមជំនឿ អាចជួយឱ្យបងប្អូនរកឃើញចម្លើយ។ ឆ្នាំនេះព្រះសហគមន៍បានបើកសន្និបាទសកល ដើម្បីស្ដាប់យោបល់នានារបស់មនុស្សគ្រប់មជ្ឈដ្ឋានទាំងអស់ ព្រះសហគមន៍រួមដំណើរជាមួយគ្នាជាធ្លុងតែមួយ ចូលរួមប្រកាសដំណឹងល្អ។ សម្ដេចប៉ាបហ្វ្រង់ស៊ីស្កូ អញ្ជើញឱ្យយើងចេះស្ដាប់គ្នាទៅវិញទៅមក។

តើខ្ញុំបានយកពេលល្មមសម្រាប់ស្ដាប់ព្រះជាម្ចាស់ មានព្រះបន្ទូលមកកាន់ខ្លួនដែរឬទេ? តើខ្ញុំបានយកពេលដើម្បីរក្សាទំនាក់ទំនងជាមួយព្រះជាម្ចាស់ដែរឬទេ? ជាពិសេសក្នុងពេលបិទខ្ទប់ ដោយសារការការពារការឆ្លងមេរោគកូវីដ១។ ជាច្រើនខែ ដែលមិនបានទៅព្រះវិហារ។ នេះជាចំណុចត្រូវរិះគិត តើខ្ញុំស្រឡាញ់ព្រះជាម្ចាស់ដែរឬទេ?

ក្នុងព្រះសហគមន៍មានសកម្មភាពជាច្រើនណាស់ ក្នុងការបម្រើ និងស្រឡាញ់មនុស្សឯទៀត។ ហេតុអ្វីយើងត្រូវបម្រើ និងស្រឡាញ់បងប្អូន? ព្រះយេស៊ូបានអប់រំ ដែលម្នាក់ៗបានអាន និងស្ដាប់ព្រះបន្ទូលរបស់ព្រះយេស៊ូ។ ព្រះអង្គដាស់តឿនយើងឱ្យស្រឡាញ់បងប្អូន ស្រឡាញ់អ្នកជិតខាង ដូចព្រះអង្គស្រឡាញ់យើងដែរ ឬព្រះអង្គបានបញ្ជាក់ថាស្រឡាញ់អ្នកដទៃឱ្យបានដូចស្រឡាញ់ខ្លួនឯង។ លោកយ៉ូហានបញ្ជាក់ក្នុងលិខិតដាស់តឿនទៅកាន់គ្រីស្ដបរិស័ទទាំងអស់ថា ៖ «បើនរណាម្នាក់ពោលថា ខ្ញុំស្រឡាញ់ព្រះជាម្ចាស់ តែស្អប់បងប្អូនរបស់ខ្លួន អ្នកនោះនិយាយកុហកហើយ។ អ្នកណាមិនស្រឡាញ់បងប្អូនដែលខ្លួនមើលឃើញ ក៏ពុំអាចស្រឡាញ់ព្រះជាម្ចាស់ដែលខ្លួនមើលពុំឃើញនោះបានដែរ»។ (១យ៉ូហាន ៤,២០) តើខ្ញុំបានចាប់ផ្ដើមហើយឬនៅ នូវកិច្ចការបម្រើបងប្អូន ចូលរួមជាមួយព្រះសហគមន៍ក្នុងកិច្ចការសង្គហៈ?

ក្នុងរដូវរង់ចាំ ជាពេលវេលាប្រមើលមើលឡើងវិញ អំពីដួងចិត្តរបស់ខ្លួនយើងម្នាក់ ខ្ញុំបានទទួលស្គាល់ថាព្រះជាម្ចាស់ជាសេចក្ដីស្រឡាញ់ដ៏ពិតប្រាកដឬទេ? តើខ្ញុំបានស្រឡាញ់ព្រះអង្គវិញយ៉ាងដូចម្ដេច? កូវីដ១៩ មិនមែនជារនាំងរាំង ខណ្ឌចែកសេចក្ដីស្រឡាញ់របស់យើងចំពោះព្រះជាម្ចាស់ឡើយ!

Formation, Dailouge, Cooperation
ការិយាល័យផ្សព្វផ្សាយព័ត៌មានកាតូលិក

ចាងហ្វាង : លោក លី សុវណ្ណា
សេចក្ដីប្រកាសលេខ៖ ០៦០/១៩ ព.ម.រ.ល.អ/ ១៥-មករា-២០១៩
ផ្ទះលេខ ២៥ ផ្លូវលេខ ២៤២ សង្កាត់ បឹងព្រលិត ខណ្ឌ ៧ មករា រាជធានីភ្នំពេញ
Tel/Fax : (855) 23 224 120
Email : csccambodia@gmail.com / Website : www.catholiccambodia.org
Email : catholicphnompenh@gmail.com / Website : www.catholicphnompenh.org
https://www.facebook.com/CatholicCambodia / https://www.facebook.com/CatholicPhnomPenh



# នាយករដ្ឋមន្ត្រីកម្ពុជាផ្ដល់អនុសាសន៍មួយចំនួន ដល់រដ្ឋមន្ត្រីដឹកជញ្ជូនអាស៊ានក្នុងការប្រតិបត្តិការ ដឹកជញ្ជូន និងខ្សែច្រវាក់ផ្គត់ផ្គង់សកល

*អត្ថបទ៖ អមរិន្ទ ដានុត*

សម្ដេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានថ្លែងនៅក្នុងកិច្ចប្រជុំរដ្ឋមន្ត្រីដឹកជញ្ជូនអាស៊ានលើកទី២៧ និងកិច្ចប្រជុំពាក់ព័ន្ធកាលពីថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០២១ថា ជំងឺកូវីដ-១៩ នឹងបន្តបង្អាក់ប្រតិបត្តិការដឹកជញ្ជូន និងខ្សែច្រវាក់ផ្គត់ផ្គង់សកល ក្នុងរយៈពេលវែងខាងមុខ ដោយលោកបានផ្ដល់នូវអនុសាសន៍មួយចំនួនដល់រដ្ឋមន្ត្រីដឹកជញ្ជូនអាស៊ាន ដើម្បីធ្វើការពិចារណា។

សម្ដេចបានលើកឡើងថា រដ្ឋមន្ត្រីគួរបន្តតាមដាន និងត្រួតពិនិត្យយ៉ាងម៉ឺងម៉ាត់ លើដំណើរការនៃការអនុវត្តផែនការសកម្មភាព ក្រោមក្របខណ្ឌការស្ដារឡើងវិញគ្រប់ជ្រុងជ្រោយរបស់ អាស៊ាន ដោយសង្កត់ធ្ងន់លើការពង្រឹងការតភ្ជាប់ក្នុងតំបន់ ដើម្បីពង្រឹងសក្ដានុពលនៃទីផ្សារអាស៊ាន និងភាពធន់សង្គម-សេដ្ឋកិច្ច ។

សម្ដេចមានប្រសាសន៍ថា៖ «ការជំរុញការដឹកជញ្ជូនឆ្លងដែនរវាងបណ្ដាប្រទេសជាសមាជិកអាស៊ាន ប្រកបដោយភាពរលូន និងរហ័សទាន់ចិត្ត នឹងចូលរួមលើកស្ទួយខ្សែច្រវាក់ផលិតកម្ម ក្នុងតំបន់ ប្រកបដោយភាពរឹងមាំ និងនិរន្តភាព»។






ប្រមុខរាជរដ្ឋាភិបាលកម្ពុជា បានបន្តថា អាស៊ានត្រូវបន្តជំរុញធ្វើសកម្មភាពបន្ថែមទៀត ក្នុងគ្រប់ផ្នែកទាំងអស់នៃវិស័យដឹកជញ្ជូន ដើម្បីសម្រេចឱ្យបានជោគជ័យនូវការអនុវត្តផែនការយុទ្ធសាស្ត្រដឹកជញ្ជូនអាស៊ាន ២០១៦-២០២៥ រួមទាំងសកម្មភាពអាទិភាពនៃការពិនិត្យឡើងវិញពាក់កណ្ដាលអាណត្តិរបស់ផែនការនេះ ដែលជា ឆ្អឹងខ្នងនៃចក្ខុវិស័យសហគមន៍សេដ្ឋកិច្ចអាស៊ាន ២០២៥ ។

សម្ដេចតេជោ ហ៊ុន សែន បានមានប្រសាសន៍ថា ៖ «អាស៊ានត្រូវខិតខំពន្លឿនការចុះហត្ថលេខា និងដាក់ឱ្យអនុវត្តឱ្យបានឆាប់រហ័សនូវកិច្ចព្រមព្រៀងទូលំទូលាយ ស្ដីពីការដឹកជញ្ជូនតាមផ្លូវអាកាសអាស៊ាន-សហភាពអឺរ៉ុប (AECATA) កិច្ចព្រមព្រៀង សេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាសអាស៊ាន-នូវែលសេឡង់ (ANZ-ASA) និងកិច្ចព្រមព្រៀងសេវាកម្ម ដឹកជញ្ជូនតាមផ្លូវអាកាសអាស៊ាន-កូរ៉េ (AK-ASA) ជាដើម»។

លោកថា កិច្ចព្រមព្រៀងទាំងនេះ ជាមូលដ្ឋានគ្រឹះ ដ៏សំខាន់សម្រាប់កិច្ចសហប្រតិបត្តិការសង្គម-សេដ្ឋកិច្ច និងជាស្ពានតភ្ជាប់អាស៊ានទៅពិភពលោក ។

ជាមួយគ្នានោះដែរ សម្ដេចតេជោក៏បានលើកឡើងទៀតដែរថា អាស៊ានត្រូវពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការជាមួយដៃគូសន្ទនា និងដៃគូអភិវឌ្ឍន៍ បន្ថែមទៀត ដើម្បីពង្រីកកិច្ចសហប្រតិបត្តិការ ស្វែងរកមូលនិធិ និងជំនួយបច្ចេកទេស ព្រមទាំង ជំរុញការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនបន្ថែមទៀត នៅក្នុងតំបន់អាស៊ាន។

> ខ្ញុំសង្ឃឹមថា កម្ពុជា នឹងអាចទទួលបាន និងចូលរួមចែករំលែកបទពិសោធន៍ និងចំណេះដឹងល្អៗ ជាមួយសមាជិកដទៃទៀត សម្រាប់ជាទុនមួយក្នុងដំណើរអភិវឌ្ឍន៍វិស័យដឹកជញ្ជូនរបស់អាស៊ានទាំងមូល

សម្ដេចបានថ្លែងថា ៖ «ខ្ញុំសូមបញ្ជាក់ជូន អង្គពិធីផងដែរថា ក្រោយពីកម្ពុជាបានចូលជាសមាជិកវេទិកាដឹកជញ្ជូនអន្តរជាតិ ខ្ញុំសង្ឃឹមថា កម្ពុជា នឹងអាចទទួលបាន និងចូលរួមចែករំលែកបទពិសោធន៍ និងចំណេះដឹងល្អៗ ជាមួយសមាជិកដទៃទៀត សម្រាប់ជាទុនមួយក្នុងដំណើរអភិវឌ្ឍន៍វិស័យដឹកជញ្ជូនរបស់អាស៊ានទាំងមូល»។

ជាមួយគ្នានោះដែរ សម្ដេចបានលើកឡើងថា វិស័យដឹកជញ្ជូនបានបញ្ចេញឧស្ម័នកាបូនឌីអុកស៊ីដ ប្រមាណ ២០ ភាគរយ ដែលជាប្រភពចម្បងមួយនៃការប្រែប្រួលអាកាសធាតុ។

សម្ដេចថា ៖ «ក្នុងន័យនេះ, ខ្ញុំសូមស្នើឱ្យអាស៊ាន បន្តអនុវត្តយ៉ាង ខ្ជាប់ខ្ជួននូវផែនការយុទ្ធសាស្ត្រដឹកជញ្ជូនអាស៊ាន ២០១៦-២០២៥ និងលើកទឹកចិត្តចំពោះការប្រើប្រាស់យានយន្តដែលមានមេត្រីភាពបរិស្ថាន ព្រមទាំងជំរុញសមាហរណកម្ម ការធ្វើផែនការប្រើប្រាស់ ដីធ្លី និងផ្លូវថ្នល់ ដើម្បីដោះស្រាយផលប៉ះពាល់បរិស្ថានដែលបណ្ដាលមកពីការប្រើប្រាស់ថាមពល, ការកកស្ទះចរាចរ, ឧស្ម័ន, ផ្ទះកញ្ចក់ និងសារធាតុបំពុលផ្សេងៗទៀត»។

ឆ្លៀតឱកាសនោះដែរ សម្ដេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ក៏បានលើកឡើងពី បញ្ហាគ្រោះថ្នាក់ចរាចរណ៍ ផងដែរ ដោយ សម្ដេចបានបញ្ជាក់ថា អាស៊ានត្រូវបន្តខិតខំដោះស្រាយបញ្ហាគ្រោះថ្នាក់ចរាចរណ៍ ដែលនៅតែជាបញ្ហាប្រឈម ដ៏សំខាន់ នៅក្នុងតំបន់អាស៊ាន និងពិភពលោក ពិសេសតាមរយៈការជំរុញការអនុវត្តនូវលិខិតុបករណ៍គតិយុត្ត។

ការអនុវត្ត នូវលិខិតុបករណ៍គតិយុត្តដែលមានសេចក្ដីណែនាំ ស្ដីពីការកែលម្អស្ដង់ដាររបាយការណ៍ សម្រាប់រាយការណ៍អំពី គ្រោះថ្នាក់ចរាចរណ៍ ដោយផ្អែកទៅលើស្ដង់ដាររបាយការណ៍របស់អង្គការសហប្រជាជាតិ និងសេចក្ដីប្រកាសព្រុយណេដារ៉ូស្សាឡាម ស្ដីពីសុវត្ថិភាពចរាចរណ៍ផ្លូវគោក ឆ្នាំ ២០២០ និងទិសដៅថ្មី ឆ្នាំ ២០៣០ ដែលកំណត់គោលដៅកាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍ យ៉ាងតិច ៥០% ពីឆ្នាំ ២០២១ ទៅឆ្នាំ ២០៣០៕

# សំបុកសត្វស្លាបទឹកនៅបឹងព្រែកល្ពៅមានការកើនឡើងក្នុងភូមិសាស្ត្រខេត្តតាកែវ





*អត្ថបទ៖ អមរិទ្ធ ដានុត*

ក្រសួងបរិស្ថានបានលើកឡើងថា សំបុកសត្វស្លាបទឹកនៅបឹងព្រែកល្ពៅមានការកើនឡើងគួរឱ្យកត់សម្គាល់បញ្ជាក់ពីភាពប្រសើរឡើងនៃការអភិរក្ស និងបង្ហាញថាបឹងព្រែកល្ពៅពិតជាមានសារៈសំខាន់ខ្លាំងណាស់សម្រាប់សត្វស្លាបទឹករស់នៅនិងពងកូន។

ក្រុមអ្នកអភិរក្សនៃក្រសួងបរិស្ថាន និងអង្គការជីវិតសត្វស្លាបអន្តរជាតិ អង្គការជីវិតធម្មជាតិនៅកម្ពុជា និងអង្គការ Wildfowl & Wetlands Trust (WWT) ដែលកំពុងធ្វើការរួមគ្នាក្នុងការការពារនិងអភិរក្សតំបន់ការពារទេសភាពបឹងព្រែកល្ពៅក្នុងភូមិសាស្ត្រខេត្តតាកែវ បានរកឃើញថាសំបុកសត្វស្លាបទឹកជាច្រើនប្រភេទមានចំនួនកើនឡើងគួរឱ្យកត់សម្គាល់នៅក្នុងឆ្នាំ ២០២១ នេះ។



> កំណើនឡើងនូវប្រភេទសត្វស្លាបទឹកទាំងនេះ គឺជាដំណឹងដ៏រីករាយបំផុតសម្រាប់រដ្ឋាភិបាល និងសម្រាប់ក្រុមអភិរក្សដែលបានបង្ហាញឱ្យឃើញពីភាពប្រសើរឡើងនៅក្នុងការងារការពារនិងអភិរក្សជីវៈចម្រុះ និងធនធានធម្មជាតិ និងប្រសិទ្ធភាពខ្ពស់ក្នុងការអភិរក្ស

នេះបើតាមការឱ្យដឹងរបស់លោក នេត្រ ភក្ត្រា រដ្ឋលេខាធិការក្រសួងបរិស្ថាន កាលពីថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២១ នេះ ដោយយោងលើលទ្ធផលដែលទទួលបានពីមន្ត្រីអភិរក្ស។

បើតាមក្រសួងបរិស្ថានបានបញ្ជាក់ថា ក្រុមអ្នកអភិរក្សបានរកឃើញថា ការជំរឿនសំបុកសត្វស្លាបជាសកម្មភាពអង្កេតតាមដានថ្មី ដែលត្រូវបានអនុវត្តន៍នៅទីតាំងពងកូននៃសត្វស្លាបទឹកក្នុងតំបន់ការពារទេសភាពបឹងព្រែកល្ពៅក្នុងឆ្នាំ២០២០និង២០២១នេះ។

នៅក្នុងឆ្នាំ ២០២១ នេះ សំបុកសត្វស្លាបទឹកចំនួន ០៦ ប្រភេទត្រូវបានកត់ត្រាដែលក្នុងនោះរួមមាន៖ សំបុកសត្វចង្កៀលខ្យងចំនួន២៩៣១ សម្បុក ក្អែកទឹកតូចចំនួន ២៨៥ សំបុក សត្វខ្វែក ១៨០ សំបុក សត្វស្មោញ៣២ សំបុក ក្រសារប្រផេះ៣០ សំបុក សាធ្មង់២២ សំបុក។ បើប្រៀបធៀបនឹងឆ្នាំ២០២០ កន្លងមក ក្រុមអភិរក្សបានសង្កេតឃើញថា សំបុកសត្វទាំងនេះមានការកើនឡើងគួរឱ្យកត់សម្គាល់ដែលបានបង្ហាញថាបឹងព្រែកល្ពៅ ពិតជាមានសារៈសំខាន់ខ្លាំងណាស់សម្រាប់សត្វស្លាបទឹករស់នៅនិងពងកូន។

លោក នេត្រ ភក្ត្រា ដែលជាមន្ត្រីនាំពាក្យក្រសួងបរិស្ថានផងដែរនោះ ក៏បានវាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែងរួមគ្នាក្នុងការអភិរក្សរវាងមន្ត្រីឧទ្យានុរក្សក្រសួងបរិស្ថាន និងអង្គការជីវិតស្លាបអន្តរជាតិ អង្គការជីវិតធម្មជាតិនៅកម្ពុជា និងអង្គការ WWT។





លោកបានថ្លែងថា៖ «កំណើនឡើងនូវប្រភេទសត្វស្លាបទឹកទាំងនេះ គឺជាដំណឹងដ៏រីករាយបំផុតសម្រាប់រដ្ឋាភិបាល និងសម្រាប់ក្រុមអភិរក្សដែលបានបង្ហាញឱ្យឃើញពីភាពប្រសើរឡើងនៅក្នុងការងារការពារនិងអភិរក្សជីវៈចម្រុះ និងធនធានធម្មជាតិ និងប្រសិទ្ធភាពខ្ពស់ក្នុងការអភិរក្ស»។

ចំណែក នាយកអង្គការ BirdLife in Cambodia លោកប៊ូ វរសក្ស បានមានប្រសាសន៍ថា តំបន់ការពារទេសភាពបឹងព្រែកល្ពៅជាតំបន់ដីសើមដ៏សំខាន់ស្ថិតនៅតំបន់ដីសណ្តទន្លេមេគង្គនៃប្រទេសកម្ពុជា តំបន់នេះគាំទ្រដល់ការរស់នៅរបស់សត្វស្លាបជាច្រើនប្រភេទក្នុងនោះមានសត្វស្លាប់កម្រនិងជិតផុតពូជដូចជា ចាបព្រៃវែង ត្រដក់ធំ និងក្រៀលជាដើម។

លោកបានបន្តថា៖ «បន្ទាប់ពីរាជរដ្ឋាភិបាលបានដាក់តំបន់នេះជាតំបន់អភិរក្សចាប់តាំងពីឆ្នាំ២០០៧មក យើងឃើញថាចំនួនសត្វស្លាបទឹកមួយចំនួនមានការកើនឡើង ជាពិសេសចាប់ពីឆ្នាំ២០២០សត្វស្លាបទឹកជាច្រើនប្រភេទដូចចង្កៀលខ្យង ស្មោញ ជាដើមបានកាច់សំបុកពងកូននៅតំបន់នេះកាន់តែច្រើនឡើងៗ នេះជាសញ្ញាដ៏ល្អដែលកើតចេញពីកិច្ចសហការប្រឹងប្រែងគ្រប់គ្រងនិងអភិរក្សតំបន់ដីសើមនេះដែលដឹកនាំដោយក្រសួងបរិស្ថាន»។

លោក ប៊ូ វរសក្ស បានបន្តថា ក្នុងនាមអង្គការដៃគូនិងដើម្បីរក្សាទីជម្រកសំខាន់ៗដែលមានក្នុងតំបន់ការពារដីសើមនេះ អង្គការ BirdLife ត្រៀមខ្លួនក្នុងការចូលរួមជាមួយក្រសួងបរិស្ថាន និងអាជ្ញាធរខេត្តតាកែវក្នុងការពន្លឿនការកំណត់ និងបែងចែកតំបន់គ្រប់គ្រងតំបន់ការពារទេសភាពនេះ។

មន្ត្រីជាន់ខ្ពស់នៃក្រសួងបរិស្ថានបានអំពាវនាវប្រជាពលរដ្ឋ និងអាជ្ញាធរពាក់ព័ន្ធចូលរួមក្នុងការអភិរក្សតំបន់បឹងព្រែកល្ពៅនេះឱ្យបានគង់វង្ស និងចាត់វិធានការច្បាប់នានាប្រឆាំងនឹង អ្នកដែលទន្ទ្រានកាន់កាប់ដីអភិរក្សខុសច្បាប់ ដើម្បីរក្សាបាននូវទីជម្រក ក៏ដូចជាកន្លែងរកចំណី និងប្រភពទឹកសម្រាប់សត្វរស់នៅ ជាពិសេសប្រភេទសត្វស្លាបកម្រ។

លោក នេត្រ ភក្ត្រា បានបន្តថា៖ «បច្ចុប្បន្ននេះក្រសួងបរិស្ថានបាននិងកំពុងសិក្សារៀបចំកំណត់តំបន់ និងបោះបង្គោលព្រំតំបន់ការពារធម្មជាតិនៅទូទាំងប្រទេស ក្នុងនោះក៏មានបីតំបន់ការពារគម្រោងអភិរក្សនិងគ្រប់គ្រងតំបន់ដីសើមបឹងព្រែកល្ពៅ ស្ថិតក្រោមកិច្ចសហការរវាងក្រសួងបរិស្ថានដែលមានមន្ទីរបរិស្ថានខេត្តតាកែវ ជាសេនាធិការអង្គការជីវិតស្លាបអន្តរជាតិ អង្គការជីវិតធម្មជាតិនៅកម្ពុជា និងអង្គការWWT»។

តំបន់ការពារទេសភាពបឹងព្រែកល្ពៅមានផ្ទៃដីទំហំ ៨៣០៥ ហិកតាស្ថិតនៅក្នុងភូមិសាស្ត្រខេត្តតាកែវ៕









# លោក នេត្រ ភក្ត្រា៖ អនាម័យបរិស្ថានស្អាត ធ្វើឱ្យសុខភាពយើងល្អ ជៀសផុតពីការឆ្លងជំងឺ



*អត្ថបទ៖ អមរិទ្ធ ដានុត*

«សូមបងប្អូនប្រជាពលរដ្ឋបន្តចូលរួមសម្អាតអនាម័យបរិស្ថាននៅតាមផ្ទះសម្បែង ភូមិឃុំរបស់ខ្លួន ញែកសំរាមតាមប្រភេទ វេចខ្ចប់ទុកដាក់សំរាមឱ្យបានត្រឹមត្រូវ និងចូលរួមអនុវត្តវិធានការ ៣ កុំ ៣ ការពារដើម្បីភូមិដ្ឋានរបស់យើងមានអនាម័យបរិស្ថានល្អ មានផាសុកភាពសម្រាប់ការរស់នៅសុខុមាលភាពពលរដ្ឋយើងល្អ ជៀសផុតពីការឆ្លងជំងឺទាំងឡាយ»។ នេះគឺជាការថ្លែងអំពាវនាវរបស់លោក នេត្រ ភក្ត្រា រដ្ឋលេខាធិការក្រសួងបរិស្ថាន។

លោក នេត្រ ភក្ត្រា បានលើកឡើងដូចនេះ នាឱកាសនៃការប្រារព្ធទិវាអនាម័យបរិស្ថានជាតិ នៅព្រឹកថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២១ នេះនៅផ្សារត្រពាំងរពៅ សង្កាត់ព្រែកត្នោត ក្រុងបូកគោ ខេត្តកំពត ក្រោមប្រធានបទ «ភូមិឋានស្អាត សុខភាពល្អ ជីវិតរីករាយ»។

នាឱកាសនោះ លោកក៏បានលើកឡើងផងដែរថា សំណល់រឹងសំរាម មានប្រមាណជាង ១ ម៉ឺនតោនក្នុងមួយថ្ងៃ និង ១ ឆ្នាំជាង ៤ លានតោន និងមានកំណើនប្រមាណ ១៥% ក្នុងមួយឆ្នាំ។ ក្នុងសំណល់សំរាម ១០០% មានសំណល់សរីរាង្គប្រមាណ ៦៨% សំណល់ប្លាស្ទិក ប្រមាណ ២០% និងសំណល់រឹងជាង ១០%។

លោក នេត្រ ភក្ត្រា បានមានប្រសាសន៍ថា៖ «អ្វីដែលយើងត្រូវយកចិត្តទុកដាក់បន្ថែមគឺសំណល់ប្លាស្ទិក ដែលជាសំណល់ប្រកបដោយគ្រោះថ្នាក់ ប្រសិនបើយើងមិនគ្រប់គ្រងបានល្អ ព្រោះសំណល់ប្លាស្ទិកមានផ្ទុកសារធាតុគីមី។ រាជរដ្ឋាភិបាលកម្ពុជា បាននិងកំពុងបន្តជំរុញលើការអនុវត្តគោលនយោបាយជាតិគ្រប់គ្រងសំណល់រឹងសំរាមទីប្រជុំជន ដើម្បីគ្រប់គ្រង សំណល់រឹងសំរាមតាមទីប្រជុំជនឱ្យមានប្រសិទ្ធភាពខ្ពស់ គ្រប់គ្រងអនាម័យបរិស្ថានបានល្អ»។

លោកបានលើកឡើងថា ការប្រារព្ធទិវាអនាម័យបរិស្ថានជាតិនេះ ក៏ជាផ្នែកមួយនៃការចូលរួមជំរុញការអនុវត្តគោលនយោបាយជាតិភូមិឃុំសង្កាត់មានសុវត្ថិភាព ដែលលើកឡើងអំពីភូមិឃុំសង្កាត់ ត្រូវតែមានអនាម័យល្អ សោភ័ណភាព និងបរិស្ថានល្អ ដែលសំដៅលើការមានវិធានការក្នុងការគ្រប់គ្រងថែរក្សា និងការពារធនធានធម្មជាតិ និងបរិស្ថានអនាម័យក្នុងភូមិឃុំសង្កាត់ប្រកបដោយប្រសិទ្ធភាព ជាពិសេសយន្តការដោះស្រាយសំរាម ធ្វើឱ្យភូមិឃុំសង្កាត់មានសោភ័ណភាព និងផាសុកភាព។

ជាមួយគ្នានេះដែរ លោក នៃ គង់ អភិបាលរងនៃគណៈអភិបាលខេត្តកំពត ដែលបានចូលរួមជាអធិបតីក្នុងទិវាអនាម័យបរិស្ថានជាតិ ២៣ វិច្ឆិកានេះដែរ បានអំពាវនាវដល់ប្រជាពលរដ្ឋឱ្យចូលរួមថែរក្សាអនាម័យបរិស្ថាន បោសសម្អាតភូមិដ្ឋាន និងវេចខ្ចប់ទុកដាក់សំរាមឱ្យបានត្រឹមត្រូវដើម្បីធ្វើឱ្យបរិស្ថានទាំង ៣ ស្អាត គឺទឹកស្អាត ខ្យល់ស្អាត និងដីស្អាត។

លោកបានមានប្រសាសន៍ថា៖ «អនាម័យស្អាតនាំឱ្យសុខភាពល្អ និងក៏ជាផ្នែកមួយនៃការទាក់ទាញភ្ញៀវទេសចរជាតិ និងអន្តរជាតិផងដែរ»។

សូមបញ្ជាក់ថា ទិវាអនាម័យបរិស្ថានជាតិ ២៣ វិច្ឆិកា ត្រូវបានរាជរដ្ឋាភិបាលកម្ពុជាបង្កើតឡើងដោយអនុក្រឹត្យលេខ ៤៧ អនក្រ បក ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ១៩៩៥ ក្នុងគោលបំណងលើកកម្ពស់ការ អប់រំ ផ្សព្វផ្សាយ និងជំរុញចលនាប្រជាពលរដ្ឋ ព្រះសង្ឃ កងកម្លាំងប្រដាប់អាវុធ មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ សិស្ស និស្សិតឱ្យចូលរួមធ្វើអនាម័យ កែលម្អសោភ័ណភាពទីក្រុង ទីប្រជុំជន ភូមិឋាន វត្តអារាម សាលារៀន មន្ទីរពេទ្យ សំដៅរួមចំណែក កសាងសង្គមកម្ពុជាឱ្យមានបរិស្ថានល្អស្អាត និងភាពស្រស់បំព្រង៕

# កម្ពុជាបានរកឃើញករណីឆ្លងវីរុសកូវីដ-១៩ បំប្លែងថ្មីអូមីក្រុងលើកដំបូងលើស្ត្រីជនជាតិខ្មែរ

*អត្ថបទ៖ អមរិទ្ធ ដានុត*

ក្រសួងសុខាភិបាលបានប្រកាសរកឃើញករណីវិជ្ជមានកូវីដ-៩ បម្លែងថ្មី ឈ្មោះ អូមីក្រុង (Omicro) ម្នាក់ទៅលើស្ត្រីជនជាតិខ្មែរ ដែលបានធ្វើដំណើរមកពីប្រទេសហ្គាណា (អាហ្វ្រិកខាងលិច) ដោយយោងតាមលទ្ធផលវិភាគបញ្ជាក់ដោយវិទ្យាស្ថានប៉ាស្ទ័រកម្ពុជានៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២១ ។

យោងតាមសេចក្តីជូនព័ត៌មានរបស់ក្រសួងសុខាភិបាល បានលើកឡើងថា ករណីវិជ្ជមានកូវីដ-១៩ អូមីក្រុងនេះ ត្រូវបានរកឃើញលើស្ត្រីជនជាតិខ្មែរ អាយុ ២៣ឆ្នាំ មានអាស័យដ្ឋានស្នាក់នៅឃុំតាបុក ស្រុកបារិត ខេត្តស្វាយរៀង។

ក្រសួងបានបន្តថា ស្ត្រីរូបនេះ មានផ្ទៃពោះចំនួន ១៥សប្តាហ៍ រួចបានធ្វើដំណើរតាមជើងហោះហើរចេញ ពីប្រទេសហ្គាណា (អាហ្វ្រិកខាងលិច) ឆ្លងកាត់តាមឌូបៃ រួចបន្តជើងហោះហើរនៅព្រលានយន្តហោះទី ក្រុងបាងកកនៃប្រទេសថៃ (ដោយនៅរងចាំជើងហោះហើរចំនួន១៤ម៉ោង) ទើបបន្តដំណើរមកដល់ ប្រទេសកម្ពុជានៅថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០២១ ។

នៅពេលមកដល់អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ ក្រុមការងារក្រសួងសុខាភិបាល បានធ្វើតេស្តរហ័សលើវត្ថុសំណាករបស់គាត់ ឃើញមានវិជ្ជមានវីរុសកូវីដ-១៩ ហើយក៏បានបញ្ជូនវត្ថុសំណាកទៅកាន់វិទ្យាស្ថានប៉ាស្ទ័រកម្ពុជា ដើម្បីវិភាគបញ្ជាក់រកវីរុសកូវីដ-១៩ បម្លែងថ្មីអូមីក្រុងនេះ។

បច្ចុប្បន្ននេះ អ្នកជំងឺខាងលើ កំពុងសម្រាកព្យាបាលនៅមជ្ឈមណ្ឌលជាតិកំចាត់រោគរបេង និង ហង់សិន ក្នុងរាជធានីភ្នំពេញ។

ក្រសួងសុខាភិបាលបានបន្តធ្វើការអំពាវនាវដល់បងប្អូនប្រជាពលរដ្ឋទាំងអស់បន្តអនុវត្តវិធានការ ការពារខ្លួនដោយហ្មត់ចត់ ជាពិសេសវិធានការ ការពារ និង ៣កុំ" និងចាក់វ៉ាក់សាំងកូវីដ-១៩ នៅពេលដល់ វេនលោកអ្នកឱ្យបានគ្រប់ៗគ្នា ដើម្បីរួមគ្នាទប់ស្កាត់ការចម្លងវីរុសកូវីដ-១៩នៅតាមសហគមន៍៕

# ក្រសួងរៀបចំដែនដី នគររូបនីយកម្ម និងសំណង់ថ្មី ត្រូវបានសម្ពោធឱ្យប្រើប្រាស់

*អត្ថបទ៖ អមរិន្ទ ដានុត*

អគារក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ជាសមិទ្ធផលមួយ ដែលបង្ហាញពីគុណតម្លៃនៃការដឹកនាំរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការលើកកម្ពស់តម្លៃស្ថាបត្យកម្ម ដែលជាស្នាដៃផ្ទាល់របស់កូនខ្មែរ ហើយក៏បានបង្ហាញនូវសមត្ថភាពរបស់រាជរដ្ឋាភិបាលលើការគ្រប់គ្រង និងប្រើប្រាស់ថវិកាជាតិ ដើម្បីបង្កើតនូវសមិទ្ធផលជាទីមោទនភាពសម្រាប់ជាតិផងដែរ។



អគារនេះត្រូវបានប្រកាសសម្ពោធដាក់ឱ្យប្រើប្រាស់នាព្រឹកថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០២១នេះ ក្រោមអធិបតីភាពរបស់សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ដោយសម្តេចបានអបអរសាទរចំពោះសមិទ្ធផលនៃអគារទីស្តីការក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ដែលត្រូវដាក់ឲ្យប្រើប្រាស់នាពេលនេះទេ។

អគារទីស្តីការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ មានទីតាំងស្ថិតនៅ ភូមិអន្លង់ក្ងាន សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ នាប៉ែកខាងជើងឆៀងខាងលិចរាជធានីភ្នំពេញ ត្រូវបានប្រារព្ធពិធីបើការដ្ឋានសាងសង់នៅថ្ងៃទី២៨ ខែមករា ឆ្នាំ២០២០។

អគារនៃក្រសួងនេះសាងសង់នៅលើផ្ទៃដីទំហំ ៤.៥ហិកតា មានទំហំតួអគារបណ្តោយប្រវែង ១៣២.៧ ម៉ែត្រ និងទទឹងប្រវែង ៩៤.៧ម៉ែត្រ មានចំនួន ៨ជាន់ កម្ពស់សរុបពីទ្រនាប់ខ្សាច់ដល់ចុងកំពូលបុស្បុក ៨៨.៥ម៉ែត្រ ក្នុងនោះមានកម្ពស់បុស្បុក ៣៣.២៨ម៉ែត្រ មានចំណតរថយន្តប្រមាណ ៤៥០គ្រឿង និងចំណតទោចក្រយានយន្តជាច្រើនគ្រឿងទៀត។

> ត្រូវរួមថែរក្សាសមិទ្ធផលដែលកើតមាននេះអោយបានគង់វង្សប្រើប្រាស់ឱ្យបានយូរអង្វែង មានកន្លែងធ្វើការល្អ ហើយ ត្រូវធ្វើការអោយមានប្រសិទ្ធភាព និងចំនុចមួយទៀតត្រូវចេះសន្សំ ទឹក ភ្លើង ផងដែរ

សម្តេចតេជោនាយករដ្ឋមន្ត្រី បានមានប្រសាសន៍ក្នុងពិធីនេះថា ៖ «នៅក្នុងឆ្នាំនេះយើងនឹងសម្ពោធអគារក្រសួងចំនួន៣ រួមមានក្រសួងសាធារណការ និងដឹកជញ្ជូនដែលបានសម្ពោធរួចក្រសួងរៀបចំដែនដីននគររូបនីយកម្ម និងសំណង់ដែលសម្ពោធនាពេលនេះ និងនៅចុងឆ្នាំ២០២១យើងនឹងសម្ពោធអគារទីស្តីការក្រសួងការពារជាតិដែលនឹងត្រូវសម្ពោធចំខួបលើកទី២៣ នៃការដាក់ចេញនយោបាយឈ្នះ ឈ្នះ គឺថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២១»។

សម្តេចតេជោនាយករដ្ឋមន្ត្រី ក៏បានដាស់តឿនរំលឹក ដល់មន្ត្រីថ្នាក់ដឹកនាំក្រសួងរៀបចំដែនដី នគររូបនីយកម្ម និងសំណង់ អោយខិតខំបំពេញការងារឱ្យបានល្អប្រសើរ។ សម្តេចតេជោបានសង្កត់ធ្ងន់ថា៖ «ត្រូវរួមថែរក្សាសមិទ្ធផលដែលកើតមាននេះអោយបានគង់វង្សប្រើប្រាស់ឱ្យបានយូរអង្វែង មានកន្លែងធ្វើការល្អហើយ ត្រូវធ្វើការអោយមានប្រសិទ្ធភាព និងចំនុចមួយទៀតត្រូវចេះសន្សំ ទឹក ភ្លើង ផងដែរ»។

នៅក្នុងឱកាសនេះផងដែរ សម្តេចតេជោនាយករដ្ឋមន្ត្រីក៏បានផ្តល់នូវការណែនាំទៅកាន់មន្ត្រីថ្នាក់ដឹកនាំក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ដែលទីនូវ៣ចំនុចសំខាន់រួចមាន៖ត្រូវបន្តខិតខំចេញប័ណ្ណកម្មសិទ្ធិអោយប្រជាពលរដ្ឋអោយបានឆាប់,ត្រូវបន្តខិតខំដោះស្រាយជំលោះដីធ្លី ជាពិសេសការដោះក្រៅប្រព័ន្ធតុលាការ និងត្រូវខិតខំបន្តដោះស្រាយដីសម្បទានសង្គមកិច្ចជាបន្តបន្ទាប់ទៀត។

លោក ជា សុផារ៉ា រដ្ឋមន្ត្រីក្រសួងរៀបចំដែនដីននគររូបនីយកម្ម និងសំណង់ បានថ្លែងក្នុងពិធីនេះថា អគារនេះមានជាន់ផ្ទាល់ដី មានសាលបដិសណ្ឋារកិច្ច អាហារដ្ឋាន ឃ្លាំង បណ្ណាល័យ មជ្ឈមណ្ឌលបណ្តុះបណ្តាល ការិយាល័យច្រកចេញចូលតែមួយ និងសួនផ្ការំដួលជាដើម។

លោកបានលើកឡើងថា ជាន់ទី១ មានសាលប្រជុំខ្នាតតូចនិងមធ្យម ចំណុះ ៣៨៦នាក់ ឃ្លាំងនិងបណ្តុំនៃនាយកដ្ឋានទាំងឡាយរបស់ក្រសួង។ ជាន់ទី២ មានសាលប្រជុំខ្នាតធំចំណុះ ២០២១នាក់ បណ្តុំនៃអគ្គនាយកដ្ឋាន គណៈស្ថាបត្យករ និងឃ្លាំង។ ជាន់ទី៣ មានបណ្តុំនៃអគ្គនាយកដ្ឋាន នាយកដ្ឋាន និងឃ្លាំង។

លោក ជា សុផារ៉ា បានបន្តថា ជាន់ទី៤ មានការិយាល័យរដ្ឋមន្ត្រី រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ ខុទ្ទកាល័យ សាលសវនាការអន្តរជាតិ សាលចុះពិធីសារ បន្ទប់ប្រជុំ បន្ទប់ពិធីការ និងការិយាល័យអគ្គាធិការដ្ឋានជាដើម។ ជាន់ទី៥ ចំកណ្តាលមានសាលប្រជុំអន្តរក្រសួង។ ជាន់ទី៥ ស្លាបខាងស្តាំនិងខាងឆ្វេង ជាន់ទី៦ និងជាន់ទី៧ ជាការិយាល័យសម្រាប់ជួលឱ្យវិស័យឯកជន។

ការសាងសង់អគារទីស្តីការនេះបានប្រើប្រាស់រយៈពេល ១ឆ្នាំ ១ខែ ២០ថ្ងៃ សិក្សាគម្រោងប្លង់ និងរចនាដោយកូនខ្មែរ និងចំណាយថវិការបស់រាជរដ្ឋាភិបាលចំនួន ២៨ ៦៦៥ ១៣៦ ដុល្លារសហរដ្ឋអាមេរិក៕

# កម្ពុជានឹងទទួលបានវត្ថុបុរាណរបស់ខ្លួនចំនួនបួនរូបវិញពីសារមន្ទីរសិល្បៈ Denverឆាប់ៗនេះ

*អត្ថបទ៖ អមរិន្ទ ដានុត*

វត្ថុបុរាណខ្មែរចំនួនបួនរូប ពីសារមន្ទីរសិល្បៈ Denverនៃសហរដ្ឋអាមេរិក នឹងត្រូវប្រគល់មកកម្ពុជាវិញនាពេលខាងមុខនេះ បន្ទាប់ពីមានការអនុលោមតាមអនុស្សរណៈនៃការយោគយល់គ្នារវាងរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលសហរដ្ឋអាមេរិក។

ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ បានចេញសេចក្តីជូនព័ត៌មាននៅថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០២១ថា រដ្ឋាភិបាលសហរដ្ឋអាមេរិកតាមរយៈការិយាល័យរដ្ឋអាជ្ញាសហរដ្ឋអាមេរិកប្រចាំសង្កាត់ភាគខាងត្បូងនៃទីក្រុងញូវយ៉ក (USAO-SDNY) និងការិយាល័យស៊ើបអង្កេតសន្តិសុខមាតុភូមិសហរដ្ឋអាមេរិក (HSI) បានដំណើរការក្តីក្នុងតុលាការពាក់ព័ន្ធនឹងសម្បត្តិវប្បធម៌ខ្មែរចំនួន៤រូប ដែលត្រូវបានរឹបអូសពីសារមន្ទីរសិល្បៈ Denver នៅសហរដ្ឋអាមេរិក។

វត្ថុបុរាណខ្មែរទាំង៤នេះរួមមាន ចម្លាក់ព្រះនាងប្រាជ្ញាបារមិតា ថ្មភក់ សម័យអង្គរ រចនាបថបាយ័ន្តចុងសតវត្សរ៍ទី១២-ដើមទី១៣។ យោងតាមព័ត៌មានពីសាក្សី បដិមានេះត្រូវបានគេរកឃើញនៅក្នុងវាលស្រែក្បែរប្រាសាទបុរាណមួយក្នុងខេត្តតាកែវ មិនឆ្ងាយពីតំបន់ទន្លេបាទី។

ក្រសួងបានឱ្យដឹងថា រូបចម្លាក់ទី២គឺចម្លាក់ព្រះសូរ្យ ថ្មភក់ សម័យមុនអង្គរ សតវត្សរ៍ទី៧-៨ ។ តាមសេចក្តីរាយការណ៍ពីសាក្សី បដិមានេះត្រូវបានលួចចេញពីប្រាសាទមួយនៅលើភ្នំគូលែន។ ចំណែករូបចម្លាក់ទី៣ ជាជួងសំរឹទ្ធសម័យបុរេប្រវត្តិ។ តាមសេចក្តីរាយការណ៍ពីសាក្សី ជួងនេះគឺជាវត្ថុមួយក្នុងចំណោមជួងសំរឹទ្ធចំនួន១២ (រៀបជារង្វង់មូលព័ទ្ធជុំវិញថ្មគោលមួយ) ដែលត្រូវបានរកឃើញនៅតំបន់មួយនៃខេត្តពោធិ៍សាត់-បាត់ដំបង។

រីឯរូបចម្លាក់ទី៤ គឺផ្តែរព្រះនារាយណ៍ធំ ថ្មភក់ សម័យមុនអង្គរ សតវត្សរ៍ទី៧-៨ ។ តាមប្រភពពីសាក្សីបានឲ្យដឹងថា ផ្តែរនេះត្រូវបានយកចេញពីប្រាសាទមួយនៅលើភ្នំគូលែន ដែលមានលក្ខណៈស្រដៀងនឹងផ្តែរនៅប្រាសាទសំបូរព្រៃគុកក្នុងខេត្តកំពង់ធំដែរ។

លោកស្រី ភឿង សកុណា រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ មានប្រសាសន៍ថា ៖ «យើងទាំងអស់គ្នាមានសេចក្តីរំភើបរីករាយ ក្នុងការបន្តស្វាគមន៍រតនៈសម្បត្តិដ៏មានតម្លៃទាំងនេះត្រឡប់មកកម្ពុជា វិញ ហើយមានមោទនភាពចំពោះកិច្ចសហការរបស់យើងជាមួយរដ្ឋាភិបាលសហរដ្ឋអាមេរិក»។

លោកស្រីបានបន្តថា លទ្ធផលដែលទទួលបានជាបន្តបន្ទាប់នេះ ក៏ដោយសារកម្ពុជាមានសុខសន្តិភាពពេញលេញ តាមរយៈនយោបាយ។ ឈ្នះរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដោយផ្តល់ ឱកាសដល់ការវិលត្រឡប់មកវិញនៃព្រលឹងបុព្វបុរសខ្មែរ ដែលបានរសាត់ចាកឆ្ងាយពីមាតុភូមិកំណើតអស់ជា ច្រើនឆ្នាំមកហើយនាសម័យសង្គ្រាម៕





# ដើមឈើអាស៊ី-អឺរ៉ុប៥៣ដើមត្រូវបានយុវជនកម្ពុជាដាំនៅមុខរមណីដ្ឋានប្រាសាទអង្គរវត្ត

*អត្ថបទ៖ អរិយបុត្រ*









ខណៈពេលដែលកម្ពុជាកំពុងតែធ្វើជាម្ចាស់ផ្ទះនៃកិច្ចប្រជុំកំពូលអាស៊ី-អឺរ៉ុបលើកទី១៣ តាមប្រព័ន្ធអនឡាញ ក្រុមយុវជនកម្ពុជាមួយក្រុម បាននាំគ្នាដាំដើមឈើអាស៊ី-អឺរ៉ុបចំនួនសរុប ៥៣ ដើម នៅមុខរមណីដ្ឋានប្រាសាទអង្គរវត្តនៅថ្ងៃដំបូងនៃពិធីបុណ្យអុំទូក បណ្តែតប្រទីប និង សំពះព្រះខែ ។

នាថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២១ លោក សុខ សូកេន រដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងជាប្រធានក្រុមការងារអន្តរក្រសួង-ស្ថាប័នរៀបចំកិច្ចប្រជុំកំពូលថ្នាក់ដឹកនាំវ័យក្មេងនៃមូលនិធិអាស៊ី-អឺរ៉ុបលើកទី៤ បានចូលរួមកម្មវិធីដាំដើមឈើសាមគ្គីយុវជនអាស៊ី-អឺរ៉ុប នៅលើទឹកដីអង្គរ ខេត្តសៀមរាប ដោយមានការអញ្ជើញចូលរួមពីសំណាក់ថ្នាក់ដឹកនាំវ័យក្មេងកម្ពុជា ដូចជា លោក ហ៊ុន ម៉ានី ប្រធានក្រុមប្រឹក្សាយុវជនអាស៊ី និងប្រធានសហភាពសហព័ន្ធយុវជនកម្ពុជា, លោក សាយ សំអាល់ រដ្ឋមន្ត្រីនៃក្រសួងបរិស្ថាន លោក ទៀ សីហា អភិបាលខេត្តសៀមរាប អង្គទូតបណ្តាប្រទេសដៃគូអាស៊ី-អឺរ៉ុប និងយុវជនប្រមាណ២០០ រូប។

កម្មវិធីនេះ ជាផ្នែកមួយនៃកិច្ចប្រជុំកំពូលថ្នាក់ដឹកនាំវ័យក្មេងនៃមូលនិធិអាស៊ី-អឺរ៉ុបលើកទី៤ (ASEFYLS4) ដែលជាព្រឹត្តិការណ៍អមកិច្ចប្រជុំកំពូលអាស៊ី-អឺរ៉ុបលើកទី១៣ដែលកម្ពុជាជាម្ចាស់ផ្ទះ និងសហការរៀបចំដោយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងមូលនិធិអាស៊ី-អឺរ៉ុប ក្នុងគោលបំណងបង្កើនចំណងសាមគ្គីភាព តាមរយៈការដាំដើមឈើចំនួន៥៣ដើម តំណាងឱ្យបណ្តាប្រទេសអាស៊ី-អឺរ៉ុប ៥១ប្រទេស និង០២ស្ថាប័ន ក៏ដូចជាលើកកម្ពស់ការចូលរួមរបស់ យុវជនក្នុងការអនុវត្តគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ទី១៣ របស់អង្គការសហប្រជាជាតិស្តីពីសកម្មភាពភាពអាកាសធាតុ។

នាឱកាសនោះ លោក ហ៊ុន ម៉ានី បានមានប្រសាសន៍ថា ពិធីដាំដើម ឈើសាមគ្គីភាពរវាងយុវជនអាស៊ី-អឺរ៉ុប គឺជាគំនិតផ្តួចផ្តើមរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្នុងនាមជាស្ថាប័ន ដឹកនាំក្រុមការងារអន្តរក្រសួងស្ថាប័ន សហការជាមួយនឹងមូលនិធិអាស៊ី-អឺរ៉ុប និងចូលរួមគាំទ្រពី ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងពាណិជ្ជកម្ម ក្រសួងទេសចរណ៍ ក្រសួងបរិស្ថាន អាជ្ញាធរជាតិអប្សរា និងសហភាពសហព័ន្ធយុវជនកម្ពុជា (ស.ស.យ.ក) ក្នុងគោលបំណង បង្ហាញអំពីសាមគ្គីភាពគ្នារវាងយុវជន និងយុវជន ប្រទេសនិងប្រទេសក្នុងទ្វីបអាស៊ី និងអឺរ៉ុប និងជាការបង្ហាញនូវការយកចិត្តទុកដាក់ ក្នុងនាមយុវជនជាថ្នាក់នាំនៃប្រទេសនីមួយៗ ទៅលើគុណតម្លៃនៃធម្មជាតិ និងបម្រែបម្រួលអាកាសធាតុដែលជាការរួមចំណែកដល់ការអភិវឌ្ឍប្រកបដោយចីរភាព តាមរយៈការដាក់ដាំនូវកូនឈើចម្រុះចំនួន៥៣ដើម នៅមុខប្រាសាទអង្គរវត្តនៃខេត្តសៀមរាប ដែលជារមណីយដ្ឋានវប្បធម៌ប្រវត្តិសាស្ត្រ និងជាបេតិកភណ្ឌពិភពលោក។

លោកបានបញ្ជាក់ថា នេះគឺជាមោទនភាពដែលប្រជាជនកម្ពុជា និងជាពិសេសយុវជននៅទូទាំងតំបន់អាស៊ី និងអឺរ៉ុបអាចចូលរួមជាមួយគំនិតផ្តួចផ្តើមនេះ និងរួមគ្នាទទួលខុសត្រូវជាមួយមហិច្ឆតាក្នុងការសម្រេចឱ្យបាននូវការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព ដែលជាដំណោះ ស្រាយឆ្លើយតបនឹងបញ្ហាបរិស្ថានពិភពលោក។ លោកបានបន្តទៀតថា ខណៈសកលលោកកំពុងតែប្រយុទ្ធប្រឆាំងនឹង ជំងឺកូវីដ-១៩ យើងក៏កំពុងប្រឈមមុខផងដែរនឹងបញ្ហាបម្រែបម្រួលអាកាសធាតុបង្កឱ្យមានការកើនកម្តៅពិភពលោក គ្រោះធម្មជាតិដូចជាទឹកជំនន់ គ្រោះរាំងស្ងួត ខ្យល់ព្យុះជាដើម ដែលទាំងនេះជាបញ្ហាសកលមួយដោយយើងមិនអាចមើលរំលងបានឡើយ។

លោកបានបន្ថែមផងដែរថា៖ «ព្រឹត្តិការណ៍ដាំកូនឈើនាពេលនេះមិនត្រឹមតែឆ្លុះបញ្ចាំង អំពីការគោរពរបស់យើងចំពោះបរិស្ថានធម្មជាតិ និងការយល់ដឹងអំពីបរិស្ថានប៉ុណ្ណោះទេ ប៉ុន្តែវាក៏ជានិមិត្តរូបនៃភាពជឿជាក់លើពហុភាគីនិយម និងការរីកចម្រើនរួមគ្នា ក្រោមការប្តេជ្ញា ចិត្ត យ៉ាងមុតមាំក្នុងការចូលរួមជាមួយយុវជននៅទូទាំងពិភពលោកទាំងក្នុងក្របខ័ណ្ឌក្រុមគ្រួសារនៃសហភាពសហព័ន្ធយុវជនកម្ពុជា និងក្រុមប្រឹក្សាយុវជនអាស៊ី»។ លោកបានបញ្ជាក់បន្តទៀតថា« ខ្ញុំពិតជាមានជំនឿជាក់ថា ដើមឈើដែលយើងរួមគ្នាដាំនៅថ្ងៃនេះនឹងក្លាយជានិមិត្តរូបសាមគ្គីភាព ប្រកបដោយការអត់ធ្មត់ ស្ថេរភាព និងសេចក្តីថ្លៃថ្នូរ ព្រមទាំងអាចផ្សាភ្ជាប់មេដឹកនាំវ័យក្មេងនៃតំបន់ទាំងពីរឱ្យបន្តមានការពិភាក្សាអំពីចក្ខុវិស័យរួមគ្នា ដើម្បីរួមចំណែកដល់ការអភិវឌ្ឍន៍ប្រកបដោយចីរភាពសម្រាប់អនាគតរបស់ប្រជាជាតិក្នុងតំបន់ទាំងពីរ» ។

លោកពិតជាមានជំនឿជាក់ថា ដើមឈើដែលយើងរួមគ្នាដាំនៅថ្ងៃនេះនឹងក្លាយជានិមិត្តរូបសាមគ្គីភាព ប្រកបដោយ ការអត់ធ្មត់ ស្ថិរភាព និងសេចក្តីថ្លៃថ្នូរ ព្រមទាំងអាចផ្សាភ្ជាប់មេដឹកនាំវ័យក្មេងនៃតំបន់ទាំងពីរ ឱ្យបន្តមានការពិភាក្សាអំពីចក្ខុវិស័យរួមគ្នា ដើម្បីរួម ចំណែកដល់ការអភិវឌ្ឍប្រកប ដោយចីរភាព សម្រាប់អនាគតរបស់ប្រជាជាតិក្នុងតំបន់ទាំងពីរ។

គួររំលឹកថា ទោះបីជាកម្ពុជាដំណុះនិងព្រៃធម្មជាតិនៅមាន ប៉ុន្តែដោយសារតែជនឆ្លៀតឱកាសមួយចំនួន ដំណុះព្រៃឈើនិងគម្របព្រៃធម្មជាតិកំពុងតែសឹករិចរិល ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយក៏ពលរដ្ឋកម្ពុជា កំពុងតែត្រូវបានលើកទឹកចិត្តឲ្យចូលរួមនៅក្នុងយុទ្ធនាការនិងចលនាដាំដើមឈើឡើងវិញនៅទូទាំងប្រទេស ។

នៅកម្ពុជាគេដឹងថា មានដំណុះព្រៃធម្មជាតិប្រមាណជា ៨.២៦០ ប្រភេទនៅក្នុងនោះ មានប្រមាណជា ១០ ភាគរយ កំពុងតែស្ថិតនៅក្នុងប្រភេទជារុក្ខជាតិដែលងាយរងគ្រោះ ។ ហើយក្រៅពីនោះ គឺនៅមាន ត្រីប្រមាណជា ៨៧៤ ប្រភេទ បក្សីប្រមាណជា ៥០០ ប្រភេទ និង នៅមានល្មូនប្រមាណជា ២៥០ ប្រភេទ និង ថនិកសត្វជាច្រើនប្រភេទទៀត៕

# កម្ពុជាកំពុងតែលើកកំពស់កម្មវិធីបណ្តុះបណ្តាល អក្ខរកម្មឌីជីថលក្នុងវិស័យទេសចរណ៍

*អត្ថបទ៖ អរិយបុត្រ*

អក្ខរកម្មឌីជីថលត្រូវបានកំពុងតែជំរុញនិងយកចិត្តទុកដាក់ដោយរាជរដ្ឋាភិបាលកម្ពុជា ជាពិសេសនៅក្នុងសម័យកាលនៃការរីករាលដាលនៃមេរោគកូវីដ ១៩ ហើយកាលពីពេលថ្មីៗកន្លងទៅនេះស្ថាប័នបីបានសហការគ្នារៀបចំកម្មវិធីបណ្តុះបណ្តាល មួយដើម្បីលើកកំពស់ជំនាញជូនដល់យុវជននិងយុវនារីដើម្បីឆ្លើយតបនឹងតម្រូវការទីផ្សារ ។

នាព្រឹកថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២១ ក្រសួងទេសចរណ៍ សហភាពសហព័ន្ធយុវជនកម្ពុជា និងមជ្ឈមណ្ឌលកម្ពុជា ៤.០ បានសហការគ្នារៀបចំ «ពិធីប្រកាសដាក់ឱ្យអនុវត្តកម្មវិធីបណ្តុះបណ្តាលអក្ខរកម្មឌីជីថល ក្នុងវិស័យទេសចរណ៍កម្ពុជា អមជាមួយការប្រគល់វិញ្ញាបនបត្រជូនសិក្ខាកាម»

ពិធីនេះធ្វើឡើងក្រោមអធិបតីភាពរបស់លោក ហ៊ុន ម៉ានី ប្រធានសហភាពសហព័ន្ធយុវជនកម្ពុជា និងជាប្រធានក្រុមប្រឹក្សាភិបាលនៃមជ្ឈមណ្ឌលកម្ពុជា ៤.០ និងលោក ថោង ខុន រដ្ឋមន្ត្រីក្រសួងទេសចរណ៍ និងជាប្រធានក្រុមការងាររាជរដ្ឋាភិបាលនិងឯកជន ដើម្បីស្តារនិងលើកស្ទួយវិស័យទេសចរណ៍កម្ពុជា ក្នុងនិងក្រោយវិបត្តិជំងឺកូវីដ-១៩ ដែលបានប្រព្រឹត្តទៅតាមប្រព័ន្ធចម្រុះ ចូលរួមផ្ទាល់ និងអនឡាញដោយមានវត្តមានអ្នកចូលរួមជាតិ និងអន្តរជាតិប្រមាណ ២៧២ នាក់។

កម្មវិធីបណ្តុះបណ្តាលអក្ខរកម្មឌីជីថលក្នុងវិស័យទេសចរណ៍កម្ពុជា ត្រូវបានរៀបចំឡើងក្នុងគោលបំណងឆ្លើយតបនឹងតម្រូវការនៃការប្រើប្រាស់បច្ចេកវិទ្យា នៅក្នុងបរិបទបច្ចុប្បន្ន ព្រមទាំងចូលរួម ស្តារកំណើនទេសចរណ៍ ក្នុងនិងក្រោយវិបត្តិជំងឺកូវីដ-១៩។ វគ្គបណ្តុះបណ្តាលនេះនឹងចូលរួមអភិវឌ្ឍន៍ ចំណេះ និងជំនាញឌីជីថលសម្រាប់បុគ្គលិកឯកជន ម្ចាស់អាជីវកម្មក្នុងវិស័យទេសចរណ៍ ក៏ដូចជាសម្រាប់មន្ត្រីទេសចរណ៍ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

លោក ថោង ខុន បានមានប្រសាសន៍ថា ៖ «អក្ខរកម្មឌីជីថលបានកំពុងដើរតួយ៉ាងសំខាន់ក្នុងការទ្រទ្រង់ដល់ការងើបឡើងវិញនូវវិស័យទេសចរណ៍កម្ពុជាពីវិបត្តិជំងឺកូវីដ-១៩ ព្រមទាំងចូលរួមពង្រឹងនិរន្តរភាព និងឧត្តមភាពប្រកួតប្រជែងនៃវិស័យទេសចរណ៍ជាតិ តាមរយៈការទាញយកសក្តានុពលពីការប្រើប្រាស់បច្ចេកវិទ្យាបំរើដល់ការគ្រប់គ្រង និងការអភិវឌ្ឍ នៅក្នុងពេលបច្ចុប្បន្ន និងទៅអនាគត ស្របតាមបរិបទនៃបដិវត្តន៍ ឧស្សាហកម្ម ៤.០»។

លោករដ្ឋមន្ត្រីរូបនេះបានបន្តថា ជាក់ស្តែងបច្ចេកវិទ្យាកំពុងមានការរីកចម្រើនយ៉ាងឆាប់រហ័ស និងបានជ្រៀតចូលយ៉ាងជ្រៅក្នុងសកម្មភាពសេដ្ឋកិច្ចសង្គម ក៏ដូចជាទំនាក់ទំនងរវាងកោសិកា គ្រប់ផ្នែកគ្រប់វិស័យនៃ ជីវភាពរស់នៅប្រចាំថ្ងៃ ដោយបានជះឥទ្ធិពលយ៉ាងខ្លាំងលើកត្តាផលិតកម្ម ឥរិយាបថនៃការប្រើប្រាស់ និងរចនាសម្ព័ន្ធសេដ្ឋកិច្ចជាតិ រួមទាំងវិស័យទេសចរណ៍ផងដែរ។

ដើម្បីជំរុញយុទ្ធនាការអក្ខរកម្មឌីជីថលក្នុងវិស័យទេសចរណ៍កម្ពុជា ឱ្យសម្រេចបានជោគជ័យប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព លោករដ្ឋមន្ត្រី បានលើកឡើងនូវអនុសាសន៍ ចំនួន ៣ រួមមាន ទី១.បន្តរៀបចំវគ្គបណ្តុះបណ្តាលអក្ខរកម្មឌីជីថលក្នុងវិស័យទេសចរណ៍កម្ពុជា ដោយ ផ្តោតលើអក្ខរកម្មមូលដ្ឋាន និងអក្ខរកម្មជំនាញ ឆ្លើយតបតម្រូវការនាពេលបច្ចុប្បន្ន និងអនាគត ស្រប តាមគន្លងប្រក្រតីភាពថ្មី និងបដិវត្តន៍ឧស្សាហកម្ម ៤.០។

លោកថា ទី២ជំរុញឱ្យមានការទទួលយក និងការប្រើ ប្រាស់ប្រព័ន្ធបច្ចេកវិទ្យា ឱ្យបានទូលំទូលាយនៅក្នុងគ្រប់ខ្សែប្រវាក់តម្លៃនៃវិស័យទេសចរណ៍កម្ពុជា ទាំង ក្នុងផ្នែកតម្រូវការ និងផ្នែកផ្គត់ផ្គង់ និងទី៣ ជំរុញការធ្វើទំនើបនីយកម្មមធ្យោបាយផ្តល់ព័ត៌មានទេសចរណ៍ ទាំងសម្រាប់ទីផ្សារទេសចរណ៍អន្តរជាតិ និងទេសចរណ៍ផ្ទៃក្នុងដោយប្រើប្រាស់ថ្នាលឌីជីថល។

លោក ហ៊ុន ម៉ានី បានចូលរួមមតិយោបល់ចំនួន ៤ ចំណុច ដើម្បីជំរុញ អក្ខរកម្មឌីជីថលនៅកម្ពុជា រួមមាន ទី១.បន្តពង្រឹងការបណ្តុះបណ្តាលផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ចាប់ពីការសិក្សានៅកម្រិតមូលដ្ឋាន មធ្យមសិក្សាទុតិយភូមិ, ទី២.បន្តជំរុញការស្រូបយក និងការសម្របខ្លួន ដោយបំផុសចលនាឱ្យប្រជាពលរដ្ឋគ្រប់រូបដែលជាកោសិកាសង្គម-សេដ្ឋកិច្ច និងជាតួអង្គ ដែលមិនអាចខ្វះបាន ត្រូវស្រូបយក និងសម្របខ្លួនទៅនឹងបច្ចេកវិទ្យាថ្មីៗ ដោយចូលរួមវគ្គបណ្តុះ បណ្តាលអក្ខរកម្ម និងអាចស្វែងរកធនធានបន្ថែមដែលមាននៅលើអ៊ីនធឺណិត។

លោក ហ៊ុន ម៉ានីបានបន្តថា ទី៣.បន្តពង្រឹងកិច្ច សហការរវាងស្ថាប័នរដ្ឋ ជាមួយវិស័យឯកជន និងគ្រឹះស្ថានអប់រំ ទាំងសាលាចំណេះទូទៅ សាលាវិជ្ជាជីវៈ និងសាកលវិទ្យាល័យ ដើម្បីបញ្ចូលការអប់រំផ្នែកបច្ចេកវិទ្យា និងវិទ្យាសាស្ត្រ នៅក្នុងការបណ្តុះបណ្តាល ការតម្រង់ទិស និងការពង្រឹងសមត្ថភាព, ទី៤.បន្តអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធគាំទ្រពិសេសបណ្តាញ ព័ត៌មានវិទ្យា និងទូរគមនាគមន៍ ដើម្បីគាំទ្រដល់នវានុវត្តន៍ និងការពង្រឹងចំណេះ និងជំនាញឌីជីថល នៅកម្ពុជា៕

# ភ្ញៀវទេសចរជាង៩០ ម៉ឺននាក់ បានចេញកម្សាន្តនៅទូទាំងប្រទេសរយៈពេល៣ថ្ងៃនៃព្រះរាជពិធីបុណ្យអុំទូក ឆ្នាំ២០២១

*អត្ថបទ៖ អមរិន្ទ ដានុត*

នាឱកាសថ្ងៃឈប់រយៈពេល៣ថ្ងៃ នៃព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប និងសំពះព្រះខែ អកអំបុក ត្រូវនឹងថ្ងៃទី១៨-២០ ខែវិច្ឆិកា ឆ្នាំ២០២១ ភ្ញៀវទេសចរដែលចេញដើរកម្សាន្តនៅទូទាំងប្រទេសមានចំនួនសរុប៩១០,១៥០នាក់ ក្នុងនោះភ្ញៀវជាតិមានចំនួន៨៩៩,៨៦៩នាក់ និងភ្ញៀវបរទេសផ្ទៃក្នុង១០,២៨១នាក់។ នេះបើតាមការឱ្យដឹងពីលោកថោង ខុន រដ្ឋមន្ត្រីក្រសួងទេសចរណ៍។

លោកថោងខុនបានបង្ហាញការកត់សម្គាល់ថា ចំនួនភ្ញៀវទេសចររយៈពេល៣ថ្ងៃនេះ លើសពីរំពឹងទុកក្នុងនោះឃើញថា តួលេខាងលើមានការកើនឡើង ៥៤.៣៤% ធៀបនឹងព្រះរាជពិធីបុណ្យអុំទូកឆ្នាំ២០២០ ហើយបើធៀបភ្ញៀវពេលឈប់សម្រាកភ្ជុំបិណ្ឌ៣ថ្ងៃ ដូចគ្នា នាដើមខែតុលា ឆ្នាំ២០២១ ថ្មីៗនេះ គឺមានកើនឡើង ៣៦.៩២%។ ទន្ទឹមនឹងនេះ ក្រៅពីគោលដៅទេសចរណ៍ និងរមណីយដ្ឋានសំខាន់ៗ ក៏មានប្រជាពលរដ្ឋជាច្រើនផ្សេងទៀតដើរកម្សាន្តមិនឆ្ងាយពីគេហដ្ឋាន ដូចជាជួបជុំញ៉ាំអាហារជាក្រុមគ្រួសារនៅតាមភោជនីយដ្ឋាន និងកន្លែងដែលមានការៀបចំជាគុស (ដូចជាតាមបណ្តោយមាត់ទន្លេនៅព្រែកលាប បាក់ខែងជាដើម)។

លោកបានបន្តថា ៖ «ចរន្តភ្ញៀវដ៏ច្រើនក្នុងរយៈពេល៣ថ្ងៃនេះ គឺបានមកពីការអនុញ្ញាតរបស់រាជរដ្ឋាភិបាលក្នុងការដំណើរការ និងជំរុញចលនាទេសចរណ៍ផ្ទៃក្នុង ការបើកឡើងវិញនូវគោលដៅដែលមានការរៀបចំបានល្អក្នុងកំឡុងពេលជំងឺកូវីដ-១៩នេះ»។

លោក ថោង ខុន បានបន្ថែមទៀតថា ៖ «ពិសេសគោលដៅសៀមរាប-អង្គរ និងក្រុងព្រះសីហនុដែលបានកំពុងរៀបចំហេដ្ឋារចនាសម្ព័ន្ធ និងសោភ័ណភាពបានស្រស់បំព្រងទាក់ទាញបានមកវិញនូវកំណើនភ្ញៀវទេសចរផ្ទៃក្នុង ស្របពេលដែលរមណីយដ្ឋានទេសចរណ៍ និងគោលដៅទេសចរណ៍ទូទាំងប្រទេស ក៏បានបើកដំណើរការឡើងវិញតាមគន្លងប្រក្រតីភាពថ្មី»។

ម្យ៉ាងវិញទៀត ទោះបីពុំមានការរៀបចំការប្រណាំងទូកថ្នាក់ជាតិ ប៉ុន្តែប្រជាពលរដ្ឋ និងភ្ញៀវទេសចរ បានចេញដើរកម្សាន្តយ៉ាងច្រើនកុះករនៅមុខព្រះបរមរាជវាំង តាមសួនច្បារបណ្តោយទន្លេចតុមុខ តំបន់កោះពេជ្រ វិមានឈ្នះ-ឈ្នះ ស្របពេលដែលបណ្តាខេត្តមួយចំនួនក៏បានរៀបចំការប្រណាំងទូក និងអុំទូកកម្សាន្ត ដូចជានៅខេត្តកណ្តាល ពោធិ៍សាត់ បន្ទាយមានជ័យ និងកំពង់ស្ពឺជាដើម។ ទន្ទឹមនឹងនេះ នៅតាមបណ្តាវត្តអារាម និងរមណីយដ្ឋានមួយចំនួនក៏បានរៀបចំពិធីអកអំបុក សំពះព្រះខែ ដើម្បីរក្សាទំនៀមទម្លាប់ និងទាក់ទាញភ្ញៀវទេសចរ និងប្រជាពលរដ្ឋក្នុងខេត្ត។

ចំពោះឥរិយាបថភ្ញៀវទេសចរក៏មានប្រែប្រួលខ្លះដែរធៀបនឹងពេលកន្លងមក ដោយក្នុងនោះពួកគាត់មួយចំនួនបានងាកមកប្រើប្រាស់សេវារបស់មូលដ្ឋានអាជីវកម្ម ដូចជាការស្នាក់នៅសណ្ឋាគារលំដាប់ផ្កាយ និងសណ្ឋាគារធម្មតា ផ្ទះសំណាក់ ដែលបានធ្វើឲ្យអត្រាកក់បន្ទប់ស្នាក់នៅតាមខេត្តគោលដៅទេសចរណ៍សំខាន់ៗមានកម្រិតខ្ពស់ និងការចូលទទួលទានអាហារដោយផ្ទាល់នៅតាមបណ្តាអាហារដ្ឋាន និងភោជនីយដ្ឋានក៏មានការកើនឡើង ខណៈដែលនាពេលកន្លងមក ពួកគាត់ច្រើនតែត្រៀមសម្ភារៈ និងម្ហូបអាហារដាក់តាមខ្លួនច្រើនជាងចូលទទួលទានផ្ទាល់នៅក្នុងហាង។

លោក ថោង ខុន បានបញ្ជាក់បន្ថែមឱ្យដឹងទៀតថា ៖ «កត្តាទាំងអស់នេះ សបញ្ជាក់ឲ្យឃើញនូវដំណើរត្រលប់ទៅរកប្រក្រតីភាពថ្មី និងធ្វើឲ្យមានចរន្តសេដ្ឋកិច្ចមានដំណើរការឡើងវិញ ពិសេសសម្រាប់មូលដ្ឋានអាជីវកម្ម និងវិស័យឯកជន ដែលបានផ្អាកសកម្មភាពនាពេលកន្លងមក»។

រដ្ឋបាលរាជធានី-ខេត្ត មន្ទីរទេសចរណ៍បានខិតខំក្នុងការជំរុញការអនុវត្តវិធានសុវត្ថិភាពទេសចរណ៍ SOP និងវិធានការ «៣កុំ និង៣ការពារ» ក្នុងការទប់ស្កាត់កូវីដ-១៩ ដោយចាត់ក្រុមការងារជំនាញចុះអប់រំណែនាំផ្ទាល់ដល់គ្រប់មូលដ្ឋានអាជីវកម្ម ខណៈដែលបុគ្គលិកបម្រើការក៏ទទួលបានការចាក់វ៉ាក់សាំងពេញលេញផងដែរ។

លោក ថោង ខុន បានសង្កេតឃើញជារួមថា ៖ «ចំពោះភ្ញៀវទេសចរ ពួកគាត់មានរីករាយ និងហាក់មានអារម្មណ៍ធូរស្រាលក្នុងចិត្តក្នុងការដើរកម្សាន្តបានពេញលេញ ពិសេសក្រោយពេលដែលបានចាក់វ៉ាក់សាំងបានពេញលេញ និងស្ថានភាពទូទៅកំពុងត្រលប់ទៅរកប្រក្រតីភាពថ្មីជាបណ្តើរៗ»។

គណៈបញ្ជាការឯកភាពរាជធានី-ខេត្ត កងកម្លាំងមានសមត្ថកិច្ច ពិតជាបានខិតខំក្នុងការរក្សាសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ និងសម្រួលចរាចរណ៍ ស្របពេលចរន្តភ្ញៀវទេសចរមានភាពផុសផុលនៅគ្រប់រាជធានី-ខេត្ត។

គោលដៅទេសចរណ៍សំខាន់ៗរយៈពេល៣ថ្ងៃនោះ រួមមាន៖ រាជធានីភ្នំពេញ ១៩៩,៨៣៥ នាក់, ខេត្តសៀមរាប ១១៨,១៤៦នាក់, ខេត្តព្រះសីហនុ ១១១,៣២២នាក់, ខេត្តកំពត ៨៣,៤៦៦នាក់, ខេត្តកែប ៧៥,៨៦៥នាក់, ខេត្តពោធិ៍សាត់ ៥៣,៨០៧នាក់, ខេត្តបាត់ដំបង ៣៨,៦៦៧នាក់, ខេត្តកំពង់ស្ពឺ ៣៧,៤៦៥នាក់, ខេត្តមណ្ឌលគិរី ៣២,៩៥៧នាក់, ខេត្តកណ្តាល ២៧,២៨០នាក់ និងខេត្តរតនគិរី ២៤,៥៩៦នាក់៕





# អ្នកជំនាញ៖ អាជីវករតូចតាចកំពុងតែប្រឈមនឹងបញ្ហាជាច្រើន

> យើងគ្មានកន្លែងលក់ត្រឹមត្រូវ ទេ កន្លែងរបស់យើងគឺធ្វើដំណើរត្រាច់ចររកកន្លែងមនុស្ស ហើយជួនកាលទៅទើសផ្លូវគេ គេដេញ តែពេលខ្លះគេក៏អនុគ្រោះ ប៉ុន្តែក៏ឧស្សាហ៍ជួបគ្រោះថ្នាក់ចរាចរណ៍ដែរ

*អត្ថបទ៖ អរិយបុត្រ*

សមាគមប្រជាធិបតេយ្យឯករាជ្យ នៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ បានអះអាងថា បណ្តាអ្នកដែលលក់ដូរតាមដងផ្លូវនានានៅក្នុងប្រទេសកំពុងតែជួបប្រទះបញ្ហាប្រឈម មួយចំនួន ដូចជា គ្មានសុវត្ថិភាព គ្មានអនាម័យ គ្មានកិច្ចគាំពារសង្គម រងការបៀតបៀន និងការរើសអើង គ្រប់រូបភាព ហើយពួកគេពុំទាន់បានទទួលស្គាល់ និងចុះបញ្ជីក្នុងប្រព័ន្ធ របបសន្តិសុខសង្គម នៅឡើយ លើសពីនេះទៅទៀត ការរីករាលដាល នៃជំងឺរាតត្បាតសាកលកូវីដ១៩ បានធ្វើឲ្យពួកគាត់ កាន់តែជួបការលំបាកបន្ថែមទៀត។



បញ្ហាទាំងនេះត្រូវបានលើកឡើងកាលពីថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២១ខណៈដែលសមាគមប្រជាធិបតេយ្យឯករាជ្យ នៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ និងដៃគូពាក់ព័ន្ធ បានរួមគ្នាប្រារព្ធទិវា អ្នកលក់ដូរតាមដងផ្លូវអន្តរជាតិ លើកទី៩ ដើម្បីចែករំលែកពីសារៈសំខាន់ នៃអ្នកលក់ដូរ តាមដងផ្លូវ នៅក្នុងបរិយាបន្នសង្គម និងការរួមមចំណែក របស់ពួកគេ ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។

វេទិកា «កិច្ចគាំពារសង្គម សម្រាប់អ្នកលក់ដូរ តាមផ្លូវនៅកម្ពុជា» នេះត្រូវបានរៀបចំឡើងដើម្បីរំលឹក និងទទួលស្គាល់ សិទ្ធិអ្នកលក់ដូរ តាមដងផ្លូវ ពិភាក្សាអំពីស្ថានភាព និងបញ្ហាជួបប្រទះរបស់ពួកគេ ព្រមទាំងចែករំលែកព័ត៌មាន និងបទពិសោធន៍ ស្តីពីគោលនយោបាយ និងការអនុវត្តកិច្ចគាំពារសង្គម។

អ្នកស្រី ពៅ ច័ន្ទដារី អាយុ ៣០ ឆ្នាំ ធ្លាប់ជាកម្មកររោងចក្រ ហើយបច្ចុប្បន្ន ជាអ្នកលក់ដូរតាមដងផ្លូវមួយរូបបាន ថ្លែងថា ក្នុងនាមជាសមាជិកសមាគមមួយរូប អ្នកស្រី បានចូលរួមប្រជុំ និងវគ្គបណ្តុះបណ្តាល អំពីកិច្ចគាំពារសង្គម និងបានយល់ដឹង កាន់តែច្រើន ពីបញ្ហាជួបប្រទះ របស់អាជីវករ ផ្សេងៗទៀត។

យោងតាមបទពិសោធន៍ ធ្លាប់ធ្វើការនៅរោងចក្រ លោកស្រីអាចមើលឃើញ ពីភាពខុសប្លែកគ្នា និងអត្ថប្រយោជន៍ជាច្រើន ដែលកម្មករក្នុងប្រព័ន្ធ ទទួលបានពីរបបកិច្ចគាំពារសង្គម ដូចជា ការថែទាំសុខភាព គ្រោះថ្នាក់ការងារ ការឈប់សម្រាលកូន ប្រាក់បំណាច់ និងប្រាក់សោធន ជាដើម។ អ្នកស្រី ចង់មើលឃើញអាជីវករ និងកម្មករក្រៅប្រព័ន្ធទាំងអស់ ទទួលបានអត្ថ ប្រយោជន៍ ដូចគ្នាដែរ។

អ្នកស្រី ច័ន្ទដារី បានបញ្ជាក់ថា ៖ «ខ្ញុំពេញចិត្តនឹងចូលរួម បើទោះជា មានការបង់វិភាគទាន ក្នុងកម្រិតណាមួយនោះ សម្រាប់កិច្ចគាំពារសង្គម»។

លោកវន់ ពៅ ប្រធានសមាគមប្រជាធិបតេយ្យឯករាជ្យនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ បានមានប្រសាសន៍ថា ចាប់តាំងពីឆ្នាំ២០០៧ មក សមាគមរបស់លោក បានធ្វើសកម្មភាពជាច្រើន ដើម្បីលើកកម្ពស់លក្ខខណ្ឌការងារទូទៅ រួមទាំងកិច្ចគាំពារសង្គម សម្រាប់អ្នកលក់ដូរតាមដងផ្លូវ ដើម្បីបញ្ចូលពួកគេ ទៅក្នុងគោល នយោបាយគាំពារសង្គម ក៏ដូចជា ការជំរុញច្បាប់ ស្តីពីរបបសន្តិសុខសង្គម ដើម្បីពង្រីក វិសាលភាព ក្នុងការគាំពារពួកគេ ក្នុងច្បាប់នេះផងដែរ។ អ្នកលក់ដូរតាមដងផ្លូវ ក៏ត្រូវការ កិច្ចគាំពារសង្គមពីច្បាប់នេះ ដើម្បីកម្ពុជាឈានទៅរកសង្គមមួយប្រកបដោយសមភាព និងសមធម៌។

លោកបានបន្ថែមថា បច្ចុប្បន្ន សមាគមបាននិងកំពុងសម្របសម្រួល បណ្តុះបណ្តាល និងចងក្រងអ្នកលក់ដូរ តាមដងផ្លូវ ក្នុងរាជធានីភ្នំពេញ និងបណ្តាខេត្តនានា បានចំនួន ២២ ក្រុម ដើម្បីផ្តួចផ្តើមឱ្យមានការសន្ទនា សមស្របជាមួយស្ថាប័នរាជរដ្ឋាភិបាលពាក់ព័ន្ធ មួយចំនួន ដើម្បីទទួលបានការទទួលស្គាល់ កាន់តែច្រើន ពីសិទ្ធិរបស់ពួកគេ ដើម្បីផ្តល់លទ្ធ ភាព ដល់ពួកគេអាចទទួលបានកិច្ចគាំពារសង្គម និងលក្ខខណ្ឌរស់នៅសមរម្យ។

លោកស្រីភាណ សោភ័ណ នាយិកាអង្គការអុកស្វាម បានមានប្រសាសន៍ថា អ្នកលក់ដូរ តាមផ្លូវចូលរួមយ៉ាងសកម្ម ក្នុងការលើកកម្ពស់ សេដ្ឋកិច្ចគ្រួសារ និងសេដ្ឋកិច្ចជាតិ។ ពួកគាត់ មានសិទ្ធិដូចកម្មករ ក្នុងវិស័យដទៃទៀតដែរ។ ការទទួលបាននូវរបបកិច្ចគាំពារសង្គម និង សុខមាលភាពដែលរួមបញ្ចូល ទាំងការធានាសុខភាព ការថែទាំកុមារ កិច្ចគាំពារមាតុភាព ការអប់រំ ការមានអនាម័យ និងសុវត្ថិភាព នៅកន្លែងលក់ដូរ និងការទទួលបាន សេវាហិរញ្ញវត្ថុ គឺជារឿងសំខាន់ខ្លាំងណាស់ ហើយដែលពួកគាត់ គួរទទួលបានដូចកម្មករដទៃទៀតដែរ ជាពិសេស នៅក្នុងបរិបទកូវីដ-១៩ នេះ។

លោកស្រី បានបន្ថែមថា ៖ «អង្គការអុកស្វាមយល់ឃើញថា ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់អ្នកលក់ដូរតាមផ្លូវ ឲ្យមានប្រសិទ្ធភាពជាការចាំបាច់ដែល ទាមទារបន្តឲ្យមានការគាំទ្រ ផ្តល់កិច្ចគាំពារសង្គម និងមានការសិក្សាស្រាវជ្រាវ ច្បាស់លាស់ អំពីតម្រូវការ និងស្ថានភាព ជាក់លាក់របស់ពួកគាត់ ដើម្បីអភិវឌ្ឍន៍ទៅជា គោលនយោបាយ ដែលឆ្លុះបញ្ចាំង និងឆ្លើយតបនឹងតម្រូវការ ជាក់ស្តែងរបស់ អ្នកលក់ដូរតាមផ្លូវ»។

លោក ទី សុផាត អ្នកលក់មីឆាតាមម៉ូតូកង់បីថ្មែបានឲ្យដឹងថា ជាទូទៅរបរនេះប្រឈមមុខនឹងបញ្ហាច្រើន ប៉ុន្តែក៏អាចនឹងចិញ្ចឹមជីវិតនិងគ្រួសារបានដែរ គ្រាន់តែវាលំបាកបន្តិចប៉ុណ្ណោះ ។

លោកបានបន្តថា ៖ «យើងគ្មានកន្លែងលក់ត្រឹមត្រូវ ទេ កន្លែងរបស់យើងគឺធ្វើដំណើរត្រាច់ចររកកន្លែងមនុស្ស ហើយជួនកាលទៅទើសផ្លូវគេ គេដេញ តែពេលខ្លះគេក៏អនុគ្រោះ ប៉ុន្តែក៏ឧស្សាហ៍ជួបគ្រោះថ្នាក់ចរាចរណ៍ដែរ»។

លោកបានឲ្យដឹងថា លោកចង់បានកន្លែងលក់ត្រឹមត្រូវដូចគេដូចឯងដែរ ប៉ុន្តែវាពិបាកត្រង់ថាកន្លែងវាថ្លៃ នៅមិនទាន់មានទុនក៏ចេះតែតស៊ូក្រោមកំដៅថ្ងៃ ភ្លៀង ផ្គរទៅ៕

# ស្ថានប័នក្រៅរដ្ឋាភិបាលជាង៨០ ស្នើសុំឱ្យ ដោះលែងនិងទម្លាក់ចោលបទចោទ

## ដល់តំណាងសហគមន៍ដីធ្លី សកម្មជនការពារព្រៃឈើ ធនធានធម្មជាតិ

*អត្ថបទ៖ អមរិន្ទ ដានុត*



ក្រុមអង្គការសង្គមស៊ីវិល សមាគម បណ្តាញសម្ព័ន្ធ សហជីព សហគមន៍មូល ដ្ឋានទាំងជនជាតិដើមភាគតិច និងមែនភាគតិចជាង៨០ស្ថាប័ន បានចេញសេចក្តីថ្លែងការណ៍រួមមួយដោយស្នើឱ្យរដ្ឋាភិបាលទម្លាក់ចោលរាល់ការចោទប្រកាន់ និងដោះលែង តំណាងសហគមន៍ដីធ្លី សកម្មជនការពារព្រៃឈើ ធនធានធម្មជាតិទាំងអស់។

សេចក្តីថ្លែងការណ៍រួមដែលបានចេញនៅថ្ងៃទី១៥ ខែវិច្ឆិកានេះ បានបង្ហាញពីការសោកស្តាយ និងព្រួយបារម្ភយ៉ាងខ្លាំង ចំពោះការចោទប្រកាន់ ការចាប់ និងឃុំខ្លួនតំណាងសហគមន៍ដីធ្លី សកម្មជនការពារព្រៃឈើ និងធនធានធម្មជាតិ នាពេលថ្មីៗកន្លងមកនេះ និងទទូចស្នើសុំឱ្យទម្លាក់រាល់ការរាល់ចោទប្រកាន់ចោទប្រកាន់ទាំងឡាយនិងដោះលែងពួកគេទាំងនោះឱ្យមានសេរីភាពវិញដោយឥតលក្ខខណ្ឌ។

ក្រុមសង្គមស៊ីវិលទាំងនេះបានបញ្ជាក់ថា៖ «ក្នុងរយៈកាលកន្លងមកនេះ មានតំណាងសហគមន៍ដីធ្លី សកម្មជនការពារព្រៃឈើ និងការពារធនធានធម្មជាតិ ជាច្រើននាក់ត្រូវបានរងការចោទប្រកាន់ និងចាប់ឃុំខ្លួន យ៉ាងអយុត្តិធម៌ ដោយពួកគាត់គ្រាន់តែប្រើប្រាស់សិទ្ធិសេរីភាពស្របច្បាប់ក្នុងការការពារដីធ្លី ព្រៃឈើ និងធនធានធម្មជាតិ ដោយសន្តិវិធី»។

សកម្មជនទាំងនោះមាន លោក ឆន ផល្លា ជាសកម្មជនការពារព្រៃឈើដ៏ឆ្នើមម្នាក់ប្រចាំខេត្តរតនគិរី ដែលបានធ្វើ សកម្មភាពយ៉ាងសកម្មក្នុងការពារព្រៃឈើ ដីធ្លី របស់សហគមន៍ជនជាតិដើមភាគតិច នៅឃុំសេដា ស្រុក លំផាត់ ខេត្តរតនៈគិរី ត្រូវបានសមត្ថកិច្ចចាប់ខ្លួនកាលពីថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២១ តាមដីការបង្គាប់ឲ្យចាប់ខ្លួនលេខ០៤/២០២១ ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០២១ នៅពេលរូបលោកទៅពិនិត្យឯកសារបោះឆ្នោត នៅប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំសេដា ស្រុកលំផាត់ ខេត្តរតនគិរី ។

លោកត្រូវបានបញ្ជូនមកឃុំខ្លួនបណ្តោះអាសន្នក្នុងពន្ធនាគារខេត្តរតនគិរី ដោយចោទប្រកាន់ពីបទកាប់គាស់ រុករានដីព្រៃ ឆ្កាដុត ឈូសឆាយ ដើម្បីយកដីព្រៃមកធ្វើជាកម្មសិទ្ធិ តាមប្បញ្ញត្តិមាត្រា៦២ ចំណុច១ ច្បាប់ស្តីពីតំបន់ការពារធម្មជាតិ។ ការ ចោទប្រកាន់នេះ ធ្វើឲ្យមានការប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ការលះបង់កម្លាំងកាយ កម្លាំងចិត្តរបស់លោក និងជាការបំបាក់ស្មារតី ដោយលោកតែងតែចេញមុខយ៉ាងសកម្ម ក្នុងការចូលរួមការពារព្រៃឈើ ដីសហ គមន៍ជនជាតិដើមភាគតិច និងការពារធនធានធម្មជាតិ នៅក្នុងសហគមន៍ឃុំសេដា ស្រុកលំផាត់ ខេត្តរត នៈគិរី ដើម្បីរក្សាទុកសម្រាប់អ្នកជំនាន់ក្រោយ ។

នៅថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២១ សាលាដំបូងខេត្តរតគិរីបានលើកយកសំណុំរឿង របស់លោក ឆន ផល្លា មកធ្វើការជំនុំជម្រះជាសាធារណៈ និងប្រកាសសាលក្រម នៅព្រឹកថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២១ ដោយសម្រេចឲ្យរូបលោកត្រូវផ្តន្ទាទោសជាប់ពន្ធនាគាររយៈពេល៥ឆ្នាំ ដោយមិនមានពិន័យជាប្រាក់ តាម មាត្រា៩៧ ចំណុច៦ ច្បាប់ស្តីពីព្រៃឈើ។

ចំណែកករណីលោក ផុន សុផល តំណាងសហគមន៍ដីធ្លីឃុំជាំក្រវៀន ស្រុកមេម៉ត ខេត្តត្បូងឃ្មុំត្រូវ បានសមត្ថកិច្ចចាប់ខ្លួនរូបលោក នៅចំនុចប្រកចូលក្រុមហ៊ុន ឃីជេ ស្ថិតនៅឃុំរាម ស្រុកព្រៃនប់ ខេត្តព្រះ សីហនុ កាលពីព្រឹកថ្ងៃ

> ក្នុងរយៈកាលកន្លងមកនេះ មានតំណាងសហគមន៍ដីធ្លី សកម្មជនការពារព្រៃឈើ និងការពារធនធានធម្មជាតិ ជាច្រើននាក់ត្រូវបានរងការចោទប្រកាន់ និងចាប់ឃុំខ្លួន យ៉ាងអយុត្តិធម៌ ដោយពួកគាត់គ្រាន់តែប្រើប្រាស់សិទ្ធិសេរីភាពស្របច្បាប់ក្នុងការការពារដីធ្លី ព្រៃឈើ និងធនធានធម្មជាតិ ដោយសន្តិវិធី

ពុធ ទី៣០ ខែធ្នូ ឆ្នាំ២០២០ បន្ទាប់ពីរូបលោកត្រលប់ពីចូលរួមកិច្ចប្រជុំឆ្លុះបញ្ចាំង សកម្មភាពការងារប្រចាំឆ្នាំ២០២០ ជាមួយសមាគមសម្ព័ន្ធកសិករកម្ពុជា ដែលធ្វើឡើងនៅសហគមន៍ថ្មធំ ព្រៃកត្របែក ភូមិអណ្តូងត្របែក ឃុំរាម ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ។ ការចាប់ខ្លួននេះធ្វើឡើងតាមរយៈ ដីកាបង្គាប់ឲ្យចាប់ខ្លួនលេខ០៣ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២០ ដោយចោទប្រកាន់ពីបទសមគំនិតក្នុងអំពើ ញុះញង់ឲ្យប្រព្រឹត្ត អំពើបង្កឲ្យមានភាពវឹកវរធ្ងន់ធ្ងរដល់សន្តិសុខសង្គម តាមប្បញ្ញត្តិមាត្រា៤៩៤ មាត្រា ៤៩៥ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រព្រឹត្តតាមបណ្តាញសង្គមហ្វេសប៊ុក ក្នុងភូមិសាស្ត្រខេត្តត្បូងឃ្មុំ កាលពីថ្ងៃទី២២ ខែសីហា ដល់ថ្ងៃទី២២ ខែតុលា ឆ្នាំ២០២។ លោកត្រូវបាននាំខ្លួនពី ខេត្តព្រះសីហនុ មកឃុំខ្លួនបណ្តោះអាសន្នក្នុងពន្ធនាគារខេត្តត្បូងឃ្មុំ កាលពីរសៀលថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០២០ ដោយមិនបានផ្តល់ព័ត៌មានដល់ក្រុមគ្រួសាររបស់គាត់ ឱ្យស្របទៅតាមនីតិវិធីឡើយ ក្រោយមក ទើបក្រុមគ្រួសារបានដឹងព័ត៌មានតាមរយៈ មន្ត្រីពន្ធនាគារដែលបានទាក់ទងទៅពួកគាត់ ។

សំណុំរឿងរបស់លោក ផុន សុផល ត្រូវបានសាលាដំបូងខេត្តត្បូងឃ្មុំ បើកសវនាការជាសាធារណៈកាលពីថ្ងៃទី១៩ ខែមករា ឆ្នាំ២០២១ ដោយសម្រេចផ្តន្ទាទោសដាក់ពន្ធនាគាររយៈពេល១(មួយ) ឆ្នាំ និងពិន័យជាប្រាក់ចំនួន២លានរៀល។ ដោយ

















មិនសុខចិត្តនិងសេចក្តីសម្រេចរបស់សាលាដំបូងខេត្ត ត្បូងឃ្មុំ ទើបរូបលោកប្រគល់ជូនមេធាវីក្នុងការធ្វើបណ្តឹងឧទ្ធរណ៍មកសាលាឧទ្ធរណ៍ខេត្តត្បូងឃ្មុំបន្ត ហើយ នៅថ្ងៃទី១១ ខែតុលា ឆ្នាំ២០២១ ត្រូវបានសាលាឧទ្ធរណ៍លើកយកសំណុំរឿងនេះមកបកសវនាកាជាសា ធារណៈនិងបានប្រកាសសាលដីកានៅព្រឹកថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២១ ដោយសម្រេចតម្កល់សាលក្រមសាលាដំបូងខេត្តត្បូងឃ្មុំ ទុកនៅដដែល ។ លោក ផុនសុផល ជាតំណាងសហគមន៍ដីធ្លីជាំក្រវៀន ខេត្ត ត្បូងឃ្មុំ តែងតែធ្វើសកម្មភាព ក្នុងការជួយជ្រោមជ្រែងការពារសិទ្ធិដីធ្លីជូនប្រជាពលរដ្ឋក្នុងសហគមន៍ និង តែងតែឈឺឆ្អាលចូលរួមតស៊ូមតិដោយអហិង្សា ពីបញ្ហាអយុត្តិធម៌សង្គម និងព្រឹត្តិការណ៍សង្គមនានា ស្រប តាមច្បាប់សិទ្ធិមនុស្សជាតិ និងអន្តរជាតិ ។

សំណុំរឿងរបស់លោក ចាន់ ធឿន ត្រូវបានចោទប្រកាន់ពីបទប៉ុនប៉ងមនុស្សឃាត ពីជនល្មើសកាប់ឈើ ប៉ាក យ៉ាងគួ គឺជាកូនមេបញ្ជាការវងកងរាជអាវុធហត្ថខេត្តកំពង់ធំ និងជាឈ្មួញរកស៊ីឈើដុះស្លែ នៅក្នុងតំបន់ព្រៃឡង់ បានដាក់ពាក្យបណ្តឹងលើសមាជិកសកម្មរបស់បណ្តាញសហគមន៍ព្រៃឡង់។ដោយ មិនសុខចិត្តនិងសេចក្តីសម្រេច របស់សាលាដំបូងខេត្តកំពង់ធំ ទើបរូបលោកប្រគល់ជូនមេធាវីក្នុងការធ្វើប ណ្តឹងឧទ្ធរណ៍មកសាលាឧទ្ធរណ៍ខេត្តកំពង់ធំបន្តទៀត។ លោក ចាន់ ធឿន ជាសមាជិកសកម្មរប ស់ បណ្តាញសហគមន៍ព្រៃឡង់ ខេត្តកំពង់ធំ គាត់បានចូលរួមសកម្មភាពការពារព្រៃឈើ ជាពិសេសការឃ្លាំ មើលស្ថានភាពព្រៃឈើក្នុងតំបន់ព្រៃឡង់ និងសហគមន៍ព្រៃឈើ។

សំណុំរឿងរបស់លោក ខេម សុឃី និងលោក សូ ថាល់ ជាសមាជិកបណ្តាញសហគមន៍ព្រៃ ឡង់ ខេត្តព្រះវិហារ ត្រូវបានសាលាដំបូងខេត្តព្រះវិហារ បើកសវនាការជាសាធារណៈ ដោយសម្រេចផ្តន្ទាទោស ដាក់ពន្ធនាគាររយៈពេល ៦ខែ(ប្រាំមួយ) ខែ និងពិន័យជាប្រាក់ចំនួន ៤លានរៀល។ ដោយ មិនសុខ ចិត្តនិងសេចក្តីសម្រេច របស់សាលាដំបូងខេត្តព្រះវិហារ ទើបរូបលោកប្រគល់ជូនមេធាវីក្នុងការធ្វើបណ្តឹង មកសាលាឧទ្ធរណ៍ខេត្តត្បូងឃ្មុំបន្ត ទើបត្រូវបានសាលាឧទ្ធរណ៍លើកយកសំណុំរឿងនេះមកសវនាកាជា សាធារណៈ និងបានប្រកាសសាលដីកាដោយសម្រេចតម្កល់សាលក្រមសាលាដំបូងខេត្តព្រះវិហារទុក នៅដដែល និងបន្តប្តឹងទៅតុលាការកំពូលបន្តទៀត។ លោក ខេម សុឃី និងលោក សូ ថាល់ គឺជាសមាជិក សកម្មរបស់បណ្តាញសហគន៍ព្រៃឡង់ខេត្តព្រះវិហារ បានចូលរួមការពារធនធានធម្មជាតិ និងព្រៃឈើ នៅ តំបន់ព្រៃឡង់។

ជាមួយគ្នានេះដែរ ក្រុមអង្គការសង្គមស៊ីវិលទាំងអស់នេះ ក៏បានស្នើឱ្យមានទម្លាក់ការចោទផងដែរដល់ក្រុមយុវជនសកម្មក្នុងការចូលរួមការពារបរិស្ថាន ដែលត្រូវបានដោះលែង នាពេលថ្មីៗកន្លងមកនេះ រួមមានលោក ថុន រដ្ឋា កញ្ញា ឡុង គន្ធា កញ្ញា ភួន កែវរស្មី លោក លី ច័ន្ទតារាវុធ លោក យឹម លាងហ៊ី កញ្ញា ស៊ុន រដ្ឋា ដែលត្រូវបានដាក់ឲ្យស្ថិតក្រោមការត្រួតពិនិត្យ ដោយមិនទាន់មានការទម្លាក់ចោលរាល់ការចោទប្រកាន់នៅឡើយ។

សេចក្តីថ្លែងការណ៍បានបញ្ជាក់ថា ៖ «យើងខ្ញុំទាំងអស់គ្នាជាអង្គការសង្គមស៊ីវិល សមាគម បណ្តាញសម្ព័ន្ធ សហជីព សហគមន៍ សង្កេតឃើញថា មានការធ្វើទុក្ខបុកម្នេញពីសំណាក់អាជ្ញាធរ ការចោទប្រកាន់ពីស្ថាប័នតុលាការ ការចាប់ខ្លួនសកម្មជនដីធ្លី បរិស្ថាន អ្នកការពារធនធានធម្មជាតិ ជាច្រើននាក់ ដោយភាគច្រើនពួកគេត្រូវរងការ ចោទប្រកាន់ពីបទញុះញង់ឲ្យប្រព្រឹត្តបទឧក្រិដ្ឋជាអាទិ៍ញុះញង់ឲ្យមានភាពវឹកវរធ្ងន់ធ្ងរដល់សន្តិសុខ សង្គម និងបទល្មើសផ្សេងៗទៀតដែលមានលក្ខណៈនយោបាយ ដើម្បីបំបិទសំឡេងរិះគន់របស់អ្នកទាំងនោះ»។

ប្រភពដដែលបានបន្តថា ចំពោះការចាប់សកម្មជនសកម្មទាំងអស់ខាងលើនេះ គឺជាការគម្រាមកំហែង បំភិត បំភ័យ និងធ្វើទុក្ខបុកម្នេញដោយផ្ទាល់ និងប្រយោល ចំពោះសកម្មជនបម្រើកិច្ចការសង្គមទូទាំងប្រទេស ដែលតែងតែជួយការពារសិទ្ធិពលរដ្ឋក្នុងសហគមន៍ ការពារព្រៃឈើ និងធនធានធម្មជាតិ យ៉ាងសកម្ម ។

ជាការឆ្លើយតបនឹងការស្នើសុំនេះ អ្នកនាំពាក្យក្រសួងយុត្តិធម៌ លោក ជិន ម៉ាលីន បានបញ្ជាក់ថា ក្នុងប្រទេសប្រជាធិបតេយ្យមិនដែលមានការស្នើសុំទម្លាក់ចោលបទចោទប្រកាន់អ្នកដែលប្រព្រឹត្តខុសនោះទេឡើយ។

លោកថា ៖ «ការទាមទារនេះចម្លែក ខុសពីក្នុងសង្គមប្រជាធិបតេយ្យ ដែលវាមិនដែលមានការស្នើសុំឱ្យតុលាការដោះលែង និងទម្លាក់បទចោទអ្នកដែលប្រព្រឹត្តបទល្មើសនោះទេ។ មធ្យោបាយការពារខ្លួនគឺមានតែការចូលរួមក្នុងដំណើរការតាមនីតិវិធីតុលាការ»។

ក្រុមអង្គការសង្គមស៊ីវិល សមាគម បណ្តាញសម្ព័ន្ធ សហជីព សហគមន៍មូលដ្ឋាន រួមមាន៖ អង្គការកម្មវិធីអភិវឌ្ឍន៍ធនធានយុវជន(YRDP), មជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្ស (CENTRAL), សហព័ន្ធសហជីពកម្មករនិយោជិតវិស័យទេសចរណ៍កម្ពុជា CTWUF, សមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា អាដហុក (ADHOC), សមាគមសម្ព័ន្ធសហគមន៍កសិករកម្ពុជា (CCFC), សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្សលីកាដូ (LICADHO), អង្គការសម្ព័ន្ធភាពការពារសិទ្ធិមនុស្សកម្ពុជា (CHRAC), អង្គការគាំទ្របច្ចេកវិទ្យាជនបទក្នុងប្រទេសកម្ពុជា, មជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីអភិវឌ្ឍន៍សង្គម (PDP CENTER), យុវកសិករដើម្បីសកម្មភាពសង្គម (YPS), សម្ព័ន្ធភាពប្រជាជនដើម្បីអធិបតេយ្យភាពស្បៀងនៅអាស៊ី (PCFS-ASIA), មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (CCHR), សមាគមប្រជាធិបតេយ្យឯករាជ្យនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ (IDEA), អង្គការវិទ្យាស្ថានប្រជាធិបតេយ្យកម្ពុជា (CID), គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (COMFREL), សហជីពទ្រទ្រង់សិទ្ធិការងារបុគ្គលិកកម្មករខ្មែរនៃក្រុមហ៊ុនណាហ្គាវើលដ៏ (LRSU), សហព័ន្ធសហជីពកម្ពុជា (CATU), សមាគមបណ្តាញយុវជនកម្ពុជា (CYN), អង្គការសមាគមជាងត្នោត (Sahmakum Teang Tnaut- STT)៕

# «ថ្ងៃអាទិត្យ ថ្ងៃអំណាន» ដើម្បីលើកទឹកចិត្តឪពុកម្តាយចំណាយពេលអានសៀវភៅជាមួយកូនៗ

*អត្ថបទ៖ ផល សុផានិត*

«ថ្ងៃអាទិត្យ ថ្ងៃអំណាន» ជាយុទ្ធនាការថ្មីមួយរបស់ក្រសួងអប់រំ យុវជន និងកីឡា សហការជាមួយ ទីភ្នាក់ងារសហរដ្ឋអាមេរិក សម្រាប់ការអភិវឌ្ឍអន្តរជាតិ (USAID) និងដេប៉ាតឺម៉ង់ប្រព័ន្ធផ្សព្វផ្សាយ និងសារគមនាគន៍ នៃសកលវិទ្យាល័យភូមិន្ទភ្នំពេញ ត្រូវបានបង្កើតឡើងក្នុងគោលបំណងលើកទឹកចិត្តអាណាព្យាបាលទាំងអស់ឱ្យចំណាយពេលអានសៀវភៅជាមួយកូនៗហោចណាស់មួយថ្ងៃក្នុងមួយសប្តាហ៍។



បង្កើតឡើងក្នុងគោលបំណងលើកកម្ពស់ការអាន និងផ្សាភ្ជាប់អំណានរវាងអាណាព្យាបាល និងកុមារ ក្រុមនិស្សិតនៃដេប៉ាតឺម៉ង់ប្រព័ន្ធផ្សព្វផ្សាយនិងសារគមនាគមន៍ នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ បានបង្កើតនូវយុទ្ធនាការ «ថ្ងៃអាទិត្យថ្ងៃអំណាន» ដើម្បីលើកទឹកចិត្តអាណាព្យាបាលឱ្យងាកមកចំណាយពេលអានសៀវភៅជាមួយកុមារយ៉ាងហោចណាស់មួយថ្ងៃក្នុងមួយសប្តាហ៍ជាពិសេសថ្ងៃអាទិត្យ។ យុទ្ធនាការនេះ ក៏ជាផ្នែកមួយជួយគាំទ្រដល់កម្មវិធី «កុមាររៀន កុមារចេះ» របស់ក្រសួងអប់រំ យុវជន និងកីឡា ក្រោមជំនួយឧបត្ថម្ភពីគម្រោង All Children Reading-Cambodia របស់ USAID។

លោក ហង់ជួន ណារ៉ុន រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា បានបង្ហាញការគាំទ្រដល់យុទ្ធនាការ «ថ្ងៃអាទិត្យ ថ្ងៃអំណាន» ដោយលោកបានលើកឡើងថា ការចំណាយពេលអានរវាងអាណាព្យាបាល និងកុមារបានផ្តល់អត្ថប្រយោជន៍ជាច្រើនដល់កុមារ ដោយពួកគេអាចរៀនសូត្រផ្ទាល់ពីអាណាព្យាបាលបន្ថែមពីអ្វីដែលពួកគេបានរៀននៅសាលា។

លោក ហង់ជួន ណារ៉ុន បានមានប្រសាសន៍ថា៖ «អំណានគឺជាមូលដ្ឋានគ្រឹះដ៏រឹងមាំសម្រាប់ការសិក្សា និងស្វែងយល់លើគ្រប់មុខវិជ្ជាជាពិសេសការលើកកម្ពស់ការសិក្សាភាសាខ្មែរ គណិតវិទ្យានៅថ្នាក់ដំបូងនៃបឋមសិក្សា»។

អ្នកស្រី ហួត សុជាតា អ្នកតំណាងរបស់សមាគមអាយប៊ីប៊ីវ៉ាយ កម្ពុជា (International Board on Books for Young People) ដែលជាស្ថាប័នធ្វើការជំរុញឱ្យមានការអានកាន់តែប្រសើរឡើងនោះ បានលើកឡើងថា ការអានគឺជាបំណិនដ៏សំខាន់ពុំអាចខ្វះបានសម្រាប់កុមារគ្រប់រូប ដើម្បីទុកធ្វើជាស្ពានឆ្ពោះទៅរកចំណេះដឹង និងជំនាញចាំបាច់នានា។ ហើយការអាននេះទៀតសោត ក៏មិនត្រូវរង់ចាំរហូតដល់កុមារចូលរៀននោះ។

អ្នកស្រី ហួត សុជាតា ពន្យល់បន្ថែមទៀតថា៖ «មនុស្សភាគច្រើនយល់ច្រឡំថា ចាំកូនចូលរៀនថ្នាក់បឋមសិក្សា ចាំរៀនអាន។ តែការធ្វើបែបនេះកុមារនឹងបាត់បង់ឱកាសច្រើន ព្រោះថាការអភិវឌ្ឍផ្នែកភាសា ធ្វើឡើងតាំងពីកុមារចេះនិយាយម្ល៉េះ»។

បើតាមអ្នកជំនាញផ្នែកកុមារតូច បានបញ្ជាក់ថា ការអានគឺជារឿងស្មុគស្មាញ សម្រាប់កុមារដែលទើបនឹងចាប់ផ្តើមរៀនអានជាលើកដំបូង ព្រោះវាទាមទារឱ្យពួកគេគិតច្រើន ក្នុងពេលធ្វើសកម្មភាពអានម្តង។ ដូច្នេះដើម្បីចៀសវៀង កុំឱ្យកុមារការបាក់ទឹកចិត្ត និងការបោះបង់ចោលការអាន អាណាព្យាបាលចាំបាច់ត្រូវផ្តល់ឱកាសអានទៅកុមារ ទៅតាមកម្រិតការលូតលាស់របស់ពួកគេ។

យ៉ាងណាមិញ រដ្ឋមន្ត្រីក្រសួងអប់រំ លោក ហង់ជួន ណារ៉ុនក៏បានសង្កត់ធ្ងន់ថា ការអានជាមួយកុមារបានផ្តល់នូវអត្ថប្រយោជន៍ច្រើន ជាពិសេសលោកឪពុកអ្នកម្តាយ ឬអាណាព្យាបាល អាចជួយពិនិត្យ មិងរំឭកមេរៀន តួអក្សរដែលកុមារបានរៀនពីសាលាបន្ថែមទៀតផងដែរ។ ហើយក្នុងនោះ ឪពុកម្តាយ និងអាណាព្យាបាលពិតជាមានតួនាទីសំខាន់ណាស់ក្នុងការធានាបាននូវពាក្យស្លោក «កុមាររៀន កុមារចេះ» ផងដែរ៕

# ស្ពានហាលអង្គរវត្តគ្រោងនឹងបញ្ចប់ការជួសជុលនៅចុងឆ្នាំ២០២១នេះ





*អត្ថបទ៖ អមរិន្ទ ដានុត*

អាជ្ញាធរជាតិអប្សរាបានឱ្យដឹងនៅថ្ងៃទី១៦ ខែវិច្ឆិកា នេះថា ក្រុមការងារនៃនាយកដ្ឋានអភិរក្សប្រាសាទក្នុងឧទ្យានអង្គរ និងបុរាណវិទ្យាបង្ការកំពុងបង្ហើយការងារដែលនៅសេសសល់ក្នុងការដ្ឋានជួសជុលស្ពានហាលប្រាសាទអង្គរវត្ត ហើយផែនការគ្រោងនឹងបញ្ចប់ទាំងស្រុងនៅចុងឆ្នាំ២០២១នេះ។

បុរាណវិទូ និងជាប្រធានក្រុមការងារជួសជុលស្ពានហាលអង្គរវត្ត លោក អន សុភាព បានមានប្រសាសន៍ថា គិតត្រឹមពាក់កណ្តាលខែវិច្ឆិកានេះ គម្រោងជួសជុលស្ពានហាលអង្គរវត្តសម្រេចបានជិត១០០ភាគរយហើយ។

លោកបន្ថែមថា៖ «ការងារនៅផ្នែកខាងលើនៃកម្រាលស្ពានសម្រេច៩៩ភាគរយហើយ ចំណែកនៅផ្នែកខាងក្រោមនៃជញ្ជាំងថ្មបាយក្រៀមសម្រេចបានប្រមាណ ៨០ភាគរយ ហើយអាចនឹងបញ្ចប់ទាំងស្រុងនៅចុងឆ្នាំ ២០២១ នេះ»។

លោក អន សុភាព បានបន្តថា ដោយឡែកចំពោះការងារជួសជុលកំពង់ទឹកនៅផ្នែកខាងជើងនឹងត្រូវបន្ត ដែលគម្រោងនេះអាចនឹងប្រើពេលមួយឆ្នាំទៀតដើម្បីជួសជុលរួច។

សូមបញ្ជាក់ថា គម្រោងជួសជុលស្ពានហាលអង្គរវត្តប៉ែកខាងជើងដំណាក់កាលទី២ មានប្រវែងសរុប ៩៤ម៉ែត្រ បានចាប់ផ្តើមដំណើរការពីឆ្នាំ២០១៦ មក ដែលជាគម្រោងកិច្ចសហប្រតិបត្តិការរវាងអាជ្ញាធរជាតិអប្សរា និងសាកលវិទ្យាល័យសូហ្វីយ៉ា ប្រទេសជប៉ុន៕





# រដ្ឋមន្ត្រីក្រសួងព័ត៌មានៈ «ប្រសិនបើគ្មានសារព័ត៌មានសេរី ឯករាជ្យ គឺមិនអាចមានសង្គមប្រជាធិបតេយ្យបានទេ»

*អត្ថបទ៖ ផល សុផានិត*

លោក ខៀវ កាញារីទ្ធ រដ្ឋមន្ត្រីក្រសួងព័ត៌មានបានលើកឡើងក្នុងឱកាសអញ្ជើញចូលរួមបើកសិក្ខាសាលាស្តីពី "ការអនុវត្តវិជ្ជាជីវៈ និងសេរីភាពសារព័ត៌មានក្នុងក្របខ័ណ្ឌច្បាប់នៃព្រះរាជាណាចក្រកម្ពុជា" នាព្រឹកទី១៦ ខែវិច្ឆិកា ឆ្នាំ២០២១ នៅសណ្ឋាគាររ៉េស៊ីដង់សុខាភ្នំពេញ ថា ប្រសិនបើគ្មានសារព័ត៌មានសេរី ឯករាជ្យ គឺមិនអាចមានសង្គមប្រជាធិបតេយ្យបានទេ។

លោករដ្ឋមន្ត្រីបានមានប្រសាសន៍ថា នៅក្នុងសង្គមប្រជាធិបតេយ្យ សារព័ត៌មានបានដើរតួនាទីសំខាន់ណាស់ ហើយបើគ្មានសារព័ត៌មានមួយសេរី ឯករាជ្យ គឺមិនអាចមានសង្គមប្រជាធិបតេយ្យបានទេ។

លោករដ្ឋមន្ត្រី បានមានប្រសាសន៍ថា សិទ្ធិសារព័ត៌មានត្រូវបានប្រគល់ជូនប្រជាជនកម្ពុជាគ្រប់រូប ព្រោះនាពេលកន្លងមកមានការច្រឡំថា ច្បាប់ស្តីពីរបបសារព័ត៌មានគឺជាច្បាប់សម្រាប់អ្នកកាសែត ប៉ុន្តែមិនមែននោះទេ ច្បាប់នោះគឺសម្រាប់គ្រប់គ្នា។

លោកបានគូសបញ្ជាក់បន្តថា អ្នកណាក៏អាចធ្វើកាសែតបានដែរ ព្រោះវិជ្ជាជីវៈសារព័ត៌មានគឺជាវិជ្ជាជីវៈសេរី ឥតកំណត់លក្ខខណ្ឌសញ្ញាបត្រឡើយ ប៉ុន្តែត្រូវតែមានក្រឹត្យក្រមដែលត្រូវអនុវត្តន៍។



នាឱកាសនោះ ដែរ លោក រដ្ឋមន្ត្រីបានចាត់ទុកសិក្ខាសាលានាថ្ងៃនេះជាថ្ងៃប្រវត្តិសាស្រ្តដែលអ្នកកាសែត អាជ្ញាធរ និងក្រសួងយុត្តិធម៌ ឈ្វេងយល់ពីគ្នា និងដឹងអំពីផ្លូវដែលត្រូវដើរ។

លោករដ្ឋមន្ត្រីក៏បានលើកឡើងអំពីការយកចិត្តទុកដាក់របស់ប្រមុខរាជរដ្ឋាភិបាល ក្នុងការធានាឱ្យសារព័ត៌មានកម្ពុជាមានសេរីភាព មានវិជ្ជាជីវៈ និងបម្រើការងារ ឱ្យសង្គមពិតប្រាកដ។

សូមជម្រាបជូនថា សិក្ខាសាលានេះ ត្រូវបានរៀបចំឡើងដោយក្រសួងព័ត៌មាន ក្នុងគោលបំណងឱ្យសិក្ខាកាមទាំងអស់យល់ដឹងកាន់តែច្បាស់ថា អ្វីទៅជាការអនុវត្តវិជ្ជាជីវៈសារព័ត៌មានពិតប្រាកដ និងចង់បង្ហាញបញ្ជាក់អំពីកម្រិតសេរីភាពសារព័ត៌មានដែលពាក់ព័ន្ធជាមួយក្របខ័ណ្ឌច្បាប់នៅព្រះរាជាណាចក្រកម្ពុជា។ លើសពីនេះទៀត សិក្ខាសាលានេះមានលក្ខណៈប្រវត្តិសាស្រ្តមួយដែលមានការពន្យល់ច្បាស់លាស់អំពីរបៀបរបបធ្វើការ និងការអនុវត្តវិជ្ជាជីវៈសារព័ត៌មានដែលត្រឹមត្រូវ មានក្រមសីលធម៌ខ្ពស់ ដែលស្របតាមច្បាប់ពាក់ព័ន្ធនៃព្រះរាជាណាចក្រកម្ពុជា៕

# ផ្លូវជាតិលេខ៣ ភ្នំពេញកំពត មានបំពាក់កាមេរ៉ាចាប់ល្បឿនឆ្លាតវៃ ១០ទីតាំង និងភ្លើងសញ្ញាចរាចរណ៍បច្ចេកវិទ្យាទំនើប





*អត្ថបទ៖ ផល សុផានិត*

ក្រសួងសាធារណការនិងដឹកជញ្ជូន បានឲ្យដឹងថា កាមេរ៉ាចាប់ល្បឿនឆ្លាតវៃ ១០ទីតាំង និងភ្លើងសញ្ញាចរាចរណ៍បច្ចេកវិទ្យាទំនើប បានដំឡើងនៅលើផ្លូវជាតិលេខ៣ ដើម្បីចូលរួមកាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍។

ក្រសួងបានបន្តថា កាមេរ៉ាចាប់ល្បឿនឆ្លាតវៃទាំង ១០ទីតាំងត្រូវបានចាប់ផ្តើមដំឡើងចាប់ពីថ្ងៃទី០៤ ខែសីហា ឆ្នាំ២០២១ និងបានបញ្ចប់នៅថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០២១ នៅលើកំណាត់ផ្លូវជាតិលេខ៣ ចោមចៅ-កំពត ដែលមានប្រវែងសរុប១៣៥គីឡូម៉ែត្រ ក្នុងនោះពីចោមចៅដល់បែកគូសជាផ្លូវ ៤គន្លងមានចំនួន៤ទីតាំង និងកំណាត់ផ្លូវពីបែកគូសទៅទីរួមខេត្តកំពត ជាផ្លូវ២គន្លង មានចំនួន ៦ទីតាំង។

ចំណែកភ្លើងសញ្ញាចរាចរណ៍បច្ចេកវិទ្យាទំនើប ពីរទីតាំងត្រូវបានដំឡើងនៅត្រង់ចំណុចវត្តស្លែង និងផ្សារអង្គតាសោម ដែលភ្លើងសញ្ញាចរាចរណ៍ទាំងពីរទីតាំងបំពាក់នូវប្រព័ន្ធWireless សម្រាប់ភ្ជាប់ពីបង្គោលមួយទៅបង្គោលមួយ និងធ្វើការបញ្ជាដំណើរការតាមទូរសព្ទដៃ ព្រមទាំងបំពាក់នូវប្រព័ន្ធសូឡាប្រើប្រាស់ពន្លឺព្រះអាទិត្យសម្រាប់ផ្គត់ផ្គង់អគ្គីសនី។

គោលបំណងសំខាន់នៃការដាក់កាមេរ៉ាចាប់ល្បឿនឆ្លាតវៃ និងភ្លើងសញ្ញាចរាចរណ៍បច្ចេកវិទ្យាទំនើបទាំងនេះ ក្រសួងបានបញ្ជាក់ថា ដើម្បីតាមដាន ការពារសុវត្ថិភាព និងសម្រួលការធ្វើដំណើររបស់បងប្អូនប្រជាពលរដ្ឋលើផ្លូវជាតិលេខ៣ ។អគ្គស្នងការនគរបាលជាតិនឹងគ្រប់គ្រងរាល់សកម្មភាព និងប្រតិបត្តិការរបស់កាមេរ៉ាចាប់ល្បឿនទាំង ១០ទីតាំង ទាំងការគ្រប់គ្រងទិន្នន័យ និងការពិន័យបទល្មើសផងដែរ។

កាមេរ៉ាចាប់ល្បឿនទាំងនេះអាចឱ្យមន្ត្រីជំនាញដឹងនូវល្បឿនរបស់រថយន្ត ពណ៌ ប្រភេទ និងស្លាកលេខរថយន្ត អ្នកបើកបរមិនពាក់ខ្សែក្រវ៉ាត់ការពារ និងប្រើទូរសព្ទពេលបើកបរ។ មុននឹងដាក់ប្រើប្រាស់ផ្លូវការ អាជ្ញាធរពាក់ព័ន្ធនឹងខិតខំអប់រំផ្សព្វផ្សាយ ជូនដំណឹងដល់បងប្អូនប្រជាពលរដ្ឋឱ្យបានដឹងអំពីច្បាប់ចរាចរណ៍ និងការដាក់កាមេរ៉ាចាប់ល្បឿន ហើយអាជ្ញាធរនឹងបំពាក់ផ្លាកសញ្ញាជូនដំណឹងដល់អ្នកបើកបរយ៉ាងតិច១គីឡូម៉ែត្រមុនដល់ទីតាំងកាមេរ៉ាចាប់ល្បឿន។

កាមេរ៉ាចាប់ល្បឿនឆ្លាតវៃទាំង១០ទីតាំង នឹងដាក់ឱ្យប្រើប្រាស់បណ្តោះអាសន្ន ក្នុងអំឡុងខែវិច្ឆិកា ឆ្នាំ២០២១នេះ បន្ទាប់ពីទទួលបានការឯកភាពពីសម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក។ ចំណែកភ្លើងស្តុបចរាចរណ៍ទាំងពីរទីតាំងត្រូវបានដាក់ដំណើរការបណ្តោះអាសន្ននៅដើមខែវិច្ឆិកាផងដែរ៕





# ក្រសួងផែនការផ្សព្វផ្សាយពីស្ថានភាព ប្រជាសាស្ត្រ និងសង្គម-សេដ្ឋកិច្ចរបស់ ជនជាតិដើមភាគតិចនៅកម្ពុជា

*អត្ថបទ៖ អមរិន្ទ ដានុត*

របាយការណ៍អំពីស្ថានភាពប្រជាសាស្ត្រ និងសង្គម-សេដ្ឋកិច្ចរបស់ជនជាតិដើមភាគតិចនៅកម្ពុជា ត្រូវបានផ្សព្វផ្សាយឱ្យប្រើប្រាស់ កាលពីថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០២១ ក្រោមអធិបតីភាពលោក ឆាយ ថន ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ តាមរយៈប្រព័ន្ធវីដេអូអនឡាញ ដែលនេះជារបាយការណ៍លើកដំបូងបង្អស់ និងជាប្រវត្តិសាស្ត្រ ដែលមានព័ត៌មានលម្អិតអំពីស្ថាន-ភាព ប្រជាសាស្ត្រ ស្ថានភាពសង្គម-សេដ្ឋកិច្ច និងការរស់នៅរបស់ជនជាតិដើមភាគតិច។ ។

លោកបានថ្លែងក្នុងឱកាសនោះថា ការរៀបចំរបាយការណ៍នេះឡើង ក្នុងគោលបំណងធ្វើជាមូលដ្ឋានសម្រាប់ការតម្រង់ទិសដល់ការរៀបចំផែនការអភិវឌ្ឍន៍ជនជាតិដើមភាគតិច និងការស្រាវជ្រាវ។ នេះជាសមិទ្ធផលដ៏ធំធេងដែលកើតចេញពីកិច្ចសហការគ្នាល្អរវាងស្ថាប័នរាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ និងសហគមន៍ជនជាតិដើមភាគតិច។

លោកបានមានប្រសាសន៍ថា ៖ «ការកំណត់អំពីអត្តសញ្ញាណជនជាតិដើមភាគតិចនៅកម្ពុជា ត្រូវបានកំណត់ តាមរយៈការប្រើភាសានិយាយពីកំណើត។ ជនជាតិដើមភាគតិចនៅកម្ពុជា មានចំនួន ២២អំបូរ ដែលមានចំនួនប្រជាជនសរុប ១៧៩.១៩៣នាក់ ស្មើនឹង ១,៣៤% នៃប្រជាជនកម្ពុជាសរុប នៅឆ្នាំ ២០០៨ និង មានចំនួន ១៨៣.៨៣១នាក់ ស្មើនឹង ១,២៥% នៃប្រជាជនកម្ពុជាសរុប នៅឆ្នាំ ២០១៣ (អត្រាកំណើនមានត្រឹម ០,៥១% ក្នុងមួយឆ្នាំ)»។

ក្នុងចំណោមអំបូរទាំង ២២ ជនជាតិ ដើមភាគតិចដែលមានចំនួនច្រើនជាង១ម៉ឺននាក់ មានតែ៦អំបូរប៉ុណ្ណោះ គឺ ទំពួន ព្នង គ្រឹង កួយ ចារាយ និង ពៅ ដែលសរុបមានចំនួនស្មើនឹង ៨៨% នៃប្រជាជនជនជាតិដើមភាគតិចទាំង២២អំបូរ។ ទោះជាបច្ចុប្បន្ននេះ ជនជាតិដើមភាគតិចកំពុងរស់នៅស្ទើរគ្រប់រាជធានីខេត្ត ប៉ុន្តែភាគច្រើនលើសលប់នៃជនជាតិ



ដើមភាគតិចទាំងនោះរស់នៅក្នុងខេត្តចំនួន ៦ ប៉ុណ្ណោះ គឺ ខេត្តរតនគិរី មណ្ឌលគិរី ក្រចេះ ស្ទឹងត្រែង កំពង់ធំ និងខេត្តព្រះវិហារ ដែលមានចំនួន ៩២,៤% នៃជនជាតិដើមភាគតិចរស់ទាំងអស់នៅឆ្នាំ២០១៣។

លោក ឆាយ ថន បន្ថែមថា ប្រជាជននៃជនជាតិដើមភាគតិច ជាប្រជាជនវ័យក្មេង អាយុក្រោម១៥ឆ្នាំ មាន ៣៧,៤% នៅឆ្នាំ២០១៣។ ប្រជាជនជនជាតិ ដើមភាគតិចក្នុងវ័យធ្វើការ មានការកើនឡើងក្នុងចន្លោះឆ្នាំ២០០៨-២០១៣ ដោយអត្រាកំណើនប្រចាំឆ្នាំស្មើនឹង ១,២៣%។

លោកថ្លែងថា ៖ «វ័យចាប់ផ្តើមការងារ អាយុ១៨ឆ្នាំ-៣៥ឆ្នាំ មានចំនួន ២៨,៨%, វ័យកណ្តាលអាយុ៣៦ឆ្នាំ-៥៩ឆ្នាំ មានចំនួន១៧,៨% និង វ័យចាស់អាយុ ៦០ឆ្នាំ ឡើង មានចំនួន ៥,៤%»។ គ្រួសារដែលមានស្ត្រីជាមេគ្រួសារ មានចំនួន ២២% នៅឆ្នាំ២០១៣ និងប្រហែល១៨% នៃ គ្រួសារជនជាតិដើមភាគតិច ជាគ្រួសារដែលមានតែប្តីជាជនជាតិដើមភាគតិច ឯប្រពន្ធជាជនជាតិផ្សេងទៀត ឬជាគ្រួសារដែលមានតែប្រពន្ធជាជនជាតិដើមភាគតិច ឯប្តីជាជនជាតិផ្សេង ទៀត។

រដ្ឋមន្ត្រីនៃក្រសួងផែនការ បានបន្តថា ជនជាតិដើមភាគតិចបានទទួលការអប់រំតិច ដោយសារអត្រាចូលរៀនទាប, ការរៀននៅកម្រិតទាបជាងអាយុ និងការបោះបង់ការសិក្សា។

លោកថា ៖ «ប្រហែលជា ១ភាគ៣ នៃ ជនជាតិដើមភាគតិច ចេះអាននិងសរសេរភាសាខ្មែរ មាន ៣៣.៨% ក្នុងចំណោមជនជាតិ ដើមភាគតិចអាយុ១៥ឆ្នាំឡើង ហើយបុរសជាទូទៅ មានអត្រាអក្ខរភាពខ្ពស់ជាងស្ត្រី។ កុមារ ជនជាតិដើមភាគតិចជិត ៥០% មិនបានរៀនសោះ»។

ក្នុងចំណោមប្រជាជនជនជាតិដើមភាគ តិចអាយុ១៥ឆ្នាំឡើង ជិត ៦៦% មិនបានរៀន ឬបញ្ចប់កម្រិតសិក្សាអ្វីទាំងអស់ រីឯ ២៤,១% ទៀតបានរៀនត្រឹមបឋមសិក្សាប៉ុណ្ណោះ។ រីឯអ្នកបានរៀនដល់កម្រិតមធ្យមសិក្សាបឋមភូមិ មានចំនួនប្រហែល ១០% ដែលក្នុងនោះ អ្នករៀនបានកម្រិតមធ្យមសិក្សាទុតិយភូមិមានចំនួន ត្រឹម ៤%។

សម្រាប់ការងារនិងស្ថានភាពសេដ្ឋកិច្ចវិញ លោក ឆាយ ថន បានបញ្ជាក់ថា ជនជាតិដើមភាគតិចមានអត្រាសកម្មសេដ្ឋកិច្ចខ្ពស់ និងខុសគ្នាតិចតួចរវាងបុរសនិងស្ត្រី គឺមានចំនួន ៨៧,៧% ក្នុងចំណោមបុរស និង ៨៥,៥% ក្នុងចំណោមស្ត្រី។ គិតតាមវិស័យសេដ្ឋកិច្ច ភាគច្រើនលើសលប់នៃជនជាតិដើមភាគតិចអាយុ ១៥ឆ្នាំឡើង ដែលមានការងារធ្វើ ប្រកបរបរក្នុងវិស័យកសិកម្ម សរុប ៩៣,៣% (បុរស៩០,៦% និងស្ត្រី៩៥,៩%) និងតិចតួចដែលធ្វើការក្នុងវិស័យឧស្សាហកម្ម សរុប ១,៦% (បុរស១,៨% និងស្ត្រី១,៤%) និងវិស័យសេវាកម្ម សរុប ៥,១% (បុរស៧,៦% និងស្ត្រី២,៨%)។

លោកឆាយ ថន បានលើកឡើងផងដែរថា ជនជាតិភាគតិចច្រើនសម្រាលកូននៅតាមផ្ទះ មាន ៥៣% និងសម្រាលកូននៅមន្ទីរពេទ្យ មាន ៣៨%។ ការសម្រាលកូននៅមណ្ឌលសុខភាព មានចំនួន ត្រឹម ៦% ប៉ុណ្ណោះ។ ស្ត្រីជាម្តាយសុទ្ធតែបានបំបៅកូនដោយទឹកដោះម្តាយទាំងអស់។ពិសេសទៅទៀត ម្តាយដែលមានកូនអាយុក្រោម២ឆ្នាំទាំងអស់ នៅបន្តបំបៅដោះកូននៅឡើយ (១០០%)។

ទាក់ទងនឹងលំនៅឋាននិងកម្មសិទ្ធិផងដែរ លោក ឆាយ ថន បានឱ្យដឹងថា នៅឆ្នាំ២០១៣ ជាង ៩៥% នៃគ្រួសារជនជាតិដើមភាគតិច មានលំនៅឋានខ្លួនឯង។ ភាគច្រើននៃគ្រួសារជនជាតិដើមភាគតិច ប្រើប្រាស់ចង្កៀងប្រេងកាត និងអាគុយជាប្រភពភ្លើងបំភ្លឺ រីឯគ្រួសារដែលប្រើប្រាស់ភ្លើងអគ្គិសនី ឬម៉ាស៊ីនភ្លើង ផ្ទាល់ខ្លួន មានចំនួន ២០,៦% នៅឆ្នាំ២០១៣។

លោកថា ចំពោះប្រភពថាមពលចម្អិន ភាគច្រើននៃ គ្រួសារជនជាតិដើមភាគតិច ប្រើប្រាស់ឧសជាប្រភពថាមពលចម្អិនអាហារ មានចំនួន ៩៥% នៅឆ្នាំ២០១៣។ ចំពោះសម្ភារៈគ្រួសារសម្រាប់ព័ត៌មាន និងការប្រាស្រ័យទាក់ទង គ្រួសារជនជាតិដើមភាគតិច ជិត ១ភាគ៣ នៃគ្រួសារ មានទូរទស្សន៍ប្រើ។ ចំពោះសម្ភារៈគ្រួសារសម្រាប់ការធ្វើដំណើរ គ្រួសារជនជាតិដើមភាគតិចចំនួន ៧៦,១% មានម៉ូតូ, ២,២% មានរថយន្ត, ៩,១% មានគោយន្ត, ៧,៨% មានទូក និង ៣៧,៤% មានកង់។

លោកមានប្រសាសន៍ថា ៖ «ដោយពិនិត្យលើទិដ្ឋភាពរួមជនជាតិដើមភាគតិចនៅកម្ពុជា ត្រូវបានចាត់ទុកថាជា ប្រជាជនងាយរងគ្រោះនៅក្នុងបរិការណ៍នៃការអភិវឌ្ឍប្រកបដោយចីរភាព។ ជនជាតិដើមភាគតិចនៅកម្ពុជា កំពុងមានស្ថានភាពប្រជាសាស្ត្រប្រែប្រួលឆ្ពោះទៅរកស្ថានភាពប្រជាសាស្ត្ររបស់ប្រជាជនកម្ពុជាទូទៅ ដូចជា ការថយចុះនៃអត្រាកំណើត និងអត្រាមរណភាព ការកើនឡើងនៃអាយុរៀបការដំបូង ការកើនឡើងនៃកម្លាំងពលកម្ម និងនិន្នាការនៃទេសន្តរប្រវេ សន៍ទៅកាន់ទីប្រជុំជន»។

លោក ឆាយ ថន បានបន្តថា ការប្រែប្រួលទាំងនេះ នៅមានទំហំតូចនៅឡើយ បើធៀបទៅ នឹងការប្រែប្រួលនៃស្ថានភាពប្រជាសាស្ត្រនៃប្រជាជនកម្ពុជាសរុប៕





# លោកអភិបាលអូលីវីយេ ស្នើឲ្យគ្រីស្តបរិស័ទ បើកចិត្ត និងដៃក្តីស្រឡាញ់សម្រាប់អ្នកដទៃ

*អត្ថបទ៖ ដាលីស*

«នាមជាគ្រីស្តបរិស័ទដែលពោរពេញដោយក្តីសង្ឃឹម យកចិត្តទុកដាក់ដល់បងប្អូនឯទៀតៗ ដើម្បីស្រឡាញ់បងប្អូនឯទៀតៗ» លោកអភិបាលអូលីវីយេ មានប្រសាសន៍នៅក្នុងកម្មវិធីអគ្គសញ្ញាលាបថ្ងាសនៅព្រះសហគមន៍ចំប៉ា។

លោកអភិបាលមានប្រសាសន៍បញ្ជាក់ថា ៖ «សូមកុំបិទដួងចិត្តដែលជាភ្លើងនៃសេចក្តីសង្ឃឹម ដោយអធិដ្ឋាន និងថែរក្សាសេចក្តីស្រឡាញ់ចំពោះបងប្អូនឯទៀតៗ»។

ព្រះវិហារសន្តហ្វ្រង់ស្វ័រសាវីយេ ចំប៉ា បានរៀបចំឲ្យមានអគ្គសញ្ញាលាបថ្ងាសដល់បេក្ខជនចំនួន៦៨នាក់ ក្រោមអធិបតីភាពរបស់លោកអភិបាលអូលីវីយេ ជ្មីតហាស្លេ និងលោកបូជាចារ្យទទួលខុសត្រូវមណ្ឌលសកម្មភាព វីរជ័យ ស៊្រីប្រាម៉ុង ក្នុងភូមិជ្រោយអំពិល ឃុំក្បាលកោះ ស្រុកកៀនស្វាយ ខេត្តកណ្តាល នៃមណ្ឌលសកម្មភាពទន្លេមេគង្គ នាថ្ងៃទី ១៤ វិច្ឆិកា ២០២១។

ក្នុងពិធីនោះ លោកអភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ បានសួរបញ្ជាក់ទៅកាន់បេក្ខជនទាំងអស់ អំពីជំនឿដែលសុខចិត្តដើរតាម



ព្រះយេស៊ូកន្លងមក និងធ្វើជាសាក្សីនៃសេចក្តីស្រឡាញ់របស់ព្រះអង្គ។

ក្នុងជីវិតជាគ្រីស្តបរិស័ទ មានកិច្ចការជាច្រើនដែលត្រូវធ្វើ តែរាល់កិច្ចការងារទាំងនោះ គឺត្រូវទូលអង្វរព្រះជាម្ចាស់ មានទំនាក់ទំនងជាមួយព្រះអង្គ។ លោកអភិបាលបានបញ្ជាក់ថា គ្រីស្តបរិស័ទត្រូវយកពេលវេលាដើម្បីអធិដ្ឋាន ដោយដឹងថាយើងជាបុត្រាបុត្រីរបស់ព្រះជាម្ចាស់ ដើម្បីធ្វើដំណើរជាមួយព្រះជាម្ចាស់យ៉ាងជិតស្និទ្ធ។

លោកអភិបាលបញ្ជាក់បន្ថែមថា ជាគ្រីស្តបរិស័ទ យើងពោរពេញដោយសេចក្តីសង្ឃឹមជានិច្ច។ យើងត្រូវរក្សាក្តីសង្ឃឹម ដោយដឹងថាយើងបានទទួលព្រះវិញ្ញាណដ៏វិសុទ្ធ ហើយថ្ងៃនេះយើងបានទទួលព្រះវិញ្ញាណដ៏វិសុទ្ធ។

បន្ទាប់ពីធ្វើធម្មទេសនា លោកអភិបាល បានធ្វើអគ្គសញ្ញាលាបថ្ងាស ដល់បេក្ខជនទាំង៦៨នាក់ ដោយយកប្រេងគ្រីស្មាមកគូសជាសញ្ញាឈើឆ្កាងលើថ្ងាស ដោយប្រកាសដៅឈ្មោះបេក្ខជនដោយព្រះវិញ្ញាណដ៏វិសុទ្ធ ក្នុងព្រះនាមព្រះបិតាព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ។

វ៉ាន់ សុផារី អ្នកទទួលអគ្គសញ្ញាលាបថ្ងាសនៅថ្ងៃនេះ បានឲ្យដឹងថា ៖ «អគ្គសញ្ញាលាបថ្ងាសនេះសំខាន់ណាស់ ហើយបានលោកអភិបាលធ្វើអភិបូជានៃអគ្គសញ្ញាលាបថ្ងាសនេះ គឺព្រះវិញ្ញាណដ៏វិសុទ្ធមកសណ្ឋិតលើខ្ញុំ ធ្វើឱ្យខ្ញុំមានក្តីសង្ឃឹមច្រើន មានសេចក្តីក្លាហាន និងសេចក្តីស្រឡាញ់»។

បេក្ខជន Rogério Mala Soares ជនជាតិទីម័រដែលមករស់នៅកម្ពុជា៣ឆ្នាំកន្លងមកបានឱ្យដឹងថា «អគ្គសញ្ញាលាបថ្ងាសនេះពិតជាមានសារៈសំខាន់ណាស់នៅក្នុងជីវិតរបស់ខ្ញុំ ព្រោះថាក្នុងនាមជាគ្រីស្តបរិស័ទកាតូលិក ប្រសិនបើគ្មានអគ្គសញ្ញានេះទេ ខ្ញុំមិនអាចរៀបអាពាហ៍ពិពាហ៍បានឡើយ»។

បេក្ខជនទាំង៦៨នាក់មកពី ព្រះសហគមចំប៉ា៥៤នាក់ ព្រះសហគមន៍រោងចក្រ ១២នាក់។

អគ្គសញ្ញាលាបថ្ងាសជាអគ្គសញ្ញាទី៤ ក្នុងចំណោមអគ្គសញ្ញាទាំង៧ នៅក្នុងជីវិតគ្រីស្តបរិស័ទ បន្ទាប់ពីអគ្គសញ្ញាជ្រមុជទឹក អគ្គសញ្ញាទទួលព្រះកាយ និងអគ្គសញ្ញាសម្រុះសម្រួល (ស្រាយបាប)៕

# គ្រីស្តបរិស័ទ១២រូបទទួលអគ្គសញ្ញាលាបថ្ងាស ក្នុងអំឡុងពេលកូវីដ១៩ ជាលើកដំបូង

*អត្ថបទ៖ ដាលីស*

គ្រីស្តបរិស័ទចំនួន១២រូប បានទទួលអគ្គសញ្ញាលាបថ្ងាស នាព្រឹកថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ២០២១ នៅព្រះវិហារសន្តសិលានិងសន្តប៉ូលភ្នំពេញថ្មី សង្កាត់ពោធិអង្រ្កង ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ដើម្បីក្លាយជាគ្រីស្តបរិស័ទដ៏ពេញលក្ខណៈតាមប្រពៃណីព្រះសហគមន៍កាតូលិក។

ពិធីអគ្គសញ្ញាលាបថ្ងាសនេះធ្វើឡើងក្រោមអធិបតីភាពលោកអភិបាលព្រះសហគមន៍ភូមិភាគភ្នំពេញ អូលីវីយេ ជ្មីតហាស្លេរ រួមជាមួយលោកបូជាចារ្យទទួលខុសត្រូវព្រះសហគមន៍សិលា សួន ហង្សលី។

លោកបូជាចារ្យ សួន ហង្សលី មានប្រសាសន៍បើកកម្មវិធីអភិបូជានៃអគ្គសញ្ញាលាបថ្ងាសនេះថា ថ្ងៃនេះជាថ្ងៃពិសេសមានបេក្ខជន ១២នាក់ដែលមកសុំទទួលអគ្គសញ្ញាលាបថ្ងាស ដោយមានខ្លះបានទទួលអគ្គសញ្ញាជ្រមុជទឹកតាំងពីឆ្នាំ២០១២ ២០២០ និង២០២១។

លោកថា ៖ «ដោយសារបញ្ហានៃការរីករាលដាលនៃវីរុសកូវីដ១៩ យើងមិនអាចធ្វើអត្តសញ្ញាជូនបេក្ខជនរបស់យើងបាន តែនៅថ្ងៃនេះ ជាថ្ងៃពិសេសដែលបេក្ខជនរបស់យើងបានរៀបចំចិត្តគំនិតដើម្បីសុំលោកអភិបាលក្នុងការទទួលអគ្គសញ្ញាលាបថ្ងាស។ថ្ងៃនេះគឺជាសញ្ញាពិសេសដែលបញ្ជាក់អំពីការរីកចម្រើននៃព្រះសហគមន៍របស់យើង ហើយប្អូនដែលទទួលអគ្គសញ្ញាលាបថ្ងាសនៅថ្ងៃនេះគឺជាសាក្សីនៃជំនឿរបស់យើង»។

នៅក្នុងពិធីនេះដែរ លោកអភិបាលអូលីវីយេ ក៏បានលើកឡើងផងដែរថា នេះជាលើកទី១ បន្ទាប់ពីថ្ងៃ ២០ កុម្ភៈ ដែលមានឱកាសជួបជុំគ្នានៅក្នុងថ្ងៃនេះនៅក្នុងសេរីភាព បន្ទាប់ពី៨ ខែកន្លងមកដែលគ្រប់គ្នាមិនបានចូលក្នុងពិធីបូជាដែលមានគ្នាច្រើនដូចនេះ។

លោកបានមានប្រសាសន៍ថា ៖ «ហើយនេះក៏ជាលើកទី១ ដែលព្រះសហគមន៍យើងធ្វើអត្តសញ្ញាលាបថ្ងាសនៅក្នុងឆ្នាំនេះ គឺបានប្រើប្រេងពិសិដ្ឋដែលបានប្រសិទ្ធិពរជាមួយលោកបូជាចារ្យមួយចំនួនកាលពីថ្ងៃទី២៤ ខែមិថុនា ឆ្នាំនេះដើម្បីធ្វើអគ្គសញ្ញានានា»។

លោកអភិបាលបានបញ្ជាក់ថា នៅថ្ងៃទី០៧ ខែវិច្ឆិកា មានគ្រីស្តបរិស័ទចំនួន១២នាក់ រីឯខែខាងមុខនេះមានជាង១០០ នាក់នៅចំប៉ាដែលនឹងទទួលអគ្គសញ្ញាលាបថ្ងាស។ នេះជាឱកាសដើម្បីប្រើប្រេងនេះដើម្បីផ្តល់កម្លាំងដែលមកពីព្រះវិញ្ញាណបរិសុទ្ធសម្រាប់ព្រះសហគមន៍។

លោកអភិបាលអូលីវីយេ បានមានប្រសាសន៍នៅក្នុងធម្មទេសនា ដោយលោកបានស្នើឲ្យគ្រីស្តបរិស័ទ ពិចារណាអំពីក្រុមគ្រីស្តទូតពីដើម និងអំពីជីវិតនៅក្នុងរដូវកាលកូវីដ១៩។ លោកបានថ្លែងថា ៖ «ក្រុមគ្រីស្តទូតពីដើមចូលក្នុងបន្ទប់ដ៏តូចមួយដើម្បីអធិដ្ឋានដោយបិទទ្វារព្រោះភ័យខ្លាចអាជ្ញាធរ។ ពេលយើងនិយាយអំពីការភ័យខ្លាច យើងនឹកឃើញដល់កូវីដ១៩ តាំងពីយើងធ្វើជំហានទី២ រហូតដល់ពេលនេះគឺយើងរស់នៅក្នុងភាពភ័យខ្លាច ការប្រុងប្រយ័ត្នដែលនាំឲ្យយើងភ័យខ្លាចដោយខ្លាចឆ្លង កូវីដ១៩ យើងខ្លាចបងប្អូនឯទៀតៗ»។

លោអូលីវីយេ បានបញ្ជាក់ទៀតថា ៖ «នៅពេលយើងខ្លាចមនុស្សយើងបិទទ្វារផ្ទះ និងបិទទ្វារនៃដួងចិត្តរបស់យើងដែរ។ ពេលយើងភ័យខ្លាចយើងបាត់បង់ទំនាក់ទំនងផ្ទាល់ដោយនៅឆ្ងាយពីគ្នា។ មនុស្សគ្រប់កម្រិតចាប់ផ្តើមស្គាល់ដូងតាមរយៈ zoom នៅតែតាមកញ្ចក់កុំព្យូទ័រនិងទូរស័ព្ទ»។

ក្នុងពិធីដដែលនេះដែរ លោកអភិបាលអូលីវីយេ បានផ្តាំផ្ញើដល់បេក្ខជនទទួលអគ្គសញ្ញាលាបថ្ងាសក៏ដូចជាគ្រីស្តបរិស័ទទាំងអស់ឱ្យយកចិត្តទុកដាក់ធ្វើជាសាក្សីកុំឲ្យខ្លាច និងធ្វើជាគ្រីស្តបរិស័ទត្រឹមតែក្នុងព្រះវិហារ ដោយត្រូវយល់ថាថ្ងៃនេះអ្នកទាំងអស់ពាក់អាវសមានកន្សែងក្រហម ដែលជាសញ្ញានៃព្រះវិញ្ញាណដ៏វិសុទ្ធ និងឱ្យកន្សែងនេះនៅក្នុងដួងចិត្តរាល់គ្នា កុំឲ្យខ្លាចធ្វើជាសាក្សីអំពីព្រះយេស៊ូនៅក្នុងដួងចិត្តរបស់អ្នកគ្រប់គ្នា។

លោកមានប្រសាសន៍ថា ៖ «ហ៊ានប្រកាសអំពីដំណឹងល្អដូចក្រុមគ្រីស្តទូត តាមរយៈជីវិតរស់នៅរបស់យើងផ្ទាល់។ យើងរៀងៗខ្លួនមានទេពកោសល្យ និងសមត្ថភាព។ និងត្រូវបង្កើតទំនាក់ទំនងជាមួយព្រះជាម្ចាស់ជារឿងសំខាន់។ កូវីដ១៩ នៅពេលដែលយើងនៅឆ្ងាយពីព្រះវិហារ យើងក៏អាចស្តាប់ព្រះបន្ទូលបានតាមរយៈបណ្តាញសង្គម»។

នៅក្នុងថ្ងៃនេះដែរ បេក្ខជន សុង គឹមហេង បានប្រាប់អ្នកនាំសារថា ៖ «នៅពេលដែលខ្ញុំបានទទួលអគ្គសញ្ញាលាបថ្ងាសនេះ ខ្ញុំពិតជាមានអំណរសប្បាយរីករាយ និងរំភើបជាខ្លាំង ព្រោះនេះជាចំណុចមួយដែលជំរុញយើងជាគ្រីស្តបរិស័ទហ៊ានប្រកាសជំនឿ បង្ហាញសេចក្តីស្រឡាញ់ ជាពិសេសធ្វើជាសក្ខីភាពអំពីព្រះសហគមន៍ដល់បងប្អូនឯទៀតៗដែលមិនទាន់ស្គាល់ព្រះសហគមន៍»។

លោក សុង គឹមហេង បានបន្តថា លោកធ្វើដោយទំនុកចិត្តដូចជាការទៅសួរសុខទុក្ខដល់បងប្អូនក្រីក្រ ក្នុងនាមជាព្រះគ្រីស្ត ហើយលោកបន្តសន្យាធ្វើជាគ្រីស្តបរិស័ទពេញលេញ និងធ្វើជាគ្រីស្តបរិស័ទគំរូក្រោយពេលធ្វើអគ្គសញ្ញាលាបថ្ងាសនេះ។

រីឯបេក្ខនារី ឈាង ស្រីនា បានឱ្យដឹងផងដែរថា សម្រាប់រូបនាងផ្ទាល់គិតថាព្រះវិញ្ញាណដ៏វិសុទ្ធជួយឱ្យនាងមានភាពរឹងមាំ ក្លាហាន ដើម្បីប្រកាសជំនឿ និងចែកសេចក្តីស្រឡាញ់ដល់ជនដែលខ្វះខាត។

នៅក្នុងកម្មវិធីអភិបូជានៃអគ្គសញ្ញាលាបថ្ងាសនេះ ព្រះសហគមន៍បានអញ្ជើញបេក្ខជនមុខធ្វើពិធីលះបង់ចោលមារនិងប្រកាសជំនឿជាថ្មី ព្រមទាំងអធិដ្ឋានអង្វរព្រះជាម្ចាស់តាមរយៈពិធីទ្រាប់ដៃដោយបេក្ខជននិងបងធម៌ទាំងអស់លំឱនកាយដល់កន្ទេល និងលោកអភិបាលរួមជាមួយលោកបូជាចារ្យទូលអង្វរព្រះជាម្ចាស់ប្រទានព្រះវិញ្ញាណព្រះអង្គមុខគង់នៅជាមួយបងប្អូនទាំងនេះដើម្បីឲ្យពួកគេបានស្គាល់សេចក្តីពិតបានទទួលព្រះអំណោយទានរបស់ព្រះជាម្ចាស់និងបានអភិសេកដូចជាព្រះគ្រីស្ត៕

# ព្រះសហគមន៍ជូនគ្រឿងឧបភោគដល់អាជ្ញាធរខណ្ឌឫស្សីកែវ



*អត្ថបទ៖ ព្រះសហគមន៍*

ព្រះសហគមន៍មណ្ឌលសកម្មភាពភ្នំពេញខាងជើងព្រះវិហារសន្តយ៉ូសែបផ្សារតូចដឹកនាំដោយលោកបូជាចារ្យ ប៉ូល រឿង ឆ័ត្រសិរី និងតំណាងគ្រីស្តបរិស័ទកាតូលិក នាំយកគ្រឿងឧបភោគបរិភោគមួយចំនួន ជូនដល់អភិបាលនៃគណៈអភិបាលខណ្ឌឫស្សីកែវថ្មី លោក ឯក យុនឿន ដែលលោកទើបចូលកាន់តំណែងជាអភិបាលខណ្ឌ ដើម្បីចូលរួមសកម្មភាពមនុស្សធម៌នានា ក្នុងការបង្ការទប់ស្កាត់ និងគ្រប់គ្រងការឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩ នៅក្នុងខណ្ឌឫស្សីកែវ នាថ្ងៃទី ១៦ វិច្ឆិកា ២០២១នេះ។

នៅក្នុងពិធីសំណេះសំណាលនិងអបអរសាទរការឡើងកាន់តំណែងថ្មីរបស់លោកអភិបាលខណ្ឌឫស្សីកែវ លោកបូជាចារ្យ ប៉ូល រឿង ឆ័ត្រសិរី ជាអ្នកទទួលបន្ទុកមណ្ឌលសកម្មភាពព្រះសហគមន៍កាតូលិកភ្នំពេញខាងជើង មានប្រសាសន៍ថា ថ្ងៃនេះជាឱកាសល្អ ដែលក្នុងនាមព្រះសហគន៍មកសួរសុខទុក្ខសំណេះសំណាលជាមួយលោកអភិបាលខណ្ឌថ្មីនិងជាឱកាសមួយ អនុញ្ញាតឲ្យព្រះសហគមន៍រួមសហការជាមួយសង្គម ដូចព្រះយេស៊ូធ្លាប់មានបន្ទូលអំពីការផ្តល់អាហារ ការសួរសុខទុក្ខអ្នកជំងឺ និងផ្តល់សម្លៀកបំពាក់ជាដើម គឺជាកិច្ចការខាងសង្គមរបស់ព្រះសហគមន៍ដែលត្រូវធ្វើ។

លោកថា ព្រះហឫទ័យរបស់ព្រះជាម្ចាស់ទតមើលលើកិច្ចការរបស់យើង។ ថ្ងៃនេះព្រះសហគមន៍យើងធ្វើជាតំណាងនៃព្រះន្ទូលរបស់ព្រះជាម្ចាស់ ដោយយើងមានទំនាក់ទំនងល្អជាមួយខាងរដ្ឋដែលជាផ្នែកនៃសង្គម គឺជាកិច្ចការមួយដែលគួរឱ្យមាននៅក្នុងជីវិតរបស់ព្រះសហគន៍ប្រចាំថ្ងៃ ដោយសាររដ្ឋមានតួនាទីគ្រប់គ្រងដើម្បីឱ្យមានផលល្អសម្រាប់ប្រជាជន ហើយព្រះសហគមន៍របស់យើងក៏មានឋានៈជាប្រជាពលរដ្ឋរបស់រដ្ឋនីមួយៗដែរ។ ដូច្នេះការពង្រឹងទំនាក់ទំនងធ្វើឱ្យយើងមានភាពស្និទ្ធស្នាលជាមួយគ្នា ហើយកិច្ចការដែលព្រះសហគមន៍ធ្វើគឺគោរពទៅនឹងច្បាប់របស់រដ្ឋ និងរដ្ឋក៏ជួយដល់កិច្ចការឬបេសកកម្មផ្សេងៗរបស់ព្រះសហគមន៍។

លោកបន្ថែមថា «ការជួយគ្នាទៅវិញទៅមកនេះជាឱកាសមួយដើម្បីឱ្យយើងយល់គ្នាពីតួនាទីរៀងៗខ្លួន ហើយព្រះសហគមន៍ជួយគ្រីស្តបរិស័ទខាងផ្លូវវិញ្ញាណក៏ជួយជំរុញឱ្យគ្រីស្តបរិស័ទជាមនុស្សល្អរបស់សង្គម។ ប្រសិនបើសង្គមមានការគ្រប់គ្រងល្អ ក៏ជួយដល់ការប្រកាសដំណឹងល្អរបស់ព្រះសហគមន៍ឱ្យកាន់តែរីកចម្រើនដែរ»។

ជាមួយគ្នានេះដែរលោកអភិបាលខណ្ឌថ្មីលោក ឯក យុនឿន មានប្រសាសន៍ថ្លែងអំណរគុណដល់ព្រះសហគមន៍កាតូលិកដែលបានពាំនាំនូវគ្រឿងឧបភោគបរិភោគ និងថវិកាមួយចំនួនមកជូនអាជ្ញាធរខណ្ឌឫស្សីកែវ ក្នុងការជួយសង្គ្រោះប្រជាពលរដ្ឋនៅក្នុងសហគមន៍ដែលកំពុងតែជួបការលំបាកនិងខ្វះខាត។

លោកអភិបាលខណ្ឌបន្តថា បងប្អូនខាងព្រះវិហារកាតូលិកបានចូលរួមចំណែកយ៉ាងសំខាន់ដល់ការគាំទ្រគោលនយោបាយរបស់សម្តេចតេជោ ក្នុងការជួយគ្នា និងចូលរួមអភិវឌ្ឍប្រទេសក្រោមដំបូលសន្តិភាព ដែលធ្វើឱ្យប្រទេសរបស់យើងមានភាពរីកចម្រើនទាំងសុខដុមសាសនាផង ទាំងការអភិវឌ្ឍប្រទេសជាតិផង ហើយនេះជាទឹកចិត្តដ៏ល្អប្រពៃរបស់បងប្អូនកាតូលិកដែលបានរួមចំណែកជាមួយរាជរដ្ឋាភិបាល ក្នុងការដោះស្រាយ និងរួមគ្នាអភិវឌ្ឍប្រទេស។

លោកបានសង្កត់ធ្ងន់ថា «សាសនាទាំងអស់ល្អដូចគ្នា ហើយចំណុចគោលធំៗដែលយើងចង់បាននោះគឺសន្តិភាព គេចផុតពីសង្គ្រាម ការជួយអ្នកខ្វះខាត អ្នករងគ្រោះ និងចូលរួមអភិវឌ្ឍ ហើយពិសេសការជួយគ្នាទៅវិញទៅមករវាងព្រះសហគមន៍និងរដ្ឋអំណាចមានសារសំខាន់ណាស់ ដោយយើងអាចរួមគ្នាលុបបំបាត់នូវភាពក្រីក្រផង និងអ្វីដែលជាអំពើអបាយមុខផង ហើយយើងរួមគ្នាថែទាំសន្តិភាព និងការអភិវឌ្ឍ ដែលទាំងអស់នេះមិនអាចឃ្លាតឆ្ងាយគ្នាបានទេ»។

លោកបន្ថែមថា គ្រប់សាសនា និងគ្រប់ជាតិសាសន៍ដែលមាននៅលើផែនដី ក៏ដូចជានៅក្នុងប្រទេសយើងនេះសុទ្ធតែជាកោសិកាសង្គមមួយដែលយើងត្រូវតែរួមគ្នាចូលរួមថែទាំសន្តិភាពដែលជាគោលការណ៍ធំ ហើយជួយគ្នាក្នុងការបណ្តុះបណ្តាលធនធានមនុស្ស ជួយគ្នាក្នុងការសង្គ្រោះអ្នកដែលខ្វះខាតរងគ្រោះដោយសារសង្គ្រាមឬទុរភិក្ស សុទ្ធសឹងតែជាគោលដៅដែលយើងចង់បាន។

លោកអភិបាលខណ្ឌ បានថ្លែងអំណរគុណ និងកោតសរសើរព្រះសហគមន៍កាតូលិកដែលមានបំណងសាងសង់ព្រះវិហារ កសាងសាលាបណ្តុះបណ្តាលធនធានមនុស្ស និងមជ្ឍមណ្ឌលព្យាបាល ដែលសុទ្ធសឹងតែជាគោលនយោបាយរបស់សម្តេចតេជោដែលចង់ជួយប្រជាជនខ្មែរយើងឱ្យមានសុខភាពល្អ និងធូរធារ៕

# គ្រូអប់រំជំនឿភ្នំពេញខាងជើងរិះគិតរួមគ្នារៀបបញ្ជូនបន្តជំនឿ





*អត្ថបទ៖ លោកបូជាចារ្យ ឆ័ត្រសិរី*

គ្រូអប់រំជំនឿនៃព្រះសហគមន៍មណ្ឌលសកម្មភាពភ្នំពេញខាងជើង១៨នាក់ ចូលរួមសំណាក់ធម៌ ដើម្បីពង្រឹងជីវិតខាងផ្លូវវិញ្ញាណ និង ចិត្តវិទ្យាជាគ្រូណែនាំបន្តជំនឿឱ្យប្អូនៗកុមារតូចៗ និង មនុស្សពេញវ័យក្រោមការណែនាំដោយលោកបូជាចារ្យទទួលខុសត្រូវមណ្ឌលសកម្មភាពភ្នំពេញខាងជើង ប៉ូល រឿងឆ័ត្រសិរី និងបងស្រី សុភក្រ្តា សូផុន។

កម្មវិធីសំណាក់ធម៌នេះធ្វើឡើងនៅព្រះវិហារសន្តសិលាពោធិ៍ធំ នាថ្ងៃទី៩ វិច្ឆិកា ២០២១នេះ។ កម្មវិធីសំណាក់ធម៌នេះធ្វើឡើងតែមួយថ្ងៃ ដោយរិះគិតលើប្រធានបទសន្និបាតឆ្នាំ២០២១-២០២៣ ដោយលើកយកព្រះបន្ទូលនៅក្នុងសន្និបាត តាមរយៈរឿង លោកសិលាចួបនាយទាហានរ៉ូម៉ាំង ក្នុងកិច្ចការគ្រីស្តទូត ជំពូក ១០។

នៅក្នុងកម្មវិធីសំណាក់ធម៌នេះលោកបូជាចារ្យទទួលបន្ទុកមណ្ឌលសកម្មភាព ឆ័ត្រសិរី មានប្រសាសន៍ដោយបញ្ជាក់អំពីតួនាទី «ព្យាការីរបស់យើង ជាអ្នកប្រកាសដំណឹងល្អ យើងជាសាសនទូត»។

ក្រុមគ្រូអប់រំជំនឿបានរិះគិត និងឆ្លើយសំណួរទាំង៣របស់អង្គសន្និបាតព្រះសហគមន៍២០២១-២០២៣ ដែលលោកអភិបាលឱ្យព្រះសហគមន៍នីមួយៗរិះគិត។ ក្នុងឱកាសនេះដែរក្រុមគ្រូអប់រំជំនឿក៏បានប្រជុំរៀបចំថ្នាក់ទទួលសិស្សថ្មី ដោយមានពិធីបើកឆ្នាំអប់រំជំនឿ និងពិធីចាត់គ្រូអប់រំជំនឿឱ្យទៅ នៅថ្ងៃអាទិត្យទី ២១ វិច្ឆិកា៕





# លោកអភិបាលអេនរីគែ ហ្វីការេដូ ធ្វើដំណើរទៅតាមព្រះសហគមន៍ដើម្បីស្តាប់យោបល់គ្រីស្តបរិស័ទ







*អត្ថបទ៖ ព្រះសហគមន៍*

អភិបាលភូមិភាគបាត់ដំបង លោកអភិបាលអេនរីគេ ហ្វីការេដូ នឹងធ្វើដំណើរតាមព្រះសហគមន៍ក្នុងភូមិភាគនៅឆ្នាំក្រោយ ដើម្បីស្តាប់យោបល់និងសេចក្តីត្រូវការរបស់គ្រីស្តបរិស័ទនៅតាមព្រះសហគមន៍នីមួយៗ ក្នុងឱកាសសន្និបាតសកល២០២១-២០២៣ ដែលកំពុងរៀបចំឡើងនៅព្រះសហគមន៍កាតូលិកទូទាំងពិភពលោក។

លោកបូជាចារ្យចន ឡេស្ទើរ៍ អូ តាយ៉ុន ហៅ បុងបុង ជាតំណាងពេញសិទ្ធិលោកអភិបាលភូមិភាគបាត់ដំបងបានមានប្រសាសន៍ក្នុងពិធីបើកសន្និបាត ព្រះសហគមន៍កាតូលិកភូមិភាគបាត់ដំបង កាលពីថ្ងៃទី១៨ ខែវិច្ឆិកា កន្លងទៅនេះថា ក្នុងនាមសម្តេចប៉ាបលោកអភិបាលនឹងស្តាប់បងប្អូន ដើម្បីរកបងប្អូនឲ្យចូលរួមកសាងព្រះសហគមន៍ ប្រមូលឯកសារនិងមតិយោបល់ព័ត៌មានពីបងប្អូន ដើម្បីចូលរួមក្នុងសន្និបាតក្នុងឆ្នាំ២០២៣ ជាមួយក្រុមលោកអភិបាលនៅទីក្រុងរ៉ូម។

កម្មវិធីបើកសន្និបាតភូមិភាគបាត់ដំបង បានធ្វើឡើងនៅព្រះវិហារព្រះជាម្ចាស់លើកព្រះនាងម៉ារីឡើងស្ថានបរមសុខ នៅក្រុងបាត់ដំបង ខេត្តបាត់ដំបង តាមរយៈអនឡាញ និងមានតំណាងចូលរួមពីព្រះសហគមន៍នានាប្រមាណជិត១០០នាក់។

ក្នុងនោះដែរ លោកបុងបុង សូមឲ្យគ្រីស្តបរិស័ទទាំងអស់ចូលរួម ជួយអធិដ្ឋាន និងជួយគាំទ្រលោកអភិបាល តាមរយៈព្រះជាម្ចាស់និងព្រះវិញ្ញាណដ៏វិសុទ្ធដែលណែនាំ។

តាមការគ្រោងទុកពីខែមករាដល់ខែមេសាលោកអភិបាលអេនរីគេ និងលោកបូជាចារ្យយ៉ូសែប ហេអ៊ីន នឹងធ្វើដំណើរទៅតាមព្រះសហគមន៍នានាក្នុងភូមិភាគបាត់ដំបង ដើម្បីស្តាប់យោបល់និងសេចក្តីត្រូវការរបស់គ្រីស្តបរិស័ទ និងធ្វើរបាយការណ៍ទៅកាន់ទីក្រុងរ៉ូម ដែលលោកអភិបាលអេនរីគេនឹងចូលប្រជុំនៅទីនោះក្នុងឆ្នាំបន្ទាប់។

«ស្តាប់គ្នា អធិដ្ឋានជាមួយគ្នា» កុំខ្ជិលកសាងព្រះសហគមន៍ ជាពិសេសកូនៗជំនាន់ក្រោយ។ នេះជាប្រសាសន៍លោកអភិបាលអេនរីគេ ក្នុងថ្ងៃបើកសន្និបាតនេះ។

លោកអភិបាលអេនរីគេ បានមានប្រសាសន៍ថា ៖ «យើងរួមគ្នាអត់មានអ្នកណាចាញ់អ្នកណាឈ្នះ អត់ប្រកាន់គ្នា រួមគ្នាដូចបងប្អូន និងប្រព្រឹត្តតាមព្រះហឫទ័យព្រះជាម្ចាស់ យើងអត់និយាយតាមចិត្ត តែនិយាយតាមព្រះបន្ទូលរបស់ព្រះជាម្ចាស់។ នេះជាអត្ថន័យរបស់synodal។ យើងរួមគ្នាដើរតាមព្រះបន្ទូលរបស់ព្រះជាម្ចាស់»។

ក្នុងពេលនោះដែរ លោកអភិបាលក៏បានជំរុញឲ្យគ្រីស្តបរិស័ទត្រូវស្តាប់គម្ពីរ អានគម្ពីរ និងអនុវត្តតាមព្រះបន្ទូល។ ដោយលោកបានបញ្ជាក់ថា ៖ «ប្រកាសដំណឹងល្អបាន ត្រូវអានគម្ពីរដើម្បីស្គាល់ព្រះយេស៊ូ ...ដោយសារយើងប្រកាសអំពីព្រះយេស៊ូ និងត្រូវមានទំនាក់ទំនងជាមួយព្រះអង្គ ដោយអធិដ្ឋាន។ ពេលនេះយើងត្រូវស្តាប់ឱ្យបានច្រើន»។

លោកអភិបាលក៏រំលឹកនិងលើកទឹកចិត្តដល់គ្រីស្តបរិស័ទនិងអ្នកដឹកនាំព្រះសហគមន៍ក្នុងភូមិភាគទាំងអស់ ឲ្យធ្វើជាគំរូសម្រាប់អ្នកដទៃ ដោយបង្ហាញភាពជាបងប្អូន ស្តាប់គ្នាទៅវិញទៅមកទាំងលោកបូជាចារ្យ និងក្រុមបងស្រី។

ជាមួយគ្នានេះដែរ លោកអភិបាលអេនរីគេ បានបញ្ជាក់បន្ថែមទៀតថា ៖ «ក្នុងពេលនេះ ខ្ញុំអត់និយាយច្រើនទេ តែត្រូវស្តាប់បងប្អូនច្រើនជាងអំពីសេចក្តីត្រូវការ និងក្តីសង្ឃឹមអ្វីខ្លះពីព្រះសហគមន៍»។

ព្រះសហគមន៍កាតូលិកភូមិភាគបាត់ដំបងគ្របដណ្តប់ខេត្តចំនួន៨ មាន ខេត្តបាត់ដំបង ព្រះវិហារ បន្ទាយមានជ័យ ឧត្តរមានជ័យ សៀមរាប ពោធិ៍សាត់ កំពង់ឆ្នាំង និងខេត្តកំពង់ធំ។

សន្និបាតព្រះសហគមន៍សកល (Synodal) ២០២១-២០២៣ ត្រូវបានបើកឲ្យដំណើរការក្នុងរយៈពេល២ឆ្នាំ ដោយសម្តេចប៉ាបហ្វ្រង់ស៊ីស្ហ្គូ ក្រោមប្រធានបទ «យើងជាព្រះសហគមន៍ធ្វើដំណើរជាមួយគ្នា ជាធ្លុងតែមួយ ចូលរួមប្រកាសដំណឹងល្អ»។ ក្នុងសន្និបាតនេះ មានសំណួររិះគិត៣សំខាន់ៗសម្រាប់ព្រះសហគមន៍និងគ្រីស្តបរិស័ទទាំងអស់ពិចារណា និងធ្វើយ៉ាងណាដើម្បីឲ្យការប្រកាសដំណឹងល្អរបស់ព្រះសហគមន៍នៅក្នុងពិភពលោកទៅដល់មនុស្សគ្រប់ជាតិសាសន៍។

សំណួរទាំងនោះរួមមាន៖ តើនៅក្នុងព្រះសហគមន៍របស់ខ្ញុំផ្ទាល់ ខ្ញុំដើររួមជាមួយគ្នាដូចម្តេចតាមរយៈក្រុមនានានិងគណៈកម្មការ? នៅពេលយើងដើររួមជាមួយគ្នានៅក្នុងព្រះសហគមន៍របស់យើងផ្ទាល់ តើយើងជួបឧបសគ្គអ្វីខ្លះ? តើយើងជួបអំណរសប្បាយអ្វីខ្លះ? និង តាមបទពិសោធរបស់យើងនៅក្នុងការធ្វើដំណើររួមជាមួយគ្នានៅក្នុងព្រះសហគមន៍របស់យើងផ្ទាល់តើយើងត្រូវការកែប្រែអ្វីខ្លះ ដើម្បីឱ្យយើងរីកចម្រើននៅក្នុងការប្រកាសដំណឹងល្អដល់បងប្អូនទាំងអស់?៕





# លោកអភិបាលអូលីវីយេ ឲ្យគ្រីស្តបរិស័ទភ្ជាប់ស្មារតីភ្ជាប់ជាមួយព្រះជាម្ចាស់សាជាថ្មី

*អត្ថបទ៖ ដាលីស*

ក្នុងពិធីបុណ្យខួបលើកទី៩នៃការរកឃើញរូបសំណាកព្រះនាងម៉ារីទី២ ពីបាតទន្លេមេគង្គ លោកអភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ អូលីវីយេ ឆ្មឹតហស្លេ មានប្រសាសន៍ថា ព្រះនាងម៉ារីភ្ជាប់ជាមួយព្រះជាម្ចាស់រហូត។ ហើយនៅក្នុងពេលវេលាដែលបើកប្រទេសឡើងវិញនេះ ជាពេលវេលាដើម្បីភ្ជាក់ស្មារតីភ្ជាប់ជាមួយព្រះជាម្ចាស់សាជាថ្មី អធិដ្ឋានជាថ្មី ដើម្បីស្វាគមន៍ព្រះអង្គទាំងកម្លាំងកាយកម្លាំងចិត្ត។

ក្នុងកម្មវិធីនេះ ចាប់ផ្តើមដោយអធិដ្ឋានផ្តាំនៅមុខរូបសំណាកព្រះនាងម៉ារី ដែលមានកម្ពស់២,៣ម៉ែត្រ ធ្វើអំពីស្ពាន់ ដែលមានព្រះនាងម៉ារីបីព្រះកុមារយេស៊ូ ដែលបានដាក់នៅមុខទ្វារចូលនៃព្រះវិហារព្រះមាតានៃសន្តិភាពអរិយក្សត្រ។

ក្នុងធម្មទេសនានៅថ្ងៃប្រារព្ធពិធីនាថ្ងៃទី១៣ វិច្ឆិកា ២០២១ ដែលមានគ្រីស្តបរិស័ទចូលរួមជាច្រើនកុះករ ក្រោយពេលដែលរដ្ឋាភិបាលបានបើកប្រទេសឲ្យមានការជួបជុំសាសនានិងពិធីនានាឡើងវិញក្នុងរយៈពេលប៉ុន្មានថ្ងៃនេះ លោកមានប្រសាសន៍ដូច្នេះថា នេះជាឱកាសមួយ ដើម្បីរួមជាមួយម៉ារីនៅក្នុងអង្គព្រះយេស៊ូគ្រីស្តដែលណែនាំឱ្យយើងពោរពេញដោយសេចក្តីសុខនៅក្នុងជីវិតរបស់យើង ដែលយើងកំពុងតែមានសកម្មភាពនៅមានជីវិតសារជាថ្មី។

លោកអភិបាលបន្ថែមថា នេះជាថ្ងៃមួយដែលយើងទទួលអំណោយពិសេសនៅក្នុងពេលវេលាដែលយើងគោរពព្រះនាងម៉ារី គឺយើងទទួលអំណោយពិសេសសម្រាប់សង្គមរបស់យើង និងព្រះសហគមន៍របស់យើងដែលអាចជួបជុំគ្នាដើម្បីអធិដ្ឋាន អប់រំជំនឿ និងចួបជុំដោយមានសេរីភាពមិនភ័យខ្លាច។

លោកអភិបាលអូលីវីយេ សូមឲ្យគ្រីស្តបរិស័ទរំលឹកអំពីការសួរសុខទុក្ខរបស់ព្រះនាងម៉ារីចំពោះយាយអេលីសាប៊ែត ដែលមានចែងនៅក្នុងគម្ពីរដំណឹងល្អ និងការសួរសុខទុក្ខពីហោរាចារ្យដែលមកថ្វាយបង្គំព្រះយេស៊ូ។ លោកអភិបាលមានប្រសាសន៍ថា «យើងឃើញថាការសួរសុខទុក្ខមានរបៀបខុសៗគ្នា ដោយក្នុងរយៈពេលកន្លងមកនេះ យើងបានសួរសុខទុក្ខតាមរបៀបថ្មី តាមប្រព័ន្ធអ៊ីនធឺណែត»។

លោកអភិបាលពន្យល់ថា ការសួរសុខទុក្ខរបស់ព្រះនាងម៉ារី គឺព្រះជាម្ចាស់ដែលបានសួរសុខទុក្ខមនុស្សលោក។ ហើយហោរាចារ្យគឺតំណាងឲ្យមនុស្សសួរសុខទុក្ខព្រះជាម្ចាស់ដែលកំពុងរង់ចាំយើង។

លោកអភិបាលសង្កត់ធ្ងន់ថា ៖ «ដូច្នេះ សូមឱ្យយើង យកចិត្តទុកដាក់សួរសុខទុក្ខគ្នាទៅវិញទៅមកជាមួយបងប្អូនឯទៀតៗផ្ទាល់ ដើម្បីយល់ពីការលំបាក ផ្តល់សេចក្តីសង្ឃឹម ដោយលើកទឹកចិត្ត»។ ជាមួយគ្នានេះ លោកអភិបាលសូមឲ្យគ្រីស្តបរិស័ទចេះស្វាគមន៍ព្រះយេស៊ូនៅក្នុងដួងចិត្ត និងពិចារណាដើម្បីសួរសុខទុក្ខដល់បងប្អូនឯទៀតៗ។

លោក សុខ សិលា ប្រធានយុវជននៅព្រះសហគមន៍អរិយក្សត្រ បានឲ្យដឹងថា ចាប់តាំងពីមានរូបសំណាកព្រះនាងម៉ារីនៅទីនេះ គ្រីស្តបរិស័ទតែងមកអធិដ្ឋានជាមួយព្រះនាងម៉ារី មានទាំងអ្នកមិនមែនជាគ្រីស្តបរិស័ទផង។ លោកសិលាបន្តថា «ពិសេសអ្វីដែលខ្ញុំសង្កេតឃើញ គឺពួកគាត់បានទទួលនូវអ្វីដែលបានអធិដ្ឋាន។ ដូច្នេះព្រះនាងម៉ារីបានផ្តល់នូវអ្វីដែលពួកគេបានសុំ ដូចជាគូស្រករដែលមិនមានកូន អាចទទួលបានកូនក្រោយពេលសុំពីព្រះនាងម៉ារីមួយឆ្នាំ»។

ប្រធានព្រះសហគមន៍រូបនេះ ក៏បាននិយាយដែរថា «នៅពេលភរិយាខ្ញុំសម្រាលកូន គាត់មានសភាពពិបាក។ ដោយសារព្រះនាងម៉ារីភរិយានិងកូនរបស់ខ្ញុំមានសុវត្ថិភាព សុខភាពល្អទាំងម្តាយនិងកូន។ ដូច្នេះ សូមបងប្អូនរួមគ្នាអធិដ្ឋានជាមួយព្រះនាងម៉ារី សម្រាប់ព្រះសហគមន៍របស់យើង»។

លោកអភិបាលអូលីវីយេ មុននឹងបិទបញ្ចប់កម្មវិធីថ្វាយអភិបូជា បានរំឭកគ្រីស្តបរិស័ទ ឱ្យរក្សាពកុំពាការពារជានិច្ច និងប្រសិនបើបងប្អូនផ្តាសាយ សូមផ្អាកការចូលរួមមួយរយៈដោយធ្វើការព្យាបាលនិងនៅដាច់ដោយឡែករហូតដល់ជាទើបអាចមកចូលរួមសកម្មភាពនានាសាជាថ្មី។

រូបសំណាកព្រះនាងម៉ារី ទី២ រកឃើញ ១៩ វិច្ឆិកា ២០១២ ក្នុងថ្ងៃដែលប្រទេសកម្ពុជាទទួលរៀបចំកិច្ចប្រជុំអាស៊ាន។ រូបសំណាកព្រះនាងម៉ារីទីពីរនេះបានស្រង់ចេញពីបាតទន្លេមេគង្គ ដោយលោក ផាង វ៉ាំង ហ៊ូ ជាអ្នកនេសាទ និងជាពុទ្ធសាសនិក បន្ទាប់ពីព្រះនាងម៉ារីបានបង្ហាញខ្លួននៅក្នុងសុបិន្តរបស់គាត់។

មុនពេលគាត់ទទួលមរណភាព លោក វ៉ាំង ហ៊ូ ធ្លាប់និយាយថា ៖ «នៅពេលស្រង់រូបសំណាកនេះ ខ្ញុំមាអារម្មណ៍ថានេះមិនមែនជារូបសំណាកទេ គឺជារូបរាងមនុស្សដែលកំពុងមានជីវិតដូចយើង ខ្ញុំសប្បាយចិត្តផងភ័យផង ហើយបួងសួងព្រះនាងសូមឱ្យប្រពន្ធខ្ញុំបានជាសះស្បើយពីជំងឺ និងថ្វាយរូបសំណាកនេះទៅព្រះវិហារដោយមិនទាមទារអ្វីទាំងអស់»។ ច្រើនឆ្នាំកន្លងមក គ្រួសាររបស់គាត់ក៏ប្រែចិត្តគំនិតដោយជឿលើព្រះជាម្ចាស់ក្រោយពីស្រង់បានរូបសំណាកនេះ។ រីឯប្រពន្ធរបស់លោក ក៏ជាពីជំងឺមានសុខភាពល្អធម្មតារហូតមកដល់សព្វថ្ងៃនេះ៕










# លោកអភិបាលអូលីវីយេ រំឭកតួនាទីទាំងបីរបស់គ្រីស្តបរិស័ទ

*អត្ថបទ៖ ដាលីស*

លោកអភិបាលអូលីវីយេ មានប្រសាសន៍នៅក្នុងពិធីបុណ្យព្រះយេស៊ូជាព្រះមហាក្សត្រនៃពិភពលោក កាលពីថ្ងៃទី ថ្ងៃទី ២១ វិច្ឆិកា ២០២១ថា គ្រីស្តបរិស័ទមានតួនាទីបីសំខាន់ៗ ដែលត្រូវអនុវត្តនៅក្នុងជីវិតរស់នៅប្រចាំថ្ងៃ នោះគឺបូជាចារ្យ មហាក្សត្រ និងព្យាការី។

ក្នុងពិធីថ្វាយអភិបូជា នៅព្រះវិហារសន្តសិលាពោធិ៍ធំ ស្រុកល្វាឯម ខេត្តកណ្តាល លោកអភិបាលបានមានប្រសាសន៍ថា ថ្ងៃនេះក៏ជាថ្ងៃបុណ្យព្រះនាងម៉ារីថ្វាយខ្លួនទៅព្រះជាម្ចាស់ដែរ ហើយនេះជាឱកាសមួយ ដើម្បីសួរសុខទុក្ខបងប្អូន និងឱ្យយើងដឹងថាយើងមានឋានៈជាបុត្រធីតារបស់ព្រះជាម្ចាស់។

លោកអភិបាលបានបន្ថែមថា ក្នុងនាមជាប្រជារាស្ត្ររបស់ព្រះជាម្ចាស់យើងទទួលតួនាទី៣គឺ៖ បូជាចារ្យ ព្រះមហាក្សត្រ និងព្យាការី។

តួនាទីជាបូជាចារ្យ គឺត្រូវតែអធិដ្ឋានដើម្បីភ្ជាប់ជាមួយព្រះជាម្ចាស់ ដោយអធិដ្ឋានសម្រាប់យើងផ្ទាល់ និងសម្រាប់ពិភពលោកទាំងមូលឱ្យរកឃើញសេចក្តីសុខសាន្តសាជាថ្មី ឱ្យសង្គមរបស់យើងរកឃើញកម្លាំងសាជាថ្មី នៅក្នុងរដូវកូវី-១៩នេះ។ លោកអភិបាលបន្ថែមថា គ្រីស្តបរិស័ទត្រូវចូលរួមក្នុងពិធីថ្វាយអភិបូជា ដើម្បីស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ដែលចិញ្ចឹមជីវិតខាងវិញ្ញាណរបស់យើង។

រីឯតួនាទីជា ព្រះមហាក្សត្រ គឺមិនធ្វើតាមរបៀបលោកីយ៍នេះទេ។ ដោយមានព្រះយេស៊ូជាគំរូនៃព្រះមហាក្សត្រ គឺយើងត្រូវបម្រើគ្នាទៅវិញទៅមកតាមរបៀបព្រះយេស៊ូ។ ព្រះយេស៊ូបម្រើរហូតដល់សោយព្រះទិវង្គត ដូច្នេះសូមឱ្យយើងបម្រើគ្នាទៅវិញទៅមកទាំងនៅក្នុងព្រះសហគមន៍និងក្នុងសង្គម ដើម្បីឲ្យអ្នកដទៃមានសេចក្តីសុខតាមរបៀបដែលយើងជួយ តាមរបៀបដែលយើងលើកទឹកចិត្តគ្នាទៅវិញទៅមកក្នុងនាមយើងជាអ្នកបម្រើដ៏ពិតប្រាកដតាមរបៀបព្រះយេស៊ូ។

ចំណែកតួនាទីចុងក្រោយ គឺព្យាការី ជាអ្នកថ្លែងព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដោយស្តាប់និងអនុវត្តព្រះបន្ទូលតាមការរស់នៅក្នុងសេចក្តីពិត ដោយនាំឲ្យបងប្អូនឯទៀតៗបានស្គាល់ព្រះយេស៊ូ ឲ្យគេអាចទទួលបានការសង្គ្រោះពីព្រះអង្គ។

លោកអភិបាលអូលីវីយេ គ្រើនរំលឹកថា «ទោះបីយើងជាប់អំពើបាបក៏ដោយ ក៏យើងដឹងថា យើងមានព្រះយេស៊ូរំដោះយើង ទោះបីជាយើងស្លាប់នៅលើផែនដីក៏ដោយក៏យើងដឹងថាមានព្រះយេស៊ូដែលសង្គ្រោះយើង»។

លោក យ៉ែម សារី ជាគណៈកម្មការព្រះសហគមន៍ពោធិ៍ធំមានប្រសាសន៍ថា (Video) «តួនាទីទាំង៣មានន័យសម្រាប់ខ្ញុំ ដោយធ្វើឱ្យខ្ញុំមិនចោលព្រះវិហារនៅថ្ងៃអាទិត្យ ហើយតែងតែអធិដ្ឋាន ព្រោះថាជីវិតខាងផ្លូវវិញ្ញាណទាល់តែយើងឧស្សាហ៍អធិដ្ឋាន។ ប្រសិនបើយើងមិនអធិដ្ឋានទេ ជំនឿរបស់យើងក៏មិនសូវមាន ហើយប្រសិនបើយើងមិនចូលព្រះវិហារយូរ មានន័យថាជំនឿរបស់យើងក៏បាត់ដែរ ព្រោះថាជំនឿប្រៀបបាននឹងដុំភ្លើងសាកអាគុយ ដែលត្រូវសាកដោយព្រះបន្ទូលនិងការណែនាំពីលោកបូជាចារ្យរៀងថ្ងៃអាទិត្យ»។

តាមប្រពៃណីព្រះសហគមន៍កាតូលិក បុណ្យព្រះយេស៊ូជាព្រះមហាក្សត្រនៃពិភពលោក គឺជាតិសប្តាហ៍ចុងក្រោយន័យប្រតិទិនឆ្នាំចាស់របស់ព្រះសហគមន៍ មុនចូលដល់រដូវរង់ចាំដែលជាឆ្នាំថ្មីសម្រាប់ព្រះសហគមន៍កាតូលិក៕



# កញ្ញា ណម សុភី៖ «សក្ខីភាពរបស់សហគមន៍នៅក្នុងភូមិជំរុញឲ្យខ្ញុំផ្លាស់ប្តូរជំនឿ»

*អត្ថបទ៖ ឆាក លាំង*

«ខ្ញុំបានផ្លាស់ប្តូរជីវិតថ្មី របៀបរស់នៅថ្មីខុសពីមុន» ក្រោយពេលទទួលអគ្គសញ្ញាជ្រមុជទឹក។ នេះជាការលើកឡើងរបស់ កញ្ញា សុភី ដែលមានវ័យ៣៣ឆ្នាំ រស់នៅក្នុងគ្រួសារពុទ្ធបរិស័ទមួយមានប្អូនស្រីម្នាក់ មានតែម្តាយ ព្រោះឪពុកបានទទួលមរណភាពតាំងពីនាងនៅវ័យជំទង់។

កញ្ញា សុភី រស់នៅ ក្នុងភូមិតារាជ ឃុំត្រពាំងរាំង ស្រុកជុំគីរី ខេត្តកំពត មណ្ឌលសកម្មភាពកំពត បានក្លាយជាគ្រីស្តបរិស័ទក្នុងឆ្នាំ២០០៧។

កញ្ញាបានឲ្យដឹងថា នាងស្គាល់ព្រះសហគមន៍កាតូលិក តាំងពីកុមារភាព ដោយបានចូលរួមក្នុងសកម្មភាពមួយចំនួនរបស់ព្រះសហគមន៍ដែលមានក្រុមកុមារកាយឫទ្ធិ និងឃើញកិច្ចមនុស្សធម៌របស់ក្រុមសង្គហៈដែលព្រះសហគមន៍បានបង្កើតឡើង និងតែងតែជួយអ្នក ជួបការលំបាកនៅក្នុងភូមិ។

កញ្ញា ណម សុភី បានប្រាប់ថា ៖ «ខ្ញុំក៏ជាក្មេងម្នាក់ក្នុងចំនោមក្មេងនៅក្នុងភូមិ ដែលចូលក្នុងក្រុមកាយឫទ្ធិដើម្បីបានលេង បានញ៉ាំនំ ញ៉ាំស្ករគ្រាប់ បានផឹកទឹកគោ....ជាដើម។ ក្នុងពេលនោះ ក៏បានទទួលការអប់រំជំនឿខ្លះពីលោកគ្រូ អ្នកគ្រូដែលទៅពីភ្នំពេញ»។

កញ្ញាថា ៖ «ពីមួយថ្ងៃទៅមួយថ្ងៃខ្ញុំកាន់តែស្គាល់ព្រះសហគមន៍ច្រើនទៅៗ និងមើលឃើញកិច្ចការជួយអ្នកភូមិកាន់តែច្រើន ក៏សុំម្តាយចូលព្រះសហគមន៍ រហូតដល់ឆ្នាំ២០០៧ ក៏បានទទួលអគ្គសញ្ញាជ្រមុជទឹកក្លាយខ្លួនជាគ្រីស្តបរិស័ទ»។

ក្រោយទទួលជីវិតជាគ្រីស្តបរិស័ទ កញ្ញា សុភី បានផ្លាស់ប្តូរជីវិតរបៀបរស់នៅថ្មីខុសពីមុន ដោយចេះជួយចែករំលែកធនធានតាមលទ្ធភាពដល់អ្នកក្រីក្រលំបាក ចេះអធិដ្ឋានសម្រាប់អ្នកដទៃ សួរសុខទុក្ខអ្នកជំងឺ និងព្យាយាមបង្ហាញពីព្រះហឫទ័យប្រណីសន្តោសរបស់ព្រះជាម្ចាស់តាមរយៈការងារដែលរូបនាងបានប្រព្រឹត្តទៅអ្នកដទៃ។

រស់នៅក្នុងជីវភាពជាកូនកំព្រាឪពុក កញ្ញាបានរស់នៅជាម្តាយ ជាកសិករដើម្បីចិញ្ចឹមជីវិតគ្រួសារ។ កញ្ញាបានបន្តថា ៖ «ម្តាយរបស់ខ្ញុំ និងអ្នកភូមិ (គ្រីស្តបរិស័ទ) បានស្គាល់ព្រះសហគមន៍តាមកិច្ចការមនុស្សធម៌ នៅក្នុងភូមិ ហេតុនេះហើយ ការប្តូជំនឿមកជាគ្រីស្តបរិស័ទ មិនមានផលលំបាកអ្វីទេពីក្រុមគ្រួសារ តែដល់ពេលខ្ញុំមករៀននៅសាលាក៏មានមិត្តមួយចំនួនបានរើសអើង»។

កញ្ញា សុភី បានបន្ថែមថា ៖ «ពេលខ្ញុំដើរចូលទៅក្នុងថ្នាក់គេនាំគ្នាសើច ដោយអ្នកខ្លះថា ភូមិខ្ញុំជាភូមិយេស៊ូ ពួកអាយេស៊ូ ពួកសាសនាដទៃ ពួកនេះមិនចេះគោរពឪពុកម្តាយ និងមិនសូវមានអ្នកនិយាយលេងជាមួយដូចមិត្តដទៃទៀតនោះឡើយ»។

ទោះជាយ៉ាងណាក៏ដោយ នាងមិនបានខឹងនឹងមិត្តរួមថ្នាក់ និងអ្នកណាដែលចំអកនាងទេ។ កញ្ញា សុភី បាននិយាយថា ៖ «ព្រះសហគមន៍បានបង្រៀនឲ្យខ្ញុំចេះស្រឡាញ់ និងចេះលើកលែងទោសអស់បងប្អូនដែលនៅជិតខ្លួន ទោះពេលខ្លះពិបាកធ្វើ តែខ្ញុំបានខិតខំអធិដ្ឋាន សុំព្រះជាម្ចាស់ជួយបំភ្លឺគេឲ្យគេយល់ និងទទួលយកជំនឿដែលខ្លួនមានលើព្រះយេស៊ូ នៅពេលណាមួយ»។

កញ្ញា ណម សុភី បច្ចុប្បន្នជាគ្រូសាលាមត្តេយ្យនៅព្រះសហគមន៍ជុំគីរី ហើយទោះបីជាកញ្ញាបានជួបរឿងអ្វីក៏ដោយ ក៏នាងមិនដែលមានគំនិតចង់ផ្លាស់ប្តូរជំនឿនោះឡើយ។ គ្រីស្តបរិស័ទរូបនេះគូសបញ្ជាក់ថា នាពេលខាងមុខនាងនឹងរស់នៅដោយសេចក្តីស្រឡាញ់ ខិតខំប្រកាសដំណឹងល្អទៅអ្នកជុំវិញខ្លួន ព្យាយាមអធិដ្ឋានសម្រាប់ក្រុមគ្រួសារ សម្រាប់ប្រជាជន និងពិភពលោកទាំងមូល៕



# លោក ប្រាក់ ប៊ុនហុង ឧបដ្ឋាកថ្មីជាតិពូណងដំបូងគេ



*អត្ថបទ៖ កែវ កញ្ញា*

របាំក្មេងរាំពត់ពេន ជាមួយចង្វាក់ភ្លេង ពីមុខព្រះវិហារសន្តយ៉ូសែប នៃព្រះសហគមន៍ក្តុលលើ នាំមុខក្បួនដង្ហែរឈើឆ្កាងដែលមានលោកបូជាចារ្យ បេក្ខជនត្រូវទទួលពិធីតែងតាំងជាឧបដ្ឋាក និងក្រុមលោកអភិបាលព្រះសហគមន៍បីភូមិភាគ ចូលមកក្នុងព្រះវិហារដើម្បីប្រារព្ធពិធី។

លោកយ៉ូហាន បាទីស្ត ប្រាក់ ប៊ុន ហុង ជានិស្សិតទេវវិទ្យាល័យ សន្តម៉ារីយ៉ាណែរ នៅប្រទេសកម្ពុជា ទទួលតែង តាំង ជា ឧដ្ឋាក ដើម្បីបម្រើការងារនៅក្នុងព្រះសហគមន៍ក្នុងភូមិភាគកំពង់ចាម។

ពិធីនេះ បានធ្វើឡើងកាលពីថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២១ ដែលមានអ្នកចូលរួមប្រមាណ២០០នាក់ នៅ ព្រះសហគមន៍ក្តុលលើ ក្នុងស្រុកក្រូចឆ្មារ ខេត្តត្បូងឃ្មុំ។

ឧដ្ឋាកជាពិធីមួយដើម្បីឈានទៅរកអគ្គសញ្ញាតែងជាបូជាចារ្យកាតូលិក ក្នុងពេលខាងមុខនេះ។ មុខងារឧបដ្ឋាក ក្នុងព្រះសហគមន៍កាតូលិក គឺអាចរៀបចំអគ្គសញ្ញាអាពាហ៍ពិពាហ៍ ធ្វើអគ្គសញ្ញាជ្រមុជទឹក បកស្រាយអត្ថបទព្រះគម្ពីរ និង ធ្វើពិធីបុណ្យសព។

ក្នុងអង្គពិធី នៅមុខព្រះសហគមន៍ដែលជាគ្រួសារដ៏ធំមួយក្នុងជំនឿ លោកអភិបាលអូលីវីយេ ឝ្មីតហាស្លេ អភិបាលនៃព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ បានត្រាស់ហៅលោកយ៉ូហាន បាទីស្ត ប្រាក់ ប៊ុន ហុង មកបង្ហាញខ្លួន និងត្រៀបដៃដោយអធិដ្ឋានអង្វរព្រះជាម្ចាស់ ជាសញ្ញាតែងតាំងជាឧបដ្ឋាក ដើម្បីបម្រើព្រះសហគមន៍។

លោកអភិបាលអូលីវីយេ មានប្រសាសន៍ក្នុងធម្មទេសនាថា «ថ្ងៃនេះយើងមានហុងនៅជាមួយយើង ជាឧបដ្ឋាក ជាបូជាចារ្យជនជាតិពូណងមុនគេបង្អស់ សម្រាប់ព្រះសហគមន៍កាតូលិកនៅទូទាំងប្រទេសកម្ពុជា» គាត់បានចូលរួមជាមួយលោកអន់ជ្រេ និងឡីស្វេហ្វនិងគ្រីស្តបរិស័ទ ដើម្បីបម្រើព្រះសហគមន៍។

លោកអភិបាលបានបន្ថែមទៀតថា លោកឧបដ្ឋាកថ្មី ប្រៀបដូចជាស្ពានមួយ ដើម្បីបន្តបេសកកម្មប្រកាដសដំណឹងល្អរបស់ព្រះជាម្ចាស់។ លោកបានលើកឡើងថា ក្នុងភូមិភាគនីមួយមានគ្រីស្តបរិស័ទជាច្រើន ដែលត្រូវការអ្នកមើលថែ និងផ្តល់សក្ខីភាពអំពីសកម្មភាពនានាដែលធ្វើសម្រាប់អ្នកក្រីក្រ។ «នេះជាបេសកកម្មមួយដែលទទួលនិងជាស្ពានមួយយ៉ាងពិសេស។» លោកអភិបាលបញ្ជាក់។

តាមប្រសាសន៍របស់លោកអភិបាល ឲ្យដឹងទៀតថា ឧបដ្ឋាក គឺសញ្ញាលះបង់ចោលអ្វីទាំងអស់ បម្រើមិនគិតប្រយោជន៍ផ្ទាល់ខ្លួន និងផ្ញើជីវិតទៅព្រះជាម្ចាស់។ ក្នុងនោះដែរ លោកអភិបាលក៏បានថ្លែងអំណរគុណដល់ក្រុមគ្រួសារ និងព្រះសហគមន៍ ដែលរួមគ្នាដើរជាមួយគ្នា ជាពិសេសលោកឧបដ្ឋាកប្រាក់ប៊ុនហុង ដែលបានលះបង់ខ្លួនថ្វាយព្រះជាម្ចាស់។

លោកឧបដ្ឋាក ប្រាក់ ប៊ុន ហុង មកពីគ្រួសារគ្រីស្តបរិស័ទ ជនជាតិខ្មែរភាគតិចពូណង នៅក្នុងខេត្ត មណ្ឌលគិរី មានបងប្អូនប្រុសស្រីចំនួន៧នាក់ ជាកូនទី៤ បានចូលក្នុងទេវវិទ្យាល័យក្នុងឆ្នាំ ២០១៤។

លោកប្រាក់ប៊ុនហុងមានប្រសាសន៍ថា «ខ្ញុំមានអារម្មណ៍ថា ភ័យផង ព្រួយផង តែពិតមែន ខ្ញុំមានអំណរសប្បាយខ្លាំងមែនទែន។ ថ្ងៃនេះ ជាថ្ងៃពិសេសសម្រាប់ខ្ញុំ ហើយមានតែម្តងក្នុងមួយឆាកជីវិត»។

លោកឧបដ្ឋាកថ្មីបានឲ្យដឹងថា យុវជនត្រូវការសក្ខីភាពអំពីសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់សម្រាប់ពួកគេ តាមរយៈការផ្តល់សក្ខីភាពរបស់អ្នកបួស ដែលបង្ហាញអំពីភាពស្មោះត្រង់ និងចិត្តចង់បម្រើព្រះសហគមន៍។

លោកប៊ុនហុងបញ្ជាក់ថា «ក្រៅពីហ្នឹង ខ្ញុំគិតថា យើងមិនអាចទាក់ពួកគេ (យុវជន) ត្រឹមតែពាក្យសម្តី ការឲ្យគេមកតែប៉ុណ្ណឹងទេ ប៉ុន្តែយើងត្រូវមានកាយវិការ អត្តចរិក សកម្មភាពដែលយើងប្រកាសស្របនឹងព្រះបន្ទូលព្រះជាម្ចាស់។ នេះជាអ្វីសំខាន់ បង្ហាញឲ្យពួកគេ ទាក់ទាញយុវជនឲ្យរិះគិតអំពីការត្រាស់ហៅ ជាបូជាចារ្យ ឬបងប្រុសបងស្រី»។

ក្រោយពេលតែងតាំង លោកឧបដ្ឋាកថ្មី នឹងទៅបម្រើការងារនៅព្រះសហគមន៍ក្នុងខេត្តរតនគិរី និងស្ទឹងត្រែង ដើម្បីសិក្សាឈ្វេងយល់អំពីរបៀបនៃកិច្ចការបម្រើព្រះសហគមន៍ និងរៀនពីរបៀបរស់នៅនិងការប្រកាសដំណឹងល្អដល់បងប្អូនក្នុងសហគមន៍។

លោកអភិបាលប្រ៊ុយណូ កូសម៍ ជាអភិបាលនៃព្រះសហគមន៍កាតូលិកភូមិភាគកំពង់ចាម ដែលលោកប្រាក់ប៊ុនហុងនឹងត្រូវបម្រើនៅក្នុងពេលខាងមុខនេះ បានមានប្រសាសន៍ថា ក្នុងរយៈពេលប៉ុន្មានខែទៅមុខ គឺមុនពេលទទួលអគ្គសញ្ញាតែងតាំងជាបូជាចារ្យ លោកឧបដ្ឋាក ប្រាក់ ប៊ុនហុង នឹងទៅរៀនបម្រើការងារនៅខេត្តរតនគិរី និងស្ទឹងត្រែង ដោយមានតួនាទីធ្វើធម្មទេសនាថ្ងៃអាទិត្យ ធ្វើពិធីជ្រមុជទឹក ជួយដល់គ្រួសារដែលចង់ទទួលអគ្គសញ្ញាអាពាហ៍ពិពាហ៍ និងមានឱកាសចុះសួរសុខទុក្ខអ្នកភូមិ។

«នេះជាដូចជាឱកាសមួយដើម្បី(ឧបដ្ឋាកថ្មី) ចូលរួមយ៉ាងជិតស្និទ្ធជាមួយលោក(បូជាចារ្យ) បងស្រី នៅព្រះសហគមន៍ និងជាពេលវេលាពិសេសដែរ ដើម្បីត្រៀមខ្លួនទទួលអគ្គសញ្ញាតែងតាំងជាបូជាចារ្យ» លោកអភិបាលប្រ៊ុយណូ បញ្ជាក់។

លោកឧបដ្ឋាក យ៉ូហានបាទីស្ត ប្រាក់ ប៊ុនហុង នឹងទទួលតែងតាំងជាបូជាចារ្យនៅក្នុងឆ្នាំ២០២២ខាងមុខនេះ។

សព្វថ្ងៃនេះ ព្រះសហគមន៍កាតូលិកនៅកម្ពុជា មានសាសនទូតជាង១០០នាក់មកពីប្រទេសនានាក្នុងពិភពលោក ដើម្បីបម្រើនិងប្រកាសដំណឹងល្អដល់ប្រជាជនក្នុងប្រទេសកម្ពុជា ក្នុងនោះមានបូជាចារ្យ កាតូលិកជាតិខ្មែរ ត្រឹមតែ៨នាក់តែប៉ុណ្ណោះ និងមាននិស្សិតកំពុងសិក្សានៅក្នុងទេវវិទ្យាល័យចំនួន៨នាក់៕





# សកម្មភាពនានានៃព្រះសហគមន៍កាតូលិកកម្ពុជា

## ព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ



## ព្រះសហគមន៍កាតូលិកភូមិភាគកំពង់ចាម



## ព្រះសហគមន៍កាតូលិកភូមិភាគបាត់ដំបង

